ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- [illegible]
- [illegible]

[illegible]

លេខ៤០ ខែ មេសា ឆ្នាំ២០០៣

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៤០ ខែមេសា ឆ្នាំ២០០៣


## មាតិកា


◆ សំបុត្រៈ ការរសាយចិត្ត និងការផ្សះផ្សាជាតិ ..........................១

**ផ្នែកឯកសារ**

◆ បទសម្ភាសន៍របស់សមមិត្ត ប៉ុល ពត ..........................២

◆ សំណល់ដ៏អសោចពីបារាំងៈ ទូរលេខ៦៦ ..........................៧

◆ មាគ៌ាជាយុទ្ធសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ ..........................៨

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស ..........................១១

◆ របាយការណ៍របស់ អៀង សារី ..........................១២

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ............១៧

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ ពីជ័យជម្នះទៅការបំផ្លាញខ្លួនឯង ..........................១៨

◆ មនុស្សតែងតែចង់រស់ ..........................២១

◆ ដឹងការពិតនាំឲ្យចិត្តរសាយ ..........................២៣

**ផ្នែកច្បាប់**

◆ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាល ........២៨

**វេទិកាពិភាក្សាសាធារណៈ**

◆ ការបោះជំហានដ៏សំខាន់មួយ ..........................៣៨

◆ ផ្លូវដែលត្រូវប្រកាន់យកក្នុងពេលខាងមុខ ..........................៤១

◆ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ..........................៥៣

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ជីវិតពលិកម្មដើម្បីបក្សនិងបដិវត្តន៍ ..........................៥៨

◆ គេមិនត្រូវការធ្វើឲ្យយុត្តិធម៌ទៅជារឿងសាមញ្ញទេ ..........................៦០

**សិល្បៈខ្មែរក្រហម**

◆ រូបថតខ្មែរក្រហម ..........................ក្របក្រោយ





## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩


រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង


**ស្នាដៃលេខនេះៈ** គីម ម៉ូលីដា, អៀប ឌុច, ហុកប៉េង ឆាយ, ចន ឆរធីអារី, ស៊ូហ្សាណា លីនគុន, យិន នាន **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សើ សាយ្យាណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** សួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# ការរំសាយចិត្ត និងការផ្សះផ្សាជាតិ

«*បន្សុទ្ធកម្មនៃសតិអារម្មណ៍*» យោងតាមវចនានុក្រមភាសាអង់គ្លេសមានន័យថា ជាបន្សុទ្ធកម្មតាមរយៈសិល្បៈកម្សាន្ត គឺជាបន្សុទ្ធកម្មមួយដែលនាំមកនូវភាពស្រស់បស់ឡើងវិញខាងផ្លូវចិត្ត ឬនាំមកនូវការបន្ធូរភាពតានតឹងក្នុងអារម្មណ៍ ។ ចំណែកឯពាក្យថា «បម្លាស់ប្តូរដែលនាំឲ្យមានអារម្មណ៍ធូរស្រាល» មានន័យថា ជាបម្លាស់ប្តូរភ្លាមៗដែលគួរឲ្យកត់សម្គាល់និងដែលគួរឲ្យភ្ញាក់ផ្អើល ។ ពោលគឺបម្លាស់ប្តូរដែលធ្វើឲ្យមនុស្សម្នាក់ទទួលបាននូវទស្សនៈថ្មីសន្លាងមួយចំពោះពិភពលោកឬចំពោះស្ថានភាពបច្ចុប្បន្នដែលបុគ្គលនោះកំពុងតែជួបប្រទះ ។ មិនតែប៉ុណ្ណោះទៀតសោត ការផ្លាស់ប្តូរបែបនេះមានឥទ្ធិពលធ្វើឲ្យមនុស្សម្នាក់មានអារម្មណ៍កាន់តែប្រសើរឡើង ។

សូមលើកយកឧទាហរណ៍គំរូមួយមកបញ្ជាក់ជូនដែលទាក់ទងនឹងដល់ចិត្តកប្ចា (ការប្រើប្រាស់ក្បួនចិត្តសាស្ត្រដើម្បីព្យាបាលជំងឺផ្លូវចិត្ត) ។ សន្មតថាមានអ្នកជំងឺម្នាក់ដែលកំពុងមានជំងឺបាក់ទឹកចិត្តនិងភាពងឿងឆ្ងល់ បានចូលមកពិគ្រោះជំងឺជាមួយវេជ្ជបណ្ឌិតចិត្តសាស្ត្រម្នាក់ ។ បន្ទាប់ពីមានការពិគ្រោះអំពីអាការជំងឺរួចមក អ្នកជំងឺនោះស្រាប់តែនឹកឃើញថា អ្វីដែលគាត់ចេះតែព្រួយបារម្ភ គឺបណ្តាលមកពីបញ្ហាមួយចំនួនដែលគាត់ធ្លាប់ជួបប្រទះកាលនៅវ័យកុមារ ។ ប៉ុន្តែការណ៍នេះមិនមានឥទ្ធិពលអ្វីទៅលើរូបគាត់ទៀតទេនៅពេលបច្ចុប្បន្ន ។ ដូច្នេះគាត់ក៏មានអារម្មណ៍ធម្មតាឡើងវិញ ហើយរស់នៅដោយសប្បាយរីករាយ ។ ការដឹងខ្លួនបែបនេះអាចហៅថា “ការផ្លាស់ប្តូរដែលនាំឲ្យមានអារម្មណ៍ធូរស្រាល” ។

ក្នុងករណីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ជាការច្បាស់ណាស់ថាប្រជាជនកម្ពុជាជាច្រើននៅតែរងឥទ្ធិពលពីរបបខ្មែរក្រហមនៅឡើយ ហើយត្រូវការជាចាំបាច់នូវការផ្សះផ្សាតាមវិធីនេះ ។ កិច្ចការរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាគឺផ្អែកទៅលើជំនឿមួយថា តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងជួយនាំមកនូវការផ្លាស់ប្តូរភ្លាមៗនិងគួរឲ្យកត់សម្គាល់ជាមិនខាន ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងក្លាយជាព្រនង់មួយវាយបំបាក់វប្បធម៌ «និទណ្ឌភាព» ។ ការជំនុំជម្រះក្តីនឹងផ្តល់ឲ្យជនរងគ្រោះភាគច្រើននូវភាពធូរស្បើយក្នុងអារម្មណ៍ ព្រមទាំងបង្ហាញដល់មហាជននូវហេតុការណ៍សម្ងាត់ផ្សេងៗជុំវិញអំពើប្រល័យពូជសាសន៍ ជាពត៌មានដែលប្រជាជនកម្ពុជាមិនបានដឹងពីមុនមក ។ ការដឹងនូវពត៌មានចេញពីតុលាការនេះ នឹងក្លាយជាការរំសាយចិត្តសម្រាប់អ្នកដែលកំពុងតែទទួលផលប៉ះពាល់ពីអំពើប្រល័យពូជសាសន៍ ។ ហេតុការណ៍នេះនឹងចូលទៅក្នុងករណីមួយហៅថា “ការពិតអាចធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្បើយលែងខ្វល់ខ្វាយ” ។ តាមវិធីនេះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមនឹងរួមចំណែកដល់ការផ្សះផ្សាជាតិ ។

ចាប់តាំងពីដើមឆ្នាំ២០០២មក មានមន្ទិលសង្ស័យកាន់តែខ្លាំងឡើងៗថា មេដឹកនាំខ្មែរក្រហមនឹងមិនត្រូវបាននាំមកកាត់ទោសចំពោះមុខតុលាការព្រហ្មទណ្ឌទេ ។ ក្នុងនាមជារដ្ឋអធិបតេយ្យ កម្ពុជាមានកាតព្វកិច្ចអនុវត្តច្បាប់របស់ខ្លួននៅក្នុងខណ្ឌសីមារបស់ខ្លួន ក៏ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជាហាក់ដូចជាមានភាពស្ទាក់ស្ទើរក្នុងការចោទប្រកាន់ជនដែលត្រូវបានស្គាល់ជាទូទៅថាជាចារីនៃបទឧក្រិដ្ឋប្រល័យពូជសាសន៍ដែលកំពុងតែរស់នៅយ៉ាងរំភើយនៅក្នុងទឹកដីកម្ពុជា ។ ការអះអាងនានាដែលថាបញ្ហានេះទុកឲ្យតុលាការជាអ្នកដោះស្រាយ មិនមានលក្ខណៈស្មោះត្រង់ទេ ។ ក្នុងបញ្ហាឧក្រិដ្ឋកម្ម អំណាចនីតិប្រតិបត្តិជាអ្នកទទួលខុសត្រូវខាងចោទប្រកាន់ ចំណែកឯអំណាចតុលាការគឺជាអ្នកចេញសាលក្រម ។ ចុះហេតុអ្វីបានជារាជរដ្ឋាភិបាលកម្ពុជាមិនព្រមចោទប្រកាន់ជាផ្លូវការទៅលើមេដឹកនាំខ្មែរក្រហម? រាជរដ្ឋាភិបាលកម្ពុជាតែងតែទទូចហើយទទូចទៀតថា ខ្លួនចង់បានជំនួយអន្តរជាតិចំពោះបញ្ហាតុលាការខ្មែរក្រហម ហើយខ្លួននៅតែបន្តស្វែងរកការចរចាបន្ថែមទៀតជាមួយ **(តទៅទំព័រ៤៨)**

*(ឯកសារដកស្រង់ចេញពីវិទ្យុផ្សាយសំឡេងកម្ពុជាប្រជាធិបតេយ្យ)*

# បទសម្ភាសន៍របស់សមមិត្ត ប៉ុល ពត លេខាគណៈកម្មាធិការមជ្ឈិម បក្សកុម្មុយនិស្តកម្ពុជា រដ្ឋមន្ត្រីទីមួយនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាមួយតំណាងកាសែតវិុនវ័យប៉ូ និង កាសែត គាគុណាប៉ាវ នៅហុងកុង

កាលពីថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៧៨ វេលារសៀល នៅវិមានរដ្ឋសមមិត្ត ប៉ុល ពត លេខាគណៈកម្មាធិការមជ្ឈិមកុម្មុយនិស្តកម្ពុជា រដ្ឋមន្ត្រីទីមួយនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ បានទទួលជួបសន្ទនាជាមួយលោក ម៉ៃ ហ្វាចាំង តំណាងកាសែតវិុនវ័យប៉ូ និងលោក ហុង ចុងលាំង តំណាងកាសែត គាគុណាប៉ាវ ប្រចាំហុងកុង ។ សមមិត្តរដ្ឋមន្ត្រីទីមួយ ប៉ុល ពត បានឆ្លើយនឹងសំណួរសម្ភាសន៍របស់កាសែតជាមិត្តទាំងពីរដោយរាក់ទាក់កក់ក្ដៅ ។ ខ្លឹមសារនៃបទសម្ភាសន៍នេះមានដូចតទៅ÷

***សំណួរទីមួយៈ*** *ឯកឧត្តមរដ្ឋមន្ត្រីទីមួយ ប៉ុល ពត ជាទីគោរព ចាប់តាំងពីដំណាច់ឆ្នាំ១៩៧៧មក ប្រភពពត៌មាននៅលើសកលលោកបានចុះផ្សាយដំណឹងផ្សេងៗអំពីសង្គ្រាមនៅព្រំដែនកម្ពុជា-វៀតណាម ជារឿយៗ ព្រឹត្តិការណ៍ទាំងអស់នេះបាននាំឲ្យមតិសកលលោកចាប់អារម្មណ៍រហូត ។ តើអ្វីដែលនាំឲ្យផ្ទុះសង្គ្រាមអ៊ីចឹង ។ សភាពការណ៍ជាក់ស្ដែងយ៉ាងម៉េចទៅ?*

**ចម្លើយៈ** ក្នុងដំណើរទស្សនកិច្ចមួយរយៈនេះនៅកម្ពុជាប្រជាធិបតេយ្យ អស់លោកបានជ្រាបសភាពការណ៍ ប្រជាជនយើងខ្ញុំប្រយុទ្ធបង្កបង្កើនផលដោះស្រាយជីវភាពរបស់ខ្លួន ហើយអស់លោកក៏បានអញ្ជើញទៅមើលនៅសមរភូមិ ហើយបានជ្រាបដោយផ្ទាល់នូវការប្រយុទ្ធរបស់ប្រជាជនកម្ពុជាការពារទឹកដីដ៏ពិសិដ្ឋរបស់យើងខ្ញុំប្រឆាំងយួនឈ្លានពានវាតទីលេបទឹកដី ។ ដូច្នេះច្បាស់ជាអស់លោកបានឃើញសភាពការណ៍ជាក់ស្ដែងនៃកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ ។ ក្នុងឱកាសដែលខ្ញុំជួបអស់លោកពេលនេះ ក៏សុំជម្រាបថែមនូវសភាពការណ៍នៃកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ ។ យើងខ្ញុំតស៊ូបដិវត្តជាបន្តបន្ទាប់មក មានទិសដៅរំដោះប្រជាជាតិ ប្រជាជនកម្ពុជាឲ្យផុតពីខ្ញុំកញ្ជះគេ រស់នៅក្នុងឯករាជ្យក្នុងទឹកដីរបស់ខ្លួន ។ ដូច្នេះបានជាយើងខ្ញុំកំណត់ក្នុងរដ្ឋធម្មនុញ្ញឲ្យកម្ពុជា ឯករាជ្យ អធិបតេយ្យ អព្យាក្រឹតសន្តិភាព មិនចូលបក្សសម្ព័ន្ធ ឲ្យប្រជាជនរស់នៅដោយសុខសាន្តមានឱកាសកសាងប្រទេសជាតិរបស់ខ្លួនដោយឯករាជ្យម្ចាស់ការ ។ ដូច្នេះហើយបានជារំដោះភ្លាម យើងខ្ញុំខំស្ដារសេដ្ឋកិច្ចនិងកសាងប្រទេសដោះស្រាយស្បៀងដោយគោលជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួន ។ មួយផ្នែកទៀត យើងខ្ញុំខំទៅទាក់ទងប្រទេសជិតខាងសំដៅរឹតចំណងមិត្តភាព រួមរស់ជិតខាងគ្នាដោយសន្តិភាព ។ ហេតុនេះបានជានៅខែមិថុនា ១៩៧៥ ប្រតិភូជាន់ខ្ពស់នៃបក្សកុម្មុយនិស្តកម្ពុជាយើងខ្ញុំ ទៅធ្វើទស្សនកិច្ចនៅហាណូយ ។ ខែតុលា ១៩៧៥ យើងខ្ញុំបានទៅលាវ ។ នៅខែតុលា ១៩៧៥ យើងខ្ញុំបានទៅថៃ ។ ទាំងអស់នេះក៏ដើម្បីចង់ទាក់ទងជាមិត្តភាពនិងរួមរស់ដោយសន្តិភាពជាមួយប្រទេសជិតខាង ។ ប៉ុន្តែយើងខ្ញុំក៏ជួបឧបសគ្គដោយប្រទេសជិតខាងខ្លះមានបំណងអាក្រក់ មិនទទួលសុឆន្ទៈរបស់កម្ពុជាប្រជាធិបតេយ្យ ។ គេរឹងរូសបន្តឈ្លានពានកម្ពុជាប្រជាធិបតេយ្យ ។ នេះមកពីយួនវាមានយុទ្ធសាស្ត្រជាយូរមកហើយ ចង់យកកម្ពុជាជាផ្នែកមួយរបស់វា ។ តាមនយោបាយសហព័ន្ធឥណ្ឌូចិន យើងខ្ញុំរំដោះភ្លាម វាឈ្លានពានយកកោះវ៉ៃ ។ នៅតាមព្រំដែនគោក ក៏វាបុករុកយើងខ្ញុំមិនឈប់ឈរ ដោយមានបំណងឲ្យយើងខ្ញុំសារភាពវា ។ ប៉ុន្តែយើងខ្ញុំមិនសុខចិត្តសារភាពវា ព្រោះយើងខ្ញុំត្រូវការឯករាជ្យ ។ ដូច្នេះបានជាវាខឹងណាស់ វាវ៉ៃយើងខ្ញុំ ។ នៅចុងឆ្នាំ១៩៧៧ វាចាប់ផ្ដើមវាយធំ មានទាំងយួនឈ្លានពាន មានទាំងវាតទីនិយមអន្តរជាតិសូវៀត ហើយបក្សពួកវាតទីនិយមផង ។ វារួមគ្នាវាយយើងខ្ញុំ វាសំដៅវាយយកកម្ពុជាដោយអនុវត្តយុទ្ធសាស្ត្រវាយតែមួយ

ព្រឹបតាមយុទ្ធសាស្ត្រវាយរហ័សឈ្នះរហ័ស ។ បើវាសម្រេចយុទ្ធសាស្ត្រវាយរហ័សឈ្នះរហ័ស វាដោះស្រាយបញ្ហាបានទាំងអស់ យោធា នយោបាយ ទាំងក្នុងប្រទេសទាំងក្រៅប្រទេស ។ វានឹងក្តាប់ប្រជាជនកម្ពុជាក្នុងកណ្តាប់ដៃរបស់វា ។ វារួមគ្នាដោយម្យ៉ាង យួនចង់យកកម្ពុជាជាដីរបស់វាជាយូរមកហើយ តាមនយោបាយប្រទេសតែមួយ ប្រជាជនតែមួយ ក្រោមការដឹកនាំតែមួយរបស់វា ។ ទន្ទឹមនឹងនេះ យួនក៏ចង់ធ្វើមហាអំណាចនៅឥណ្ឌូចិន ហើយរុលទៅអាស៊ី-អាគ្នេយ៍ទៀត ។ ឯខាងវាតទីនិយមអន្តជាតិសូវៀត វាមានយុទ្ធសាស្ត្រសកលរបស់វា ហើយក្នុងនេះវាចង់ដណ្តើមក្តាប់យកអាស៊ី-អាគ្នេយ៍ ។ ដើម្បីដណ្តើមយកអាស៊ី-អាគ្នេយ៍ វាត្រូវដោះស្រាយបញ្ហាកម្ពុជាដែលជាឧបសគ្គគន្លឹះដល់យួនផងនិងដល់វាតទីនិយមអន្តរជាតិសូវៀតផង ។ ដូច្នេះបានជាវារួមគ្នាវាយកម្ពុជា មានផែនការវាយបើកកម្ពុជាភ្លាមតែម្តង ។ ដូច្នេះហើយបានជាវាប្រើកម្លាំងកងទ័ពធំដល់ទៅ១៤កងពល ។ ក្នុងនោះមាន៩កងពលស្រួចវាយបុក រថក្រោះក៏ច្រើនមានទាំងរថក្រោះសូវៀតសន្ទឹកសន្ទាប់ ហើយនិងកាំភ្លើងធំក៏ច្រើន ។ តែយើងខ្ញុំវាយបំបាក់វាភ្លាម ។ ខាងបូព៌ាវាចូលដីយើងខ្ញុំ៣០គីឡូម៉ែត្រ ។ ខាងផ្លូវលេខ៧ វាមកដល់ខាងជើងស្នួង ។ ឯនៅនិរតី វាចូលប្រហែល២៥គីឡូម៉ែត្រ លើផ្លូវលេខ២ ពីភ្នំដិនមកតាកែវ ។ យើងខ្ញុំទប់វាជាប់ ហើយយើងខ្ញុំកាត់វាជាកង់ៗឲ្យកម្លាំងទ័ពវាដាច់ជាច្រើនកំណាត់ ។ យើងខ្ញុំវាយកម្ទេចវាតាមចំណែកៗ ។ កន្លែងខ្លះយើងខ្ញុំវាយកម្ទេចវាជាអង្គភាពវរសេនាធំ ។ ដល់វាបាក់ជាចំណែកៗ វាទប់កម្លាំងយើងមិនបាន នាំឲ្យយើងខ្ញុំដេញវាទៅលើទឹកដីវានៅថ្ងៃទី៦ មករា ឆ្នាំ១៩៧៨ ក្នុងការប្រយុទ្ធពេលនោះ មានទីប្រឹក្សានិងអ្នកបច្ចេកទេសសូវៀតមកបញ្ជាកាំភ្លើងធំ និងរថក្រោះ ។ កងទ័ពយើងខ្ញុំវាយវាងាប់ពីរក្បាលនៅក្នុងរថក្រោះ ។ ដូច្នេះថ្ងៃទី៦ មករា ឆ្នាំ១៩៧៨ យើងខ្ញុំវាយឲ្យបរាជ័យយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់យួន វាយកម្ទាត់យុទ្ធសាស្ត្រប្រជាជនតែមួយ ប្រទេសតែមួយ បក្សតែមួយរបស់យួន ។ យើងខ្ញុំជ្រោងទង់ឯករាជ្យ អធិបតេយ្យ និងបូរណភាពដែនដីរបស់ខ្លួនបាន ។ ក្រោយមកទៀត ចាប់ពីខែកុម្ភៈរហូតមកដល់បច្ចុប្បន្ន វាវាយយើងខ្ញុំទៀត ។ ប៉ុន្តែកម្លាំងវាខ្ពស់បំផុតមិនដល់ពាក់កណ្តាល១៤កងពលដែលវាប្រើនៅចុងឆ្នាំ១៩៧៧ទេ ។ ហើយកម្លាំងដែលវាចាប់វាយយើងខ្ញុំតាំងពីខែកុម្ភៈមកត្រូវខ្ទេចខ្ទីច្រើន ។ ឥឡូវវាកំពុងមានការលំបាកច្រើនលើគ្រប់ផ្នែក ។ ខាងយោធាវាក៏មានការលំបាកច្រើន ។ កម្លាំងវាដែលវាយយើងខ្ញុំ ឥឡូវតាមព្រំដែនមានមិនដល់ពីរកងពល ។ មិនដល់ពីរកងពលនេះ ខ្ញុំនិយាយពីកម្លាំងប្រយុទ្ធ មិនមែននិយាយពីឈ្មោះកងពលទេ ។ ឈ្មោះកងពលវាច្រើន វាខ្វះសាច់ទ័ព បានជាវាប្រើកប៉ាល់ហោះ ។ សញ្ញាដែលវាប្រើកប៉ាល់ហោះ ជាសញ្ញាដែលវាចាញ់ខាងថ្មើរជើង ពីខែកក្កដាដល់ដើមខែកញ្ញានេះយើងខ្ញុំបាញ់ធ្លាក់កប៉ាល់ហោះប្រដេញទម្លាក់និងខទ្ទម្ភាគបក្រវាចំនួន៨គ្រឿង ។ ខាងកប៉ាល់ហោះវាមានលទ្ធភាពតិច ពីព្រោះយួនមិនមែនជាប្រទេសឧស្សាហកម្មទេ ។ យួនជាប្រទេសកសិកម្មខ្ទិនថយ ។ ដូច្នេះកម្លាំងកប៉ាល់ហោះមិនដើរនាទីជាយុទ្ធសាស្ត្រទេ ។ វាប្រើកប៉ាល់ហោះនាំឲ្យវារឹតតែលំបាកថែមទៀត ខាងនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ។ កងទ័ពយើងខ្ញុំធ្លាប់ទប់សង្គ្រាមអាកាស២០០យប់២០០ថ្ងៃរបស់ចក្រពត្តិអាមេរិក កប៉ាល់ហោះមិនបានមួយភាគពាន់នៃកប៉ាល់ហោះអាមេរិកដែលវាយយើងខ្ញុំពីឆ្នាំ១៩៧៣ទេ ។

**សំណួរទីពីរៈ** សព្វថ្ងៃនេះ ការវិវត្តថ្មីនៃសង្គ្រាមកម្ពុជា-វៀតណាម មានសភាពយ៉ាងដូចម្តេច តើសង្គ្រាមនេះ មានលទ្ធភាពបន្តទៅទៀតឬទេ?

**ចម្លើយៈ** ឥឡូវសភាពការណ៍យួនមានការប្រែប្រួលឆាប់រហ័ស ទាំងក្នុងប្រទេសវា ទាំងក្រៅប្រទេស តាំងពីវាឈ្លានពានកម្ពុជាមក ។ មុនវាឈ្លានពានកម្ពុជា គេមិនទាន់ស្គាល់មុខមាត់វាយ៉ាងម៉េចទេ ស្មានថាវាសង្គមនិយម ស្មានថាវាបដិវត្ត ។ ឥឡូវគេឃើញយួនឈ្លានពានកម្ពុជា ។ យួនមិនមែនបដិវត្តទេ យួនមិនមែនសង្គមនិយមទេ ។ យួនមិនមែនជាប្រទេសមិនចូលបក្សសម្ព័ន្ធទេ ។ យួនជាប្រទេសចូលបក្សសម្ព័ន្ធ ដោយវាចូលក្នុងបក្សសម្ព័ន្ធសេដ្ឋកិច្ចសូវៀត ចូលបក្សសម្ព័ន្ធនយោបាយជាមួយសូវៀត ។ វាបោះមូលដ្ឋានសឹកវានៅក្រៅប្រទេស ។ មុខមាត់របស់យួនប្រែប្រួលក្រឡាប់ចាក់ក្នុងរយៈជាង៨ខែដែលវាចាប់ឈ្លានពានកម្ពុជា ។ ក្រៅពីនេះវាមានការលំបាកខាងសេដ្ឋកិច្ច




ហិរញ្ញវត្ថុធ្ងន់ធ្ងរណាស់ ។ វាអត់បាយស៊ី ហើយវារឹតតែអត់ថែមទៀត ។ ខាងនយោបាយ វាជួបការលំបាកក្នុងប្រទេសវា ប្រជាជនវាតស៊ូនឹងវានៅច្រើនកន្លែង នៅក្នុងប្រទេសវា ។ ក្នុងសភាពលំបាកនេះ វាទៅរករឿងសាធារណរដ្ឋប្រជាមានិតចិនទៀត ។ វារឹតតែវ័ណ្ឌកទៀត ។ ដូច្នេះវាលំបាកទាំងក្នុងប្រទេស ទាំងក្រៅប្រទេស លំបាកទាំងខាងយោធា នយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ខ្វះបាយស៊ី ដូច្នោះដែលវាវាយកម្ពុជាមិនបាននោះ ឲ្យវាមានសភាពយ៉ាងនេះ ។ បើវាយកកម្ពុជាបានសភាពការណ៍ផ្សេង ហើយម៉្លេះវាក្រអើតក្រទម ព្រហើនកោងកាចយ៉ាងណាទៅទៀតទេ ។ តើវារុកទៅខាងត្បូងទៀតទេ ។ តើយួននិងសូវៀតគំរាមកំហែងវាតទីនៅអាស៊ី-អាគ្នេយ៍ឬទេ ។ បញ្ហានេះច្បាស់លាស់ណាស់ គឺវារុកទៅហើយ ហើយវាទៅជាអ្នកគំរាមកំហែងដូចតែពួកហ្វាស៊ីសពីដើមដែលវាអាងតែលើកម្លាំងបាយ ។ បើវាវាតទីយកអាស៊ី-អាគ្នេយ៍បាន តើសភាពការណ៍ប្រែប្រួលយ៉ាងណាទៅនៅលើសកលលោក ។ វាវាតទីខាងយោធា ទាំងជើងគោក ទាំងជើងទឹក កាន់កាប់ច្រកសមុទ្រម៉ាឡាកា ម្ចាស់លើភោគផលសេដ្ឋកិច្ចនៅអាស៊ី-អាគ្នេយ៍ ។ សភាពការណ៍ហ្នឹងស្មុគស្មាញយ៉ាងណា ។ តើវាវាតទីទៅកាន់កាប់អាស៊ី-អាគ្នេយ៍បានឬមិនបាន ។ បញ្ហានេះ ចោទថាបើមិនមានការប្រយុទ្ធជាមួយវា វាយកបាន ។ បើមានប្រយុទ្ធជាមួយវាឲ្យខ្លាំងក្លា វាយកមិនបានទេ ។ យើងខ្ញុំជឿជាក់ណាស់ថាប្រទេសនិងប្រជាជនអាស៊ី-អាគ្នេយ៍ ក៏ដូចប្រជាជនសកលលោកមិនឲ្យយួននិងវាតទីនិយមអន្តរជាតិដើរខបាយកលវាតទីលេបទឹកដីគេបានជាដាច់ខាត ។ តែខបមាបើខាងអាស៊ី-អាគ្នេយ៍ការពារមិនបានប្រទេសធំផ្សេងៗមកជួយអាស៊ី-អាគ្នេយ៍ តើសង្គ្រាមវាបើកទូលាយយ៉ាងណា ។ ខ្ញុំសុំជម្រាបថ្ងៃនេះ អស់លោកក៏ឃើញច្បាស់នូវតួនាទីកម្ពុជាប្រជាធិបតេយ្យទប់ទល់យួននិងវាតទីនិយមសូវៀត ដែលវៃកម្ពុជាគឺតួនាទីកម្ពុជាការពារខ្លួនផង និងតួនាទីទាក់ទងដល់សភាពការណ៍ទូទៅនៅអាស៊ី-អាគ្នេយ៍ផង ។ បើយ៉ាងនេះសកលលោកត្រូវការឲ្យកម្ពុជា ឯករាជ្យ អធិបតេយ្យ និងបូរណភាពដែនដីឬក៏ឲ្យកម្ពុជាទៅជាអាយ៉ងរបស់យួន ប្រជាមូលដ្ឋានគ្រប់យ៉ាងរបស់យួននិងសូវៀត ។ ចំពោះបញ្ហានេះ ប្រទេសនៅអាស៊ី-អាគ្នេយ៍ ប្រទេសជាច្រើនទៀតនៅអាស៊ី-អាគ្នេយ៍បានយល់ច្បាស់លាស់ ហើយកាន់តែយល់ថែមទៀត ។ ប្រទេសនៅលើសកលលោកកាន់តែច្រើនឡើងៗក៏យល់បញ្ហានេះ ។ ប៉ុន្តែក៏នៅមានប្រទេសខ្លះមិនទាន់យល់ ក្នុងហ្នឹងក៏មានប្រទេសធំៗដែលមានផលប្រយោជន៍ជាយុទ្ធសាស្ត្រតាមផ្លូវម៉ាឡាកា និងនៅអាស៊ី-អាគ្នេយ៍ ។ ដូច្នេះហើយបានជាគេមានអាកប្បកិរិយានយោបាយមិនទាន់ត្រឹមត្រូវជាមួយកម្ពុជាប្រជាធិបតេយ្យមិនឃើញតួនាទីរបស់កម្ពុជាប្រជាធិបតេយ្យដែលទប់ទល់នឹងការឈ្លានពានរបស់យួន និងរបស់វាតទីនិយមអន្តរជាតិ ប៉ុន្តែយើងខ្ញុំយល់ថា មុខនឹងគេយល់បណ្តើរៗតាមសភាពការណ៍វិវត្ត ។ អស់លោកចេះលេងអុកឈើត្រង់ យួនវាលេងក្រឡាពីរជាន់ ។ ដូច្នេះអ្នកលេងក្រឡាតែមួយជាន់មើលមិនឃើញក្រឡាទីពីររបស់វា ។ យួនវាដើរខបាយកលបំភ័ន្តមតិសកលលោកវៃប្រហារកម្ពុជាក៏ក្នុងយុទ្ធសាស្ត្រឈ្លានពានកម្ពុជា ហើយវៃកម្ពុជាក៏ក្នុងយុទ្ធសាស្ត្រ

ឈ្លានពានអាស៊ី-អាគ្នេយ៍ ។ បានជាយើងខ្ញុំជម្រាបថា បើយួននិងវាតទីនិយម អន្តរជាតិនិយមសូវៀតយកកម្ពុជាបាន តើសភាពការណ៍អាស៊ី-អាគ្នេយ៍ទៅជាយ៉ាងដូចម្តេច ។ យួនទៅធ្វើសកម្មភាពទូតទៅអាស៊ី-អាគ្នេយ៍ក៏ដើម្បីយុទ្ធសាស្ត្រនេះដែរ ។ វាស្តារសភាពការណ៍បរាជ័យរបស់វានៅសមរភូមិកម្ពុជា ដើម្បីពន្យារពេលដកឃ្លា ។ ម្យ៉ាងដើម្បីឯកោកម្ពុជា ម្យ៉ាងទៀតដើម្បីរៀបចំកម្លាំងរបស់វាវ៉ៃកម្ពុជាទៀត ។ ដល់វ៉ៃកម្ពុជារបើកទៅវាឈ្លានពានទៅអាស៊ី-អាគ្នេយ៍ទៀត ។ ប៉ុន្តែយើងខ្ញុំយល់ឃើញថា យួនធ្វើមិនបានទេ ។ យួននិងបក្សពួកយកកម្ពុជាមិនបានទេ ។ វាបន្តវ៉ៃយើងខ្ញុំទៀត ។ យើងខ្ញុំប្រកាសប្រាប់វាថា ត្រូវវាត្រៀមវ៉ៃមួយរយឆ្នាំ ហើយមួយរយឆ្នាំក៏យកកម្ពុជាមិនបានទៀត មានតែវាវិនាសហិនហោចទៅៗមិនចប់ ។ ខ្ញុំជម្រាបនេះមិនមែនតាមកំហឹងនិងជាគំនិតជាទទេទេ ។ យើងខ្ញុំសម្អាតលើកម្លាំងយើងខ្ញុំ ។ ទី១) យើងខ្ញុំមានបក្សកុម្មុយនិស្តកម្ពុជាដឹកនាំរឹងមាំ ។ ទី២) យើងខ្ញុំមានប្រជាជន ។ ប្រជាជននេះឯកភាពជាមួយបក្សពេញចិត្តនឹងរបបសមូហភាពដោយគេទទួលផលពីរបបនេះពិសេសប្រជាជនពលករដែលមានចំនួនជាង៩០ភាគរយ ហើយ១០ភាគរយទៀត គេស្រឡាញ់បដិវត្តន៍ គេចូលរួមបដិវត្តន៍ ហើយគេស្នេហាជាតិគេមិនត្រូវការឲ្យយួនមកលេបទឹកដីកម្ពុជាបានទេ ។ ទី៣) យើងខ្ញុំមានកងទ័ពបដិវត្តកម្ពុជាអង់អាចក្លាហាន ។ ទី៤) យើងខ្ញុំមានសេដ្ឋកិច្ចឧបត្ថម្ភស្បៀងដោយខ្លួនឯងបាន ហើយមានទាំងជួយយួនថែមទៀត ។ ដូច្នេះឥឡូវនេះយើងខ្ញុំរឹតតែមានលក្ខណៈសម្បត្តិផ្គត់ផ្គង់ខាងស្បៀងដោយខ្លួនឯងពេញទី ។ ទី៥) យើងខ្ញុំមានរបបសង្គមនិយមសមូហភាពស្អាតស្អំ និងកាន់តែមានមូលដ្ឋានរឹងមាំជាលំដាប់ ។ យួនវិញ បក្សវាមិនមែនជាបក្សម៉ាកឡេនីនត្រឹមត្រូវទេ ជាបក្សសេរីរើពេញទីក្បត់បដិវត្ត ។ របបវាមិនមែនជារបបសង្គមនិយមត្រឹមត្រូវ ជារបបសង្គមនិយមក្លែងក្លាយជិះជាន់ប្រជាជន ប្រជាជនក្រីក្រនៅតែទទួលការជិះជាន់ ។ រដ្ឋអំណាចវាទាំងនយោបាយ ទាំងសេដ្ឋកិច្ច ពុករលួយ ពាលាអាវ៉ាសែ សង្កត់សង្កិនកេងប្រវ័ញ្ចប្រជាជន ។ ដូច្នេះប្រជាជនមិនគាំទ្រ មានតែប្រឆាំងនឹងវា ។ កងទ័ពវាក៏ជាកងទ័ពក្លែងក្លាយ ពុករលួយ កេងប្រវ័ញ្ច សង្កត់សង្កិនប្រជាជន ប្រជាជនមិនឧបត្ថម្ភវាទេ ។ ដូច្នេះហើយ បានជាវាចាប់ទាហានបន្ថែមតាមសំណូមពររបស់វាមិនបាន ។ សេដ្ឋកិច្ចហិរញ្ញវត្ថុវាលំបាកមែនទែន ។ សភាពអត់ឃ្លានកាន់តែធ្ងន់ធ្ងរហើយ បើវានៅតែបន្តឈ្លានពានកម្ពុជាវាកាន់តែធ្ងន់ធ្ងរថែមឡើងតទៅទៀត ។ លើឆាកអន្តរជាតិ យួនបែកមុខជាអ្នកឈ្លានពានកម្ពុជា ជាអ្នកវាតទីជាកងទ័ពស៊ីឈ្នួលវាតទីនិយមសូវៀត ជាប្រទេសចូលបក្សសម្ព័ន្ធសូវៀត ។ ដូច្នេះវាកាន់តែបែកមុខ កាន់តែឯកោ ។ ប្រជាជនលើសកលលោក កាន់តែប្រទេចផ្តាសាវា ។ ប្រជាជនសកលលោកឃើញច្បាស់ថាៈ យួនឈ្លានពានកម្ពុជា ហើយកម្ពុជាការពារឯករាជ្យខ្លួនទប់ទល់យួនឈ្លានពាន ។ នេះហើយជាហេតុផលដែលយើងខ្ញុំមានជំនឿថា យើងខ្ញុំការពារឯករាជ្យ ។ យើងខ្ញុំក៏ទទួលការឧបត្ថម្ភ គាំទ្រនិងលើកទឹកចិត្តពីមិត្តភក្តិលើសកលលោកកាន់តែច្រើនទៀត ។

**សំណួរទី៣ៈ** ពេលថ្មីៗនេះ មានសារព័ត៌មានអន្តរជាតិបានធ្វើអត្ថាធិប្បាយចំពោះបញ្ហាខ្លះនៅកម្ពុជា ។ តើរដ្ឋាភិបាលកម្ពុជា



មានមតិយ៉ាងម៉េចចំពោះប្រការនេះ?

**ចម្លើយ:** មានការឃោសនាក្នុងសាកលលោករបស់ចក្រពត្តិ និងវាតទីនិយមអន្តរជាតិថា រដ្ឋកម្ពុជាប្រជាធិបតេយ្យត្រូវប្រជាជនប្រឆាំង ថានៅកម្ពុជាមានអសន្តិសុខពាសពេញ ថានៅកម្ពុជាគ្មានសិទ្ធិមនុស្ស ថាឥឡូវនេះ រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យនៅតែប៉ុន្មានទាក់ ។ អ្នកដែលមានវិចារណញ្ញាណបន្តិចបន្តួចក៏គេសន្និដ្ឋានត្រូវដែរ ។ ទីមួយ អ្នកប្រឆាំងបដិវត្តកម្ពុជានិងកម្ពុជាប្រជាធិបតេយ្យ គឺអ្នកណា គឺពួកចក្រពត្តិនិយមប្រតិកិរិយា និងវាតទីនិយមអន្តរជាតិ ដែលវាឃើញកម្ពុជាប្រជាធិតេយ្យ ឯករាជ្យ អធិបតេយ្យ ។ វាបាត់ផលប្រយោជន៍យោធា នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ជ្រៀតចូលកម្ពុជាប្រជាធិបតេយ្យលែងបាន វាតែងតែខឹងសម្បានិងប្រឆាំងកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំ ។ នេះជាការធម្មតា ។ ទីពីរ អស់លោកទៅធ្វើទស្សនកិច្ចច្រើនខេត្ត ឃើញមានអសន្តិសុខបះបោរទេ ។ អស់លោកជាសាក្សី ។ ទីបី អស់លោកមុខជាយល់ដូចយើងខ្ញុំដែរ បដិវត្តកម្ពុជាកន្លងមកបើគ្មានប្រជាជនកម្ពុជាចូលរួមមិនឈ្នះទេ គ្មាន១៧ មេសា ១៩៧៥ ទេ ។ ឯបដិវត្តកម្ពុជាបច្ចុប្បន្ន ការពារប្រទេស ដោះស្រាយស្បៀងដោយឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួន បើគ្មានប្រជាជនទាំងអស់ចូលរួមទេ យើងខ្ញុំការពារប្រទេសមិនបានទេ កសាងប្រទេសមិនបានទេ ដោះស្រាយស្បៀងខ្លួនឯងមិនបានទេ មុខជាអត់បាយដាច់ពោះដើរសុំទានគេពាសពេញហើយ ។ នេះបញ្ជាក់ច្បាស់ណាស់ថា ប្រជាជនកម្ពុជាធ្វើបដិវត្តន៍ហើយជាម្ចាស់លើកម្ពុជាប្រជាធិបតេយ្យ ។ កម្លាំងប្រជាជនយើងខ្ញុំមានដូចតទៅៈ ម្យ៉ាងប្រជាជនទាំងមូលនៅខាងបដិវត្ត ។ ម្យ៉ាងទៀត យើងខ្ញុំសុំចែកប្រជាជនជាពីរប្រភេទគឺ ប្រជាជន ពលករ មាន ៩០ ភាគរយ ពេញចិត្តនឹងរបបសមូហភាពដែលផ្តល់ជីវភាពរស់នៅរបស់គេ ប្រជាជន ពលករ ដែលពីដើមខ្វះហូប ដើរលក់ខ្លួន លក់កូនចៅប្រុសស្រី លក់ប្រពន្ធប្តី មានជីវភាពយ៉ាប់យ៉ឺន ។ ឥឡូវគេមានហូបគ្រប់គ្រាន់ គេការពាររបបនេះផ្ទាល់ ។ ឯប្រជាជនដប់ភាគរយ ប្រៀបធៀបជីវភាពគេពីមុនចុះបន្តិច ។ ប៉ុន្តែ គេមានហូប មានផ្ទះនៅ មានសម្លៀកបំពាក់ មានពេទ្យព្យាបាលដូចគេដូចឯង ។ ប្រជាជនទាំងមូលឃើញថា សង្គមនេះយុត្តិធម៌ដែលអ្នកណាក៏ចង់បានយូរមកហើយ ។ ហើយពីដើមគេចង់បានសិទ្ធិសេរីភាពក្នុងការរស់នៅ ។ ពីដើមគេក្នុងសៀវភៅឲ្យមានសិទ្ធិសេរីភាពប្រជាធិប-តេយ្យក្នុងការរស់នៅ ។ ការពិតមានតែសិទ្ធិខាងវណ្ណៈជិះជាន់មកជិះជាន់ខាងយោធា នយោបាយ សេដ្ឋកិច្ច សង្គមកិច្ច ខាងវប្បធម៌ ។ ឥឡូវ គេយល់ខាងសិទ្ធិប្រជាធិបតេយ្យនិងយុត្តិធម៌សង្គមច្បាស់ ដោយគេមានសិទ្ធិលើមធ្យោបាយ ផលិតកម្មធ្វើម្ចាស់លើដីស្រែចម្ការ គោក្របី លើរោងចក្រ ។ គេមានសិទ្ធិរៀនសូត្រទាំងអស់គ្នា មានសិទ្ធិចាត់ចែងវាសនាប្រទេសជាតិទាំងអស់គ្នា ។ ដូច្នេះ សិទ្ធិប្រជាធិតេយ្យនេះជាសិទ្ធិប្រជាធិបតេយ្យពិតប្រាកដ ។ នេះជាសភាពការណ៍កម្លាំងប្រជាជនយើងខ្ញុំ ។ ដូច្នេះ ខ្មាំងសត្រូវឃោសនាវាយប្រហារកម្ពុជាប្រជាធិបតេយ្យយើងខ្ញុំវាយល់សប្តិ ។ ការពិតកម្លាំងប្រជាជនកម្ពុជា នៅជាមួយបដិវត្តន៍កម្ពុជា ការពាររបបសមូហភាពរបស់ខ្លួន ។

# ពន្យល់ពាក្យខ្មែរក្រហម

- **សមភាព :** ភាវៈស្មើគ្នាគ្មាននរណាធំជាងនរណា ។
- **សត្តិភាព :** សេចក្តីសុខរៀបរយសាន្តត្រាណ ។
- **អន្តរាគមន៍ :** ការដែលចូលទៅជួយគ្នាគិតគូរ ។
- **មនុស្សធម៌ :** របៀបស្គាល់ខុសត្រូវតាមគន្លងធម៌ ។
- **យុទ្ធការ :** ការតស៊ូ ការប្រឆាំងនឹងអ្វីមួយ ។
- **មិត្តភាព :** សភាពរាប់អាន សេចក្តីមេត្រីភាពរាប់អាន ។
- **ភាតរភាព :** សភាពជាបងប្អូននឹងគ្នា ។
- **ប្រសិទ្ធភាព :** កម្លាំងដែលសម្រេចដូចចិត្ត ។
- **សមត្ថភាព :** ភាវៈដែលមានចំណេះគ្រប់គ្រាន់នឹងធ្វើទៅបានបរិបូរណ៍ ។
- **ថាមពល :** សភាពមានកម្លាំងរឹងប៉ឹង ។
- **ក្រុមព្រឹក្សា :** អ្នកទទួលភារៈទីជុំជំនុំគ្នា ។

**(ដកស្រង់ពីសៀវភៅកំណត់ហេតុ ប៊ុន ធឿន)**

# សំណាល់ដីអរសោចពីបារាំង

**ឯកសាររបបកម្ពុជាប្រជាធិបតេយ្យ ទូរលេខ ៦៦, ៩២០ ខ្មង់**

*យើងខ្ញុំសូមរាយការណ៍ជូនបង ពីការជួបអ្នកកាសែតស៊ុយអែតៈ កាលពីថ្ងៃ៧-៤-៧៨ មុន គេទៅទស្សនកិច្ចនៅយួន ១) គេនិយាយថា មុនទៅយួន គេសុំជួបនឹងទូតកម្ពុជា ដើម្បីដឹងពីសភាពការណ៍នៅកម្ពុជាបច្ចុប្បន្ន។ ពេលនោះយើងខ្ញុំសួរគេវិញថា ចំពោះសភាពការណ៍កម្ពុជាមានជាច្រើនខែមកហើយជាមួយយួន តើលោកយល់ឃើញយ៉ាងណា? គេឆ្លើយតបវិញថា គេជាអ្នកកាសែត គេនៅកណ្តាលសេចក្តីថ្លែងការណ៍របស់កម្ពុជានិងយួន គេចុះផ្សាយទាំងពីរ តែដោយឡែកពីការសរសេរ គេមានការយល់ស្របតាមយើងដែលថា យួនចង់យកកម្ពុជាធ្វើជាសមាជិកសហព័ន្ធឥណ្ឌូចិន គេថាគេក៏មិនព្រមធ្វើរណបអ្នកណាដែរ ។ ក្នុងបញ្ហានេះ គេធ្លាប់បានដឹងពីប្រវត្តិសាស្ត្រកន្លងទៅហើយ ដូចជាចរចានៅហ្សឺណែវ ឆ្នាំ១៩៥៤ និងចរចានៅប៉ារីស ឆ្នាំ១៩៥៣ គ្មានឃើញតំណាងកម្ពុជាចូលរួមទេ នេះគឺមកពីកម្ពុជានិងយួន ។ ២) យើងខ្ញុំក៏ផ្តើមនិយាយសកម្មភាពរបស់យួន ទាំងខាងនយោបាយ យោធា ចារកម្មមកលើកម្ពុជាក្រោមផ្លាកសហព័ន្ធឥណ្ឌូចិន ចាប់ពីឆ្នាំ១៩៧០ ដល់ថ្ងៃ១៧មេសា ឆ្នាំ១៩៧៥ និងចាប់ពីក្រោយ ១៧មេសា ឆ្នាំ១៩៧៥ មកដល់សព្វថ្ងៃ។ តែគ្រប់សកម្មភាពរបស់វាត្រូវបរាជ័យ ។ ពិសេសបរាជ័យខាងយោធា កាលពីថ្ងៃ៦-១-៧៨ តែវានៅតែរៀបចំកម្លាំងយោធាវាយធំជាលើកទី២ទៀតមកលើកម្ពុជាក្នុងខែ៤នេះ ។ ទន្ទឹមនឹងនេះ ពួកវាបានឃោសនាបំភាន់មតិអន្តរជាតិឲ្យច្របូកច្របល់ក្នុងបញ្ហានេះ ។ យើងខ្ញុំបាននិយាយពីការរីកចំរើនខាងសេដ្ឋកិច្ច ពិសេសកសិកម្ម និងជូនឯកសារឲ្យគេមួយចំនួនផង ។ គេនិយាយថា គេបានយល់ពីសភាពការណ៍នេះហើយ គេអាចនឹងជំរាបគណៈប្រតិភូគេដឹកនាំដោយរដ្ឋមន្ត្រីការបរទេសដែលមកទស្សនកិច្ចនៅយួនជ្រាបពីសភាពការណ៍នេះ ។ ទីចុងបំផុតគេសួរយើងខ្ញុំថា÷ ១) តើយើងចង់យកដីកូសាំងស៊ីនមកវិញទេ? យើងខ្ញុំឆ្លើយតបវិញថា បញ្ហានេះជាបញ្ហាចាស់ រដ្ឋាភិបាលកម្ពុជាមិនសើរើរឿងចាស់ទេ ។ យើងខ្ញុំខិតខំការពារតែព្រំដែននេះឲ្យគង់វង្សដែលជាសំណល់ដីអសោចពីជំនាន់ អាណានិគមនិយមទុកឲ្យ ។ គេថា គេយល់ហើយរឿងកម្ពុជានិងយួនជាប់មានក្នុងប្រវត្តិសាស្ត្រយូរយារមកហើយ គេនឹងចុះផ្សាយនូវការពិតនេះឲ្យប្រជាជនស៊ុយអែតដឹង ។ ដោយភាតរភាពបដិវត្តយ៉ាងកក់ក្តៅបំផុត ។*

*ថ្ងៃ១២.៤.៧៨, ម៉ោង៩, រដ្ឋ, ទទួលថ្ងៃ១៣.៤.៧៨*

*ចម្លងជូនៈ អ៊ំ អ៊ំនួន បងវ៉ាន់ បងវន មន្ទីរ ឯកសារ*



គង់ សាបាន



អ៊ឹម ប៉ារិស



ចាប សារឿន

# មាគ៌ានយោបាយជាយុទ្ធសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ

***សំណួមពរ***

*១) ក្តាប់ឲ្យជាប់នូវមាគ៌ាយុទ្ធសាស្ត្រថ្មីនៃបដិវត្តន៍សង្គមនិយម ការកសាងសង្គមនិយម ។ ក្តាប់ក្នុងន័យអនុវត្តមិនមែនក្តាប់ដោយចាំមាត់នោះទេ ។ ២) ក្តាប់ឲ្យជាប់នូវភារកិច្ចនយោបាយនៃការកសាងកម្លាំងគ្រប់ផ្នែកដើម្បីអនុវត្តមាគ៌ាយុទ្ធសាស្ត្រមួយចំនួនឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព ។*

***ជំពូកទី១៖*** *ភារកិច្ចនយោបាយជាយុទ្ធសាស្ត្រថ្មីនៃបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យ ។ ១) បន្តធ្វើបដិវត្តសង្គមនិយម ដោយបន្តវាយសំណល់របបវណ្ណៈនាយទុន របបឯកជននិងកម្មសិទ្ធផ្ទាល់ខ្លួនទាំងអស់ឲ្យកាន់តែខ្លាំងក្លា កាន់តែជ្រាលជ្រៅជាប់ជានិច្ចរហូតនិងបានជាស្ថាពរលើគ្រប់ផ្នែកទាំងអស់និងគ្រប់ប្រភេទទាំងអស់នៅកម្ពុជាប្រជាធិបតេយ្យ ។*

*បដិវត្តន៍សង្គមនិយមធ្វើឡើងខាងសតិអារម្មណ៍ ចាត់តាំង សេដ្ឋកិច្ច សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ និងធ្វើឡើងក្នុងបក្សអង្គការស្នូលកងទ័ពបដិវត្តន៍ក្នុងជួរបដិវត្តយើងទាំងអស់ ក្នុងសមាជិកកម្មករ ក្នុងសហករណ៍កសិករ ក្នុងមន្ទីរក្រសួង និងក្នុងសង្គមជាតិទាំងមូល ។ ២) ពង្រឹងពង្រីករបបសមូហភាពនៃវណ្ណៈអធនលើគ្រប់ផ្នែក សតិអារម្មណ៍ ចាត់តាំង សេដ្ឋកិច្ចវប្បធម៌ សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រឲ្យបានខ្លាំងក្លា ជ្រាលជ្រៅជាប់ជានិច្ចឲ្យបានជាស្ថាពរ ។ ឈរលើទីតាំងសមូហភាពនៃវណ្ណៈអធននេះ ដំណើរការកសាងសង្គមនិយម ជំរុញនិងបំផុសការកសាងសង្គមនិយមខាងសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច បច្ចេកទេសវិទ្យាសាស្ត្រឲ្យខ្លាំងក្លាឆាប់រហ័ស មានគុណភាពខ្ពស់ ដោយជំហរឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនជាសំខាន់បំផុត ។ ការកសាងសង្គមនិយមធ្វើឡើងនៅក្នុងអង្គការស្នូល និងកងទ័ពបដិវត្តន៍ ក្នុងជួរបដិវត្តយើងទាំងសមាជិកកម្មករ សហករណ៍ កសិករ មន្ទីរ ក្រសួង ក្រុងនិងសង្គមជាតិទាំងមូល ។*

***ជំពូកទី២៖*** *ភារកិច្ចនយោបាយតាមផ្នែកផ្សេងៗ ដើម្បីអនុវត្តភារកិច្ចយុទ្ធសាស្ត្រនៃបដិវត្តសង្គមនិយមនៅកម្ពុជាប្រជា-ធិបតេយ្យ ។*

*ក) ការកសាងពង្រឹងពង្រីកបក្សគ្រប់ផ្នែកនយោបាយ សតិអារម្មណ៍ចាត់តាំង÷*

*ដើម្បីបំពេញភារកិច្ចដឹកនាំអនុវត្តមាគ៌ានយោបាយជាយុទ្ធសាស្ត្រនៃបដិវត្តន៍សង្គមនិយមនិងកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យគឺ៖*

*នយោបាយ៖ ត្រូវបំពាក់បំប៉ននូវសភាពការណ៍សង្គមកម្ពុជាថ្មីឲ្យច្បាស់និងជ្រៅជ្រះ ភារកិច្ចជាមាគ៌ានយោបាយយុទ្ធសាស្ត្រថ្មីនៃបដិវត្តសង្គមនិយមនិងការកសាងសង្គមនិយមនៅកម្ពុជា ក្តាប់ភារកិច្ចនយោបាយតាមផ្នែកការងារផ្សេងៗឲ្យរឹងប៉ឹង ក្តាប់គោលជំហរជាមូលដ្ឋាន ដើម្បីអនុវត្តមាគ៌ាយុទ្ធសាស្ត្ររឹងប៉ឹង ក្តាប់គោលនយោបាយផ្សេងៗ ដែលផ្នែកលើកឡើងជាបន្តបន្ទាប់ជាយុទ្ធវិធីនិងមាគ៌ាដំណើរការ ដើម្បីអនុវត្តមាគ៌ាយុទ្ធសាស្ត្រឲ្យបានរឹងប៉ឹង ព្រមជាមួយនេះតាមដានចលនាក្នុងនិងក្រៅប្រទេស ដើម្បីវិភាគសភាពការណ៍ឲ្យច្បាស់ ហើយមានវិធានការឲ្យច្បាស់ក្នុងរយៈកាលនីមួយៗ ដើម្បីពិនិត្យតម្រែតម្រង់ ឬកែលម្អនូវយុទ្ធវិធី មាគ៌ាដំណើរការ ឬមាគ៌ាយុទ្ធសាស្ត្រទៀតផង ។*

*សតិអារម្មណ៍៖ សតិអារម្មណ៍ទីមួយដែលត្រូវកសាងជាបន្តបន្ទាប់គឺសតិអារម្មណ៍ស្នេហាជាតិនិយម បដិវត្តនិងអន្តរជាតិនិយមបដិវត្តន៍ដោយឈរលើស្នេហាជាតិនិយមជាមូលដ្ឋាន ។ សតិអារម្មណ៍ទីពីរគឺ គោលជំហរវណ្ណៈអធននិងគោលជំហរវណ្ណៈកម្មករ ។ សតិអារម្មណ៍ទីបី គឺទស្សនៈម៉ាក្សឡេនីន ជាមូលដ្ឋានខ្ទះពិសេសសម្ភារនិយម បដិច្ចសមុប្បាទនិងសម្ភារនិយមប្រវត្តិ-សាស្ត្រ ។*

*ចាត់តាំង៖ បញ្ហាទី១ ក្នុងបញ្ហាចាត់តាំងគឺប្រជាជាតិប្រជាធិបតេយ្យប្រមូលផ្តុំ បញ្ហាទី២ គឺផ្អែកមាគ៌ាវណ្ណៈកម្មកររបស់បក្ស ។*

*ខ) ការកសាងពង្រឹងពង្រីកប្រជាជន កម្មករ កសិករ÷*

អង្គការសហជីពកម្មករៈ ពង្រឹងឲ្យជាប់នូវសហជីពកម្មករទាំងកម្មករថ្មី ទាំងកសិករចាស់ពង្រឹងឲ្យជាប់អង្គការសហករណ៍ទាំងកសិករចាស់-ថ្មី តាមជំហរនិងតាមទិសដៅបដិវត្តសង្គមនិយមនិងកសាងសង្គមនិយម ដើម្បីឲ្យកម្លាំងកម្មករកសិករទាំងអស់ពង្រឹងពង្រីកខ្លួនតាមជំហរសមូហភាពជំហរវណ្ណៈអធន ទើបគេជាកម្លាំងខ្លាំងក្លាអនុវត្តនិងសម្រេចបដិវត្តន៍សង្គមនិយមបានល្អឆាប់រហ័ស ។ ត្រូវយកចិត្តទុកដាក់បំពាក់បំប៉ន កម្មករ កសិករនូវនយោបាយសតិអារម្មណ៍និងចាត់តាំងដូចខ្លឹមសារកសាងបក្សដែរ ។

*ឃ) ការកសាងពង្រឹងពង្រីករដ្ឋអំណាចបដិវត្តនិងផ្តាច់ការបដិវត្តវណ្ណៈអធនរបស់បក្ស÷*

តើពង្រឹងពង្រីករដ្ឋអំណាចរបស់បដិវត្តរបស់បក្សដើម្បីអ្វី? ដើម្បីបដិវត្តន៍សង្គមនិយម និងការកសាងសង្គមនិយមនៅកម្ពុជាបច្ចុប្បន្ន ។ ដូច្នេះមិនបម្រើបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ឬបម្រើវណ្ណៈដទៃទេ ។

ធាតុពិតនៃរដ្ឋអំណាចនិងផ្តាច់ការបដិវត្តក្នុងរយៈកាលបដិវត្តថ្មីនិងតាមមាគ៌ាយុទ្ធសាស្ត្រថ្មីត្រូវមានធាតុពិតវណ្ណៈអធន មានជំហរវណ្ណៈអធន មានជំហរសមូហភាព មានជំហរសង្គមនិយម ។ ពង្រឹងពង្រីកកម្លាំងអំណាចបដិវត្តរបស់បក្សគឺតាមខ្លឹមសារនយោបាយសតិអារម្មណ៍ចាត់តាំង ដូចខ្លឹមសារដែលត្រូវបំពាក់បំប៉ននៅក្នុងបក្សដែរ ។

ត្រូវយកចិត្តទុកដាក់សម្រាលការចាត់តាំងរដ្ឋអំណាចបដិវត្តថ្នាក់ ឲ្យបានជាអតិបរិមា ដើម្បីសម្រាលតំណាងស្រទាប់លើ ។

*ង) ការកសាងពង្រឹងពង្រីកកម្លាំងយោធាបដិវត្តរបស់បក្សហើយនិងកិច្ចការពារប្រទេសរបស់បក្ស÷*

ខ្លឹមសារទី១) កងទ័ពបដិវត្តរបស់បក្សមានភារកិច្ច ការពារអនុវត្តនូវបដិវត្តសង្គមនិយមនិងកសាងសង្គមនិយមរបស់បក្ស ។

ខ្លឹមសារទី២) ធាតុពិតនៃកងទ័ពរបស់បក្សបច្ចុប្បន្ននេះគឺធាតុពិតសង្គមនិយមសមូហភាពតាមជំហរវណ្ណៈអធនរបស់បក្ស ។

ខ្លឹមសារទី៣) ត្រូវបំពាក់បំប៉នជាប់ជានិច្ចឲ្យកងទ័ពបដិវត្តរបស់បក្សជ្រួតជ្រាបជាប់ជានិច្ចនូវនយោបាយរបស់បក្សសតិ-អារម្មណ៍របស់បក្សដូចខ្លឹមសារបំពាក់បំប៉នឲ្យបក្សដែរ ។

ខ្លឹមសារទី៤) ត្រូវយកចិត្តទុកដាក់ពង្រឹងពង្រីកកងទ័ពបដិវត្តរបស់បក្ស កងទ័ពស្រួច កងតំបន់ កងឈ្លប ព្រមទាំងជើងគោកជើងទឹកជើងអាកាសឲ្យមានសភាពខ្លាំងក្លានិងទាន់សម័យឡើង ដើម្បីជាលក្ខណៈសម្បត្តិគ្រប់គ្រាន់ការពារប្រទេសកម្ពុជាប្រជាធិបតេយ្យការពារបដិវត្តសង្គមនិយមនិងកសាងសង្គមនិយមដោយឈរលើមាគ៌ាយោធារបស់បក្សនិងមាគ៌ាសង្គ្រាមប្រជាជនរបស់បក្ស ។

ខ្លឹមសារទី៥) កិច្ចការពារប្រទេសរបស់បក្សយើងត្រូវផ្អែកលើកម្លាំងប្រជាជនទាំងមូល ។

ខ្លឹមសារទី៦) ត្រូវមានប្រជាជនតាមមូលដ្ឋានដែលមានប្រជាជនតិចគ្មានប្រជាជន ត្រូវបណ្តុះប្រជាជនឲ្យទៅនៅកន្លែងដែលទំនេរ ដែលគ្មានប្រជាជនឲ្យគេទៅកសាងភូមិឋានរបស់គេជាបណ្តើរៗ ។

*ច) ការកសាងពង្រឹងពង្រីកកម្លាំងកសាងប្រទេសគ្រប់ផ្នែកសេដ្ឋកិច្ច វប្បធម៌ សង្គមកិច្ច បច្ចេកទេស វិទ្យាសាស្ត្រ÷*

ខ្លឹមសារទី១) កម្លាំងកសាងប្រទេសគ្រប់ផ្នែកនេះ ដើម្បីបម្រើបដិវត្តសង្គមនិយមនិងកសាងសង្គមនិយម ឈរលើគោលជំហរវណ្ណៈអធននិងកម្មសិទ្ធសមូហភាពរបស់បក្ស ។

ខ្លឹមសារទី២) ឈរលើមូលដ្ឋានបដិវត្តសង្គមនិយមសមូហភាព វណ្ណៈអធនរបស់បក្សត្រូវជំរុញនិងបំផុសមហាចលនាកសាងប្រទេសគ្រប់ផ្នែកឲ្យលោតផ្លោះខ្លាំងក្លាតាមសំណូមពរកសិកម្មអន់ថយទៅជាកសិកម្មសម័យរវាង១០ឆ្នាំទៅ១៥ឆ្នាំ ពីប្រទេសកសិកម្មទៅប្រទេសឧស្សាហកម្មរវាង១៥ឆ្នាំ ទៅ២០ឆ្នាំមានវប្បធម៌ សង្គមកិច្ច រីកលូតលាស់ មានបច្ចេកទេស វិទ្យាសាស្ត្រលូតលាស់ទាំងអស់ដើម្បីជីវភាពប្រជាជនខាងសម្ភារនិងខាងផ្នែកផ្សេងៗទៀតសម្បូណ៌គ្រប់គ្រាន់ជាមូលដ្ឋាន ដើម្បីប្រជាជនមានសុភមង្គលពិតប្រាកដគ្រប់ផ្នែកទាំងអស់ក្នុងសង្គមជាតិទាំងមូលរុងរឿងសម្បូណ៌សប្បាយ ។

ខ្លឹមសារទី៣) ក្នុងកិច្ចដំណើរការកសាងប្រទេសគ្រប់ផ្នែកត្រូវមានផែនការនិងកម្មវិធីច្បាស់លាស់ដែលមានទំនាក់ទំនងគ្នារវាងផ្នែកមួយទៅផ្នែកមួយរវាងទូទាំងប្រទេសនិងមូលដ្ឋានរវាងភូមិភាគនិងតំបន់ ស្រុក សង្កាត់ ។ល ។

*ឆ) ការកសាងពង្រឹងពង្រីកកម្លាំងមិត្តលើសកលលោក÷*

ខ្លឹមសារទី១) យកចិត្តទុកដាក់ពង្រឹងពង្រីកកម្លាំងមិត្តលើសកលលោក ម្យ៉ាងផងណ្ដើមកម្លាំងបដិវត្តន៍និងកត្តាស្នេហាជាតិ ស្នេហាយុត្តិធម៌ដែលដណ្ដើមបានលើសកលលោកជួយខបត្ថម្ភគាំទ្រដល់បដិវត្តយើង ហើយម្យ៉ាងទៀតសាមគ្គីជាមួយកម្លាំងបដិវត្តន៍និងកម្លាំងស្នេហាជាតិ យុត្តិធម៌ក្នុងសកលលោកប្រឆាំងចក្រពត្តិអាណានិគមនិយមចាស់ថ្មី ។

ខ្លឹមសារទី២) យកចិត្តទុកដាក់សំខាន់ កម្លាំងបដិវត្តអាស៊ី-អាគ្នេយ៍ ទន្ទឹមនឹងនេះក៏យកចិត្តទុកកម្លាំងចម្រើននៅក្នុងប្រទេសមិនចូលបក្សសម្ព័ន្ធនិងលោកទី៣ ហើយបន្ទាប់មកយកចិត្តទុកដាក់កម្លាំងស្នេហាសន្តិភាពនិងយុត្តិធម៌នៅក្នុងសកលលោក ។

ខ្លឹមសារទី៣) យកចិត្តទុកដាក់សាមគ្គីជាមួយបក្សម៉ាក្សឡេនីនត្រឹមត្រូវនៅលើសកលលោក ពិសេសបក្សដែលមិនទំនាស់ជាមួយយើង ហើយជួយខបត្ថម្ភគ្នាទៅវិញទៅមកប្រជាជនបក្ស ។

ខ្លឹមសារទី៤) ព្រមជាមួយនេះ ក៏ត្រូវយកចិត្តទុកដាក់ដែរចំពោះប្រទេសបដិវត្តមិនទាន់កាន់អំណាចដើម្បីបន្តលក្ខណៈសម្បត្តិមានផលប្រយោជន៍ដល់បដិវត្តយើង ។

ខ្លឹមសារទី៥) គោលជំហរជាមូលដ្ឋាននៃការប្រមូលកម្លាំងរបស់យើងនៅលើសកលលោក គឺការខំប្រឹងពង្រឹងពង្រីកអត្តនោម័តិរបស់យើងជាមូលដ្ឋាននិងជាសំខាន់បំផុត ។ បើអត្តនោម័តិរបស់យើងល្អហើយកាន់តែល្អ យើងមានលក្ខណៈសម្បត្តិវាយសម្រុកក្នុងការងារប្រមូលកម្លាំងមិត្តបានច្រើន ។

ជ) ការកសាងពង្រឹងពង្រីកមូលដ្ឋានបផ្អែកបដិវត្ត៖

ក្នុងឋានៈជាម្ចាស់ប្រទេសទាំងមូល គ្រប់គ្រងរដ្ឋអំណាចទាំងមូល យើងត្រូវកសាងគ្រប់ច្រកល្ហកព្រៃភ្នំវាលរាបទីប្រជុំជនទាំងអស់នៅក្នុងប្រទេសយើងជាមូលដ្ឋានបផ្អែកបដិវត្តរឹងប៉ឹងធានាអះអាងដល់កិច្ចការពារប្រទេសគ្រប់កាលៈទេសៈក្នុងឋានៈវាយសម្រុកនិងម្ចាស់ការ ។ ដូច្នេះត្រូវមានកម្លាំងបក្សរឹង មានកម្លាំងប្រជាជនរឹង កម្លាំងយោធារឹង កម្លាំងរដ្ឋអំណាចរឹង កម្លាំងសេដ្ឋកិច្ចនិងគ្រប់ផ្នែកនិងគ្រប់មូលដ្ឋានទាំងអស់ ។

ឈ) ការទប់ទល់សង្គ្រាមចារកម្មស៊ីរូងបំផ្លិចបំផ្លាញរបស់ខ្មាំងសត្រូវពីគ្រប់ទិសទី ដើម្បីការពារបក្សបដិវត្តប្រជាជនកងទ័ពកម្ពុជាប្រជាធិបតេយ្យ៖

ត្រូវមានទស្សនៈគោលជំហរនិងវិធានការទប់ទល់ទៅកម្ចាត់ក្នុងជម្នះវាយសម្រុកនូវសង្គ្រាមចារកម្មរបស់ខ្មាំងកុំឲ្យវាលូកដៃមកដាច់ខាត ។ ដូច្នេះ បក្សត្រូវរឹងប៉ឹងនិងស្អាត ប្រជាជនរឹងនិងស្អាត កងទ័ពរឹង យោធារឹងនិងស្អាត រដ្ឋអំណាចរឹងនិងស្អាតជួរទាំងមូលរឹងនិងស្អាត ។

៣) មាគ៌ាការពារបក្សនិងអង្គការដឹកនាំរបស់បក្ស៖

ត្រូវយកចិត្តទុកដាក់ការពារបក្សនិងអង្គការដឹកនាំរបស់បក្សឲ្យបានដាច់ខាតដើម្បីធានាអះអាងដល់ការដឹកនាំបដិវត្ត ។ ដូច្នេះត្រូវមានទស្សនៈប្រុងប្រយ័ត្នបដិវត្តជាប់មានវិធានការចាត់តាំងហ្មត់ចត់ ពិសេសរក្សាការសម្ងាត់មូលដ្ឋានតែសំខាន់បំផុតគឺបក្សទាំងមូលរឹងនិងស្អាត កងទ័ពទាំងមូលរឹងនិងស្អាត ជួរយើងទាំងមូលរឹងនិងស្អាត ប្រជាជនទាំងមូលរឹងនិងស្អាត ។

**ជំពូកទី៣៖** គោលជំហរជាមូលដ្ឋានមួយចំនួនដើម្បីអនុវត្តមាគ៌ាជាយុទ្ធសាស្ត្រនៃបដិវត្តសង្គមនិយមនិងការកសាងសង្គមនិយមរបស់បក្ស ។ ១) ឯករាជ្យម្ចាស់ការខ្លួនទីពឹងខ្លួនកាន់កាប់វាសនាបដិវត្តខ្លួនរឹងមាំជានិច្ច ។ ២) បន្តការតស៊ូវណ្ណៈជ្រាលជ្រៅតទៅទៀតជាប់ជានិច្ចនិងដាច់ខាត ។ ៣) បន្តជំរុញមហាចលនាសមូហភាពភាវូបនីយកម្មគ្រប់ផ្នែកទាំងអស់នៅក្នុងបក្សទាំងមូលកងទ័ពទាំងមូល ប្រជាជនទាំងមូល ។ ៤) ក្នុងការវាយសម្រុកការងារត្រូវយកចិត្តទុកដាក់ជំហរតស៊ូយូរអង្វែងឆ្លងកាត់លំបាកវេទនា ដណ្ដើមជ័យជម្នះរហូតដល់ជ័យជម្នះទាំងស្រុងនិងស្ថាពរ ។ ៥) មាគ៌ាសកម្មភាពនិងមាគ៌ាដំណើរការផ្សេងៗ ត្រូវឈរលើការបំផុសបំផុលមហាចលនាបដិវត្តរបស់ប្រជាជនជាប់នឹងមហាចលនាដាក់ស្នែងរបស់ប្រជាជនរៀនសូត្រដកពិសោធន៍ឲ្យរស់រវើកនិងច្នៃប្រឌិតពីក្នុងមហាចលនាបដិវត្តរបស់ប្រជាជន ។ ៦) យកចិត្តទុកដាក់ខាងនយោបាយសតិអារម្មណ៍បដិវត្តជាមូលដ្ឋានសំខាន់បំផុតព្រមជាមួយនោះត្រូវយកចិត្តទុកដាក់ជាអតិបរមាក្នុងបច្ចេកទេស ។ ៧) លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់ ដើម្បីបង្ក្រាបសង្គ្រាមឈ្លានពាន ការពារបូរណភាពដែនដី ការពារបក្ស ការពារបដិវត្តសង្គមនិយម និងកសាងសង្គមនិយមនៅកម្ពុជាប្រជាធិបតេយ្យ ការពារប្រជាជននិងកងទ័ព ។

***(សៀវភៅកំណត់ហេតុលេខ D២១៦៤៧)***

# បញ្ជីឈ្មោះជនរងគ្រោះជនបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ៣១៨ | យិន ហៀង | យួន | ប្រជាជន | កំពង់សោម | ២៨-៤-៧៨ | ២៧-៥-៧៨ |
| ៣១៩ | វិន មិនចូវ | យួន | ប្រជាជន | កំពង់សោម | ២០-៣-៧៨ | ២៧-៥-៧៨ |
| ៣២០ | ង្វៀង យ៉ាំងអាន | យួន | បីញញឹក | តំបន់៥០៥ | ២៥-៤-៧៨ | ២៧-៥-៧៨ |
| ៣២១ | យ៉ យ៉ាំងអឹក | យួន | ប្រជាជន | ស្វាយរៀង | ?-?-៧៨ | ២៧-៥-៧៨ |
| ៣២២ | វុ អ៊ុស៊ីក | យួន | ហាស៊ី | និរតី | ៩-៤-៧៨ | ២៧-៥-៧៨ |
| ៣២៣ | ង្វៀង យ៉ាំងបុ | យួន | ដុងវ៉ុយ | តាកែវ | ២៦-២-៧៨ | ២៧-៥-៧៨ |
| ៣២៤ | ង្វៀង យ៉ាំងហាយ | យួន | ចិនវ៉ុយ | កំពង់សោម | ១២-៤-៧៨ | ២៧-៥-៧៨ |
| ៣២៥ | ត្រឹង យ៉ាំងហាយ | យួន | ដុងវ៉ុយ | ស្វាយរៀង | ៨-១-៧៨ | ២៧-៥-៧៨ |
| ៣២៦ | ត្រឹង ង៉ុកតាយ | យួន | ប្រជាជន | ស្វាយរៀង | ៣១-១-៧៨ | ២៧-៥-៧៨ |
| ៣២៧ | ង្វៀង កុង | យួន | ប្រជាជន | កំពង់សោម | ១៦-៥-៧៨ | ២៧-៥-៧៨ |
| ៣២៨ | តូ យ៉ាំងធូ | យួន | ដុងវ៉ុយ | កំពត | ៤-២-៧៨ | ២៧-៥-៧៨ |
| ៣២៩ | ចូវ យ៉ាំងឌឹក | យួន | ដីវវ៉ុយ | ស្វាយរៀង | ៤-៣-៧៨ | ២៧-៥-៧៨ |
| ៣៣០ | វិន យ៉ាំងថឺ | យួន | បីញញឹ | ស្វាយរៀង | ៦-៥-៧៨ | ២៧-៥-៧៨ |
| ៣៣១ | ង្វៀង យ៉ាំងប៉ែ | យួន | ដីវវ៉ុយ | កំពង់សោម | ១១-២-៧៨ | ២៧-៥-៧៨ |
| ៣៣២ | ដឿន ក្វាង | យួន | ប្រជាជន | កំពង់សោម | ១១-៥-៧៨ | ២៧-៥-៧៨ |
| ៣៣៣ | លឿង កុងវ៉ាយ | យួន | ដុងវ៉ុយ | កំពង់សោម | ១៩៧៨ | ២៧-៥-៧៨ |
| ៣៣៤ | ឡេង ឌឹកថូ | យួន | បីញញឹក | កំពង់សោម | ១៩៧៨ | ២៧-៥-៧៨ |
| ៣៣៥ | ដាង កេង | យួន | ប្រជាជន | កំពង់សោម | ១៩៧៨ | ២៧-៥-៧៨ |
| ៣៣៦ | វិន យ៉ាំងហ្វា | យួន | កូន អាថឺ | ស្វាយរៀង | ១៩៧៨ | ២៧-៥-៧៨ |
| ៣៣៧ | វឿង ង៉ុកស៊ុន | យួន | បីញញឹក | កំពត | ១៩៧៨ | ២៧-៥-៧៨ |
| ៣៣៨ | លឿង វ៉ុកបាវ | យួន | ប្រជាជន | ? | ២២-១-៧៨ | ២៧-៥-៧៨ |
| ៣៣៩ | ង្វៀង យ៉ាំងហាយ | យួន | ប្រជាជន | កំពត | ១៩៧៨ | ២៧-៥-៧៨ |
| ៣៤០ | ដាម ធីខឺន(ស) | យួន | លក់បន្លែ | កំពង់សោម | ១២-៥-៧៨ | ១៤-៥-៧៨ |
| ៣៤១ | ង្វៀង ធីហុង | យួន | លក់បន្លែ | កំពង់សោម | ១២-៥-៧៨ | ១៤-៥-៧៨ |
| ៣៤២ | វិន ធីង៉ុក | យួន | កូនវិន យ៉ាំងថាយ | ស្វាយរៀង | ៦-៥-៧៨ | ១៤-៥-៧៨ |
| ៣៤៣ | ដាន វ៉ាន់ធៀង | យួន | ពលទោឆ្កាយ២ | ស្វាយរៀង | ១៣-២-៧៨ | ២៧-៣-៧៨ |
| ៣៤៤ | ង្វៀង វ៉ានមឿយ | យួន | ពលទោឆ្កាយ១ | ស្វាយរៀង | ?-១-៧៨ | ២៧-៣-៧៨ |

(នៅមានត)

# របាយការណ៍របស់ អៀង សារី ថ្លែងចំពោះមុខ សមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា

អៀង សារី បានធ្វើរបាយការណ៍មួយនៅចំពោះមុខសមាជិកការិយាល័យនយោបាយនៃរណសិរ្សរួបរួមជាតិកម្ពុជា ដើម្បីបញ្ជាក់ពីស្ថានភាពចិត្តគំនិតរបស់ «បណ្តាសមមិត្ត»គាត់ដែលកំពុងប្រយុទ្ធតស៊ូនៅខាងក្នុងប្រទេស ។ សម្តេច សីហនុ បានមានព្រះបន្ទូលក្នុងការសន្ទនាមួយប្រាប់លោក ហ្សង់ ឡាគូទៀ *(Jean Lacouture)* ថា អៀង សារី ជាសាស្ត្រាចារ្យដែលធ្វើសកម្មភាពនយោបាយលួចលាក់តាំងពីឆ្នាំ១៩៦៣ ។ អៀង សារី ទើបនឹងធ្វើដំណើរមកជួបខ្ញុំនៅទីក្រុងប៉េកាំង បន្ទាប់ពីការធ្វើដំណើរដោយថ្មើរជើងអស់រយៈពេលជាច្រើនខែតាមបណ្តោយផ្លូវលំហូជីមិញ ។ ខាងក្រោមនេះជាសេចក្តីរាយការណ៍របស់ អៀង សារី÷

«យើងទាំងអស់គ្នាចូលព្រៃ ពុំមែនដើម្បីបំផ្លាញដោយឧបាយសម្ងាត់នូវនយោបាយសន្តិភាព ឯករាជ្យភាព និងអព្យាក្រឹតភាព ប្រឆាំងនឹងចក្រពត្តិនិយមរបស់សម្តេចសីហនុទេ ប៉ុន្តែគឺដើម្បីគេចខ្លួនពីការរួមគំនិតក្បត់របស់ លន់ ណុល, សិរិមតៈ និង សឺង ង៉ុកថាញ់ ដែលគាំទ្រដោយសេ.អ៊ី.អា ។ គោលដៅរបស់ក្រុមនេះគឺកម្ចាត់អ្នកនិយមឆ្វេងបំផុតតាមគ្រប់មធ្យោបាយទាំងអស់ រួមទាំងលួចធ្វើឃាតផង ។ ការចូលព្រៃរបស់យើងគឺជាបញ្ហាស្លាប់ឬរស់មួយសម្រាប់ពួកយើង ។

«នៅពេលដែលព្រះអង្គកាន់អំណាច សម្តេច សីហនុ បានផ្តល់ឲ្យយើងនូវភ័ព្វសំណាងរួចផុតពីគ្រោះថ្នាក់មួយ យើងមានមធ្យោបាយធ្វើឲ្យសំឡេងរបស់យើងត្រូវគេស្តាប់នៅរដ្ឋសភាជាតិ ហើយជួនកាលនៅក្នុងផ្ទៃរដ្ឋាភិបាលដែរ ដែលមានពួកយើងជាច្រើនចូលរួមក្នុងនោះ ។ នៅឆ្នាំ១៩៦៦ អ៊ីៗទាំងអស់បាន



ផ្លាស់ប្តូរ ។ “បេក្ខភាពសេរី” (ការដាក់ពាក្យសុំឈរឈ្មោះជាអ្នកតំណាងរាស្ត្រ) ដល់ពេលដែលត្រូវវង់ចំពុះទុង លន់ ណុល និង រហស្សបាយ (ល្បិចសម្ងាត់) របស់សេ.អ៊ី.អា ជាមួយការឲ្យដៃរបស់សភានិយមស្តាំបំផុតហើយ ។ នៅពេលនោះ ពួកគេបានបង្កនូវសង្គ្រាមស៊ីវិលពិតប្រាកដមួយប្រឆាំងនឹងយើងភ្លាមៈ គេតម្រូវឲ្យយើងឆ្លើយតបនឹងកាំភ្លើងរបស់គេដោយកាំភ្លើងរបស់យើង ។

យើងមិនចង់ធ្វើឲ្យមានការប្រឈមមុខដែលប្រើកម្លាំងកំហែងកំហល់របៀបនេះទេ ។ រហូតដល់ក្នុងព្រៃ យើងនៅតែគាំទ្រនយោបាយឯករាជ្យភាព អព្យាក្រឹតភាព និងសាមគ្គីភាពជាមួយរណសិរ្សរំដោះជាតិ (វៀតកុង) និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមរបស់សម្តេច សីហនុ ដដែល ។ នៅសមាជជាតិចុងក្រោយ គឺសមាជជាតិនៅខែធ្នូ ឆ្នាំ១៩៦៩ អ្នកនាំពាក្យរបស់យើងបានទំប្រឹងធ្វើជាវបាំងការពារនយោបាយថ្មីមួយដែលជារបស់ក្រុម លន់ ណុល និងផ្តួលរំលំរដ្ឋាភិបាលប្រតិកិរិយា ។ សមាជជាតិបានគាំទ្រការលើកឡើងនេះ ប៉ុន្តែសម្តេច(សីហនុ) ពុំបានឆ្លៀតទាញប្រយោជន៍ពីជ័យជម្នះនេះដើម្បីកម្ចាត់រដ្ឋាភិបាល លន់ ណុល, សិរិមតៈ និងតម្រង់ប្រទេសជាថ្មីឆ្ពោះទៅរកកលទ្ធិសង្គមនិយម ហើយប្រឆាំងលទ្ធិចក្រពត្តិនិយមឡើយ ។ ផ្ទុយទៅវិញ សម្តេចសព្វព្រះទ័យយាងទៅប្រទេសបារាំងដើម្បីព្យាបាលរោគក្នុងមន្ទីរពេទ្យនៅទីនោះជាង ។

“នៅសម័យដែលរដ្ឋាភិបាលនិយមសីហនុ កាន់កាប់អំណាច សង្គ្រាមស៊ីវិល ត្រូវបានទប់ឲ្យស្ថិតនៅក្នុងកម្រិតទាបបំផុតមួយ ។ ដោយឆ្លៀតឱកាសនៃអវត្តមានរបស់ព្រះប្រមុខរដ្ឋ សិរិមតៈបានកំណត់ពីលក្ខណៈនិងប្រពលភាពនៃសង្គ្រាមនេះ តាមរយៈការបង្ក្រាបយ៉ាងសាហាវឃោរឃៅនិងជាទូទៅ ។ ភូមិទាំងឡាយដែលសង្ស័យថាចូលដៃចូលជើងជាមួយយើង ត្រូវបានដុតកម្ទេច ហើយជាញឹកញាប់ពួកអ្នកភូមិត្រូវសម្លាប់ចោល ។

“ជាធម្មតា នៅថ្ងៃបន្ទាប់ពីរដ្ឋប្រហារ១៨ មីនា លន់ ណុល និង សិរិមតៈ បានល្បងធ្វើប្រតិបត្តិការប្រជាភិថុតិមួយ ដោយចោទប្រកាន់សម្តេច សីហនុ ថា ជាអ្នកទទួលខុសត្រូវធំបំផុតក្នុងការប្រយុទ្ធប្រឆាំងនឹងពួកខ្មែរក្រហម ។ ពួកគេអះអាងថាពួកគេប្រុងប្រៀបខ្លួនជាស្រេចដើម្បីជានឹងគ្នាវិញ ទទួលស្វាគមន៍យើងនៅភ្នំពេញ និងបែងចែកអំណាចជាមួយយើងដោយរលាស់ចោលសីហនុ ។ ប៉ុន្តែប្រជាជននិងពួកយើងផ្ទាល់ដឹងនូវអ្វីដែលយើងត្រូវប្រកាន់យកក្នុងរឿងនេះ យើងមិនធ្លាក់ទៅក្នុងអន្ទាក់សាមញ្ញមួយបែបនេះទេ ។ តាំងពីក្រោយថ្ងៃរដ្ឋប្រហាររបស់ លន់ ណុល យើងបានចូលរួមជាមួយបាតុកម្មរបស់ប្រជាជននៅតាមខេត្តជាច្រើនដើម្បីទាមទារការវិលត្រឡប់របស់សម្តេច និង ការសុំលាលែងរបស់រដ្ឋាភិបាលដែលកើតពីរដ្ឋប្រហារ ។

“នៅថ្ងៃទី២៣ ខែមីនា យើងបានស្តាប់សេចក្តីអំពាវនាវចំពោះប្រជាជាតិរបស់សម្តេច សីហនុ ដែលផ្សាយតាមវិទ្យុប៉េកាំង ក្នុងទម្រង់ជាសេចក្តីថ្លែងការណ៍មួយមាន៥ចំណុច ។ យើងបាននិយាយឲ្យដឹងនូវការគាំទ្រភ្លាមថា យើងយល់ព្រមចំពោះកម្មវិធីនេះ និងការរួបរួមរបស់យើងជាមួយរណសិរ្សរួបរួមជាតិកម្ពុជា (ត្រង់នេះសម្តេច សីហនុ បានធ្វើកំណត់សម្គាល់ថា “លិខិតគាំទ្ររបស់ជនជាតិខ្មែរដែលជាអ្នកតស៊ូក្នុងព្រៃបានមកដល់ក្រុងប៉េកាំងនៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៧០”) ។

“ក្នុងអំឡុងបណ្តាថ្ងៃចុងក្រោយនៃខែមីនា ឆ្នាំ១៩៧០ ប្រសិនបើយើងមានគ្រឿងសព្វាវុធច្រើននិងទំនើបៗសម្រាប់ប្រើប្រាស់នោះ រដ្ឋាភិបាល លន់ ណុល នឹងដួលរលំយ៉ាងឆាប់រហ័ស មុនពេលដែលអាចហៅរកការធ្វើអន្តរាគមន៍របស់ពួកអាមេរិកាំងនិងពួកបាវបម្រើនៅក្រុងព្រៃនគរទៅទៀត ។

“ប៉ុន្តែតទៅទៀត យើងអាចពង្រីកដោយឆាប់រហ័សនូវកងទ័ពប្រជាជនរបស់យើង ដែលមានការរៀបចំនិងការហ្វឹកហ្វឺនតាំងពីឆ្នាំ១៩៦៦-១៩៦៧ម៉្លេះ ដោយសារនយោបាយបង្ក្រាបរបស់ លន់ ណុល និង សិរិមតៈ ។ ប្រជាជនភូមិនានាបានចាត់អ្នកខ្លះក្នុងចំណោមគ្នាយើងឲ្យឈរឈ្មោះជាអ្នកតំណាងរាស្ត្រចូលរដ្ឋសភាជាតិនៅឆ្នាំ១៩៦៦ (ទោះបីជាសភាជាតិនេះជារបស់ពួកប្រតិកិរិយាក៏ដោយ)...។ យើងពុំបាន“ញុះញង់”ប្រឆាំងនឹងនយោបាយអ្នកនិយម សីហនុ ទេ ប៉ុន្តែការស្រុះស្រួលគ្នារបស់យើងជាមួយព្រះអង្គគ្មានអ្វីក្រៅពីពង្រឹងខ្លួនឲ្យរឹតតែរឹងមាំឡើង និងចូលរួមប្រយុទ្ធប្រឆាំងនឹងការឈ្លានពានរបស់បរទេសឡើយ ។ “ទំនាក់ទំនងរបស់យើងជាមួយកងទ័ពប្រជាជនវៀតណាមដែល

ប្រយុទ្ធដើម្បីធ្វើការរំដោះឥណ្ឌូចិនត្រូវបានកត់សម្គាល់ដោយការបារម្ភពីឯករាជ្យភាពទាំងស្រុងរបស់យើងនិងអំពីផែនការទាំងអស់នៅចំពោះមុខបងប្អូនយុទ្ធជនរបស់យើង ។ យើងជាម្ចាស់ប្រទេសកម្ពុជាពុំមែនពួកគេទេ ។ យើងជាសម្ព័ន្ធមិត្ត ប៉ុន្តែមិនមែនសម្ព័ន្ធមិត្តរបៀប "អ្នកតូច"ត្រូវចំណុះ "អ្នកធំ"ទេ ។ យើងគិតជាសំខាន់ក្នុងការបង្ការភាពថ្លៃថ្នូរ ភាពស្មើមុខគ្នា និងលក្ខណៈជាខ្មែរ ។ យើងជាជនជាតិកម្ពុជាដែលតស៊ូក្នុងព្រៃសុខចិត្តយល់ព្រមចំពោះគោលការណ៍សំខាន់ថ្មីស្មើអាយុជីវិតទាំងនោះ ។

"គុណសម្បត្តិនៃអ្នកប្រយុទ្ធរបស់យើង? ឥឡូវនេះយើងជឿថា ពួកគេពិតជាប្រមូលបាននូវបទពិសោធន៍ ។ វាពិតហើយថា ពួកយើងពុំមាននិងនៅតែពុំមានពេលវេលាច្រើនដើម្បីចំណាយពេលវេលារៀនសូត្រខាងទ្រឹស្តីឡើយ ។ ប៉ុន្តែបទពិសោធន៍ដែលទទួលបាននៅលើសមរភូមិក្នុងការវាយប្រយុទ្ធទល់នឹងសត្រូវមិនមែនជាបទពិសោធន៍ដែលឥតប្រៀបផ្ទឹមបានទេឬ? នៅដើមដំបូងនៃសង្គ្រាម លន់ ណុល អាចប្រមូលយុវជននិងចាប់យុវជនយ៉ាងច្រើនឲ្យធ្វើទាហាន ដើម្បីធ្វើជា "ចំណីគ្រាប់កាណុង"របស់បក្រពត្តិនិយមអាមេរិក ដោយជញ្ជូនផលប្រយោជន៍ពីមនោ-សញ្ចេតនារបស់អ្នកជាតិនិយមខ្មែរម្នាក់ដែលប្រឆាំងនឹងវៀតណាម ។ ប៉ុន្តែ មូលហេតុពីរបានធ្វើឲ្យនិន្នាការនេះប្រែក្រឡាប់÷

ក) ការកាន់កាប់ប្រទេសរបស់យើងដោយកងទ័ពរបស់ ធីវ (ប្រធានាធិបតីវៀតណាមខាងត្បូង) អមទៅដោយការឆក់ប្លន់ទ្រព្យសម្បត្តិប្រជាជននិងការប្រព្រឹត្តអំពើឃោរឃៅគ្រប់បែបយ៉ាង ។

ខ) ការលេចឡើងនូវកងទ័ពប្រជាជនខ្មែរ ពុំមែនរបស់វៀតណាមដែលបានបង្ហាញឲ្យប្រជាជនយើងឃើញប៉ែកខាងណាជាអ្នកស្នេហាជាតិ មាតុភូមិ ដែលកំពុងធ្វើការប្រយុទ្ធ ។

"ពិតហើយ កងអាកាសចរណ៍របស់សត្រូវគឺជាការចាញ់ប្រៀបដ៏ធ្ងន់ធ្ងរមួយសម្រាប់យើង ។ យុទ្ធជនរបស់យើងសុទ្ធតែមានវ័យក្មេង ពួកមនុស្សចាស់ពុំអាចបង្ហាញនូវការពូកែអត់ធន់នឹងលក្ខណៈសង្គ្រាមនេះទេ ហើយក៏ពុំមានប្រតិកម្មរហ័សក្នុងការប្រយុទ្ធមួយដែលមានលក្ខណៈពុះកញ្ជ្រោលនិងដែលធ្វើឲ្យទាល់គំនិតនេះដែរ ។ ពួកគេត្រូវប្រឈមមុខទល់នឹងយន្តហោះទម្លាក់គ្រាប់បែក នាវាចម្បាំង ខ្ទម្ពាគចក្រយ៉ាងច្រើនដោយគ្រាន់តែឮសូរសំឡេងធ្វើឲ្យពួកគេព្រឺខ្លាចទៅហើយ ។ ឥឡូវនេះការវាយប្រហារគ្នាបានប្រព្រឹត្តទៅយ៉ាងខ្លាំងក្លានៅជុំវិញទីក្រុងភ្នំពេញដែលការពារដោយកងទ័ពរបស់ លន់ ណុល ចំនួន៥៩កងវរសេនាតូច ។ ប្រសិនបើពួកអ្នកប្រយុទ្ធពុំមែនជាខ្មែរ តើប្រជាជនរួមសហការជាមួយយើងដែរឬទេ? ហេតុអ្វីបានជាពួកគេរក្សាការសម្ងាត់ស្តីអំពីការឆ្មក់វាយប្រហារទម្លាក់គ្រាប់បែកមកលើយើង?

"ចំពោះឯកភាពនយោបាយយោធារបស់រណសិរ្សរួបរួមជាតិកម្ពុជាយើងទាំងក្នុងនិងក្រៅប្រទេស ឥឡូវនេះត្រូវបានធ្វើឲ្យប្រាកដហើយ ។ រណសិរ្សរួបរួមជាតិកម្ពុជាគឺមានតែមួយពុំមានពីរទេ ។ ការបែងចែកទាំងអស់រវាង"ក្រហម"និង"មិនមែនក្រហម" នឹងរលាយបាត់ដើម្បីអនាគត និងឯករាជ្យភាពនៅប្រទេសកម្ពុជា រួមទាំងដើម្បីអព្យាក្រឹតភាពរបស់ខ្លួនផង ។

"យុទ្ធសាស្ត្ររបស់យើងគឺមានតែមួយគត់ និងមិនអាចប៉ះពាល់បាន៖ ក) យើងទាំងអស់គ្នាប្រឆាំងនឹងការសម្រុះសម្រួល ការដោះស្រាយនយោបាយទាំងអស់ដែលនឹងដាក់ឲ្យមានការពិភាក្សាជាថ្មី នូវកាតព្វកិច្ចទាំងឡាយដែលជាគ្រឹះទាក់ទងទៅនឹងភាពពេញច្បាប់នៃរណសិរ្សរួបរួមជាតិកម្ពុជា និងការប្រឆាំងបក្រពត្តិនិយម ។ ខ) ទោះបីជារយៈពេលនៃការប្រយុទ្ធយូរអង្វែង និងឧបសគ្គនានាដែលយើងទាំងអស់គ្នានឹងពើបប្រទះក៏ដោយក៏យើងអាចនឹងធ្វើការតស៊ូដោយអាវុធរហូតដល់ការធ្វើឲ្យសម្រេចដោយពិតប្រាកដនូវគោលដៅទាំងឡាយរបស់យើងដែរ" ។

"ដោយពុំអាចឈ្នះយើងតាមកម្លាំងទ័ព សត្រូវបានសាកល្បងបង្អត់អាហារយើងដោយរោយមេស្វាដែលមានជាតិពុលបណ្តាលឲ្យប៉ះពាល់ដំណាំនិងធ្វើឲ្យខូចដីស្រែចម្ការយើងយ៉ាងធ្ងន់ធ្ងរ ។ ប៉ុន្តែយើងចេះរបៀបបន្តរស់នៅទៀតដោយដាំដំណាំនិងដាំឡើងវិញជាដរាប... ។

"កងទ័ពប្រជាជនរបស់យើងជាអ្វី? កងទ័ពរំដោះជាតិរបស់យើងរួមមានអង្គភាពចំណានលើសគេមួយមានមនុស្ស ១២.០០០នាក់ ដែលទទួលប្រាក់បំណាច់៣០រៀលក្នុងមួយខែ

សម្រាប់សោហ៊ុយចាយវាយប្រចាំថ្ងៃរបស់ពួកគេ, កងទ័ពតំបន់ដែលមានចំនួន១៥.០០០នាក់ (គ្មានប្រាក់បៀវត្សរ៍) និងកងឈ្លបភូមិដែលគេអាចវាយតម្លៃថាមានប្រហែល១០០.០០០នាក់ ហើយដែលគ្មានប្រាក់បៀវត្សរ៍ដែរ ។

"អំណាចបញ្ជាការរបស់គេ គឺឯករាជ្យទាំងស្រុងពីអំណាចបញ្ជាការរបស់ពួកវៀតណាម ដែលទទួលរ៉ាប់រងដោយផ្ទាល់ដោយ ខៀវ សំផន ជារដ្ឋមន្ត្រីការពារជាតិនិងឧបនាយករដ្ឋមន្ត្រី ។ ចំពោះរឿងនេះ យើងត្រូវធ្វើឲ្យលាយបាត់បង់នូវការមួលបង្កាច់មិនសមទំនងដែលផ្សព្វផ្សាយដោយពួកមេដឹកនាំក្រុងភ្នំពេញបច្ចុប្បន្ន និងបណ្តាក្នាក់ងាររបស់វានៅបរទេសៈ ខៀវ សំផន, ហ៊ូ យន់, ហ៊ូ នឹម និងបណ្តាមេដឹកនាំអ្នកតស៊ូនិងសមាជិករណសិរ្សរួបរួមជាតិកម្ពុជាដទៃទៀត នៅមានជីវិតរស់នៅដោយពិតប្រាកដ ។ អ្នកទាំងបីពុំត្រូវបានប្រហារជីវិតក្រោយរបបមុនទេៈ ខ្ញុំធ្លាប់បានជួបពួកគេ ខ្ញុំធ្លាប់ធ្វើការជាមួយអ្នកទាំងនោះ ខ្ញុំបានធ្វើឲ្យបណ្តាមិត្តភក្តិរបស់ពួកគេ ប្រជាជនកម្ពុជា និងបណ្តាសម្ព័ន្ធមិត្តរបស់យើង បាត់ភ័យព្រួយ និងធ្វើឲ្យសត្រូវទាំងឡាយផ្អើលឆ្ងល់...។

"សម្រាប់យើង ករណីយកិច្ចដ៏ធំជាមួយនឹងជ័យជម្នះ និងការទម្លាក់របបអាយ៉ង គឺការរំដោះប្រជាកសិករ ដោយការបំបាត់សក្តិភូមិនិយម និងការយកការប្រាក់ហួសហេតុដែលបង្ហិនទ្រព្យសម្បត្តិប្រជាកសិករនៅតាមជនបទ ។ សម្រាប់រឿងនេះ គេត្រូវតែដាក់ដាលំដាប់លំដោយនូវអំណាចប្រជាជនមួយជំនួសរដ្ឋបាលក្រុងភ្នំពេញ ។ ស្របជាមួយគ្នានោះ យើងត្រូវបន្តធ្វើតទៅទៀត ខាងវិស័យអប់រំជាតិ រៀបចំកងទ័ពប្រជាជន បង្កើតសាលារៀន ឬវិទ្យាល័យបើឱកាសហុចឲ្យ...។

"រដ្ឋបាលរបស់យើងគ្មានទីស្នាក់ការណាក្រៅពីវាលស្រែនិងព្រៃព្រឹក្សាឡើយ ថ្វីដ្បិតតែវាមានភាពខុសប្លែកគ្នាពីបងប្អូនវៀតណាមរបស់យើង តែយើងបានរំដោះទីក្រុងខ្លះៗរួចមកហើយ ដូចជាក្រចេះជាដើម ។ ទាំងអ្នកគ្រប់គ្រងខាងរដ្ឋបាលរបស់យើង ទាំងកម្មាភិបាលទ័ពរបស់យើងពុំមានពាក់សញ្ញាសម្គាល់ឋានន្តរស័ក្តិឬបុ៉ានស័ក្តិឡើយ ។ ប្រជាជននិងយុទ្ធជនរឹតតែគោរពពួកគេ ហើយពេញចិត្តនឹងការគោរពដោយភាពស្មើមុខគ្នានេះ ។

"ហេតុអ្វីបានជាប្រជាជនគាំទ្រយើង បើទុកជាគាត់រងទុក្ខវេទនាដោយសារតែការប្រយុទ្ធក៏ដោយ? គឺដោយសារ÷

◆ ការស្អប់ខ្ពើមពួកអាមេរិកាំង ការចូលលុកលុយ ការវាយប្រហារបណ្តាលឲ្យស្លាប់មនុស្សយ៉ាងច្រើនពីសំណាក់កងអាកាសចរណ៍របស់ពួកវា ។

◆ ការស្អប់ខ្ពើមបាវបម្រើនិងសម្ព័ន្ធមិត្តវៀតណាមខាងត្បូងរបស់សហរដ្ឋអាមេរិក ដែលការប្រព្រឹត្តអំពើឃោរឃៅរបស់គេធ្វើឲ្យព្រឺខ្លាចយ៉ាងខ្លាំង ។

◆ ការស្អប់ខ្ពើមអំពើពុករលួយ ពួកអ្នករកស៊ីចងការប្រាក់ដែលយកការប្រាក់ហួសប្រមាណពួកនាម៉ឺនមន្ត្រី ពួកអ្នករកស៊ីកេងប្រវ័ញ្ចនិងអ្នកសមគំនិតទាំងអស់នៃរបបថ្មី ។

◆ ស្មារតីភក្តីចំពោះសម្តេច សីហនុ ដែលពាក្យមួលបង្កាច់ផ្សេងៗដែលផ្សព្វផ្សាយដោយក្រុងភ្នំពេញ ពុំបានប៉ះពាល់ដល់ព្រះកិត្តិនាមព្រះអង្គឡើយក្នុងក្រសែភ្នែកប្រជាជននៅតាមស្រុកស្រែចម្ការនានា ។

"យើងបានបន្ថយពន្ធចំនួន៥០ភាគរយ បើប្រៀបធៀបនឹងសម័យមុនថ្ងៃ១៨ មីនា ឆ្នាំ១៩៧០ ដោយឲ្យរួចពន្ធទាំងស្រុងនូវផលិតផលខ្លះៗ ជាពិសេសមានប្រយោជន៍ចំពោះបុព្វហេតុរបស់យើង ហើយយើងបានរៀបចំឲ្យដំណើរការនូវសហករណ៍ជាច្រើនដែលការចាត់ចែងមានលក្ខណៈផាយដឹកនាំបំផុត ។ នេះជារូបមន្តដែលមិននាំទៅរកការបង្ខិតបង្ខំណាមួយឡើយ គឺណែនាំជាធម្មតាតាមគំនិតឲ្យប្រជាកសិករជួយគ្នាទៅវិញទៅមក (ធ្វើជាក្រុមប្រវាស់ដៃ) ។

"ចុះចំណែកព្រះសង្ឃ? ការគាំទ្ររបស់ព្រះអង្គចំពោះបុព្វហេតុជាតិ គឺគ្មានអ្វីគួរឲ្យសង្ស័យឡើយ ។ ថ្មីៗនេះមហាសន្និបាតបានប្រមូលផ្តុំព្រះសង្ឃមួយចំនួនធំក្នុងចំណោមព្រះសង្ឃទាំងអស់ និងបានសម្តែងឲ្យឃើញនូវការព្រមព្រៀងរវាងបណ្តាសមាជិកជាសង្ឃនិងប្រជាជន ថ្វីបើមានការប៉ុនប៉ងទាក់ទាញចិត្តយ៉ាងច្រើនរបស់រដ្ឋអំណាច និងការឃោសនាដ៏ខ្លាំងក្លាមួយដែលមានគោលបំណងបង្ហាញថា កងទ័ពប្រជាជនជាសត្រូវនឹងសាសនាក៏ដោយ ។

"ខ្មាំងសត្រូវបានបង្កើនរឹតតែខ្លាំងនូវការប៉ុនប៉ងផ្សេងៗ

ដើម្បីបំបែកបំបាក់រណសិរ្សរួបរួមជាតិកម្ពុជាៈ វាសាកល្បងទិញទឹកចិត្តមនុស្សជាច្រើនដោយប្រើលុយដុល្លារ ដោយផ្តល់តំណែងដែលរកកម្រៃក្រៅបានច្រើន ឬរួមគ្នាកាន់អំណាច ។ វាពុំបានទទួលការចុះចូលណាមួយដែលគួរឲ្យកត់សម្គាល់ឡើយៈ ពួកអ្នកដែលបែកបក្សពួកបាននាំគ្នាមកចូលខាងយើង ។ "សេចក្តីស្រើបចិត្ត"ប្រឆាំងវៀតមិញ នៅពេលដំបូងបានប្រែក្លាយទៅជាការស្រងាកចិត្តយ៉ាងឆាប់រហ័ស ហើយការប្រឹងប្រែងក្នុងការជ្រើសរើសកងទ័ព "សាធារណរដ្ឋ"របស់ លន់ ណុល ប្រែទៅជាល្បែងបិទពួនដោយផ្នែក១...។ ដោយហេតុថា សាររបស់សម្តេច សីហនុ ជាប្រមុខស្របច្បាប់ដែលផ្សាយតាមវិទ្យុប៉េកាំង ហើយដែលអាចស្តាប់ឮយ៉ាងច្បាស់នៅប្រទេសកម្ពុជា បានបណ្តាលឲ្យមានឥទ្ធិពលមួយយ៉ាងសម្បើមលើមតិសាធារណៈ ។

"ដំណោះស្រាយដែលក្រុមអ្នកតស៊ូក្នុងព្រៃយល់ឃើញពុំមែនជារបស់ "ពួកខ្មែរក្រហម" "ពួកអ្នកនិយមសីហនុ" ទេ ប៉ុន្តែជារបស់ "ខ្មែររណសិរ្សរួបរួមជាតិកម្ពុជា" ត្រូវតែមានលក្ខណៈជារបស់កម្ពុជាយ៉ាងដោយឡែក ។ ប៉ុន្តែ ដំណោះស្រាយដែលអាចថ្លែងក្នុងនាមនៃប្រទេសវៀតណាមឬប្រទេសឡាវពុំមែនសុទ្ធតែល្អសម្រាប់ប្រទេសកម្ពុជាទេ ។ ក្រុមអ្នកតស៊ូនៅខាងក្នុងប្រទេសបានច្រានចោលដាច់អហង្ការនូវរូបមន្តស្តីអំពីក្រុមអ្នកតំណាងដែលគ្រាន់តែតំណាងឲ្យភាពមិនស្របច្បាប់ការដាក់ខ្លួនក្រោមបង្គាប់បរទេសនិងចក្រពត្តិនិយមប៉ុណ្ណោះ ។ បុព្វហេតុរបស់យើងជាបុព្វហេតុនៃភាពពេញច្បាប់ក្នុងរយៈពេលនិងក្រោយការតស៊ូដោយអាវុធ ។ ប្រមុខរដ្ឋមួយអង្គគត់ដែលយើងទទួលស្គាល់គឺ សម្តេចព្រះ នរោត្តម សីហនុ ដែលតែងតែការពារឯករាជ្យភាពជានិច្ច និងដែលទទួលបានជាថ្មីនូវស្វាមីភក្តិរបស់យើងដោយព្រះអង្គផ្សាយឲ្យដឹងកម្មវិធីមួយមាន៥ចំណុចនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៧០ ហើយដែលក្លាយទៅជាគោលការណ៍គ្រឹះរបស់យើង ។

"ម្យ៉ាងទៀត ទោះជាក្នុងតំបន់នានាដែលសន្មតថាគ្រប់គ្រងដោយសត្រូវក៏ដោយ ក៏យើងមិនដែលឮអ្នកណាប្រកែកពីភាពស្របច្បាប់របស់សម្តេចព្រះប្រមុខរដ្ឋថាមិនពិតដែរ" ។

***ដកស្រង់ចេញពីសៀវភៅ L'INDOCHINE VUE DE PEKIN របស់លោក JEAN LACOUTURE ។ ប្រែសម្រួលក្រៅផ្លូវការដោយ ទេព មេងឃាន ។***



# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | ផ្សេងៗ |
|---|---|---|---|---|---|---|
| ៦៨៥ | អើ អ៊ែល | កាប៉ូរ៉ាល់ | កំពង់ស្ពឺ | ២៨-៦-៧៦* | ១៧-៦-៧៦ | |
| ៦៨៦ | ទៀង កូប | កាប៉ូរ៉ាល់សេហ្ | កំពង់ស្ពឺ | ២៨-៦-៧៦* | ១៧-៦-៧៦ | |
| ៦៨៧ | ជីន វ៉ែន | អធិការហិរញ្ញវត្ថុ | បាត់ដំបង | ១១-១-៧៦ | ១៧-៦-៧៦ | |
| ៦៨៨ | ពិន ជុន | កម្មករ | រោងចក្រកង់ឡាន | ១៨-២-៧៦ | ១៧-៦-៧៦ | |
| ៦៨៩ | បក អុន | កម្មករ | ក្រឡឹង ដ-៦ | ២-២-៧៦ | ១៧-៦-៧៦ | |
| ៦៩០ | ហឹង ចុង | កម្មករ | សុរាគារ | ២៧-១២-៧៥ | ១៩-៦-៧៦ | ឈឺស្លាប់ |
| ៦៩១ | ស៊ុន ស្រ៊ុម | ទាហានពលទោ | តំបន់២៥ | ១៦-៣-៧៦ | ២៤-៦-៧៦ | ឈឺស្លាប់ |
| ៦៩២ | ព្រែក លាង | ប្រជាជន | តំបន់២៥ | ១២-៣-៧៦ | ២៤-៦-៧៦ | ឈឺស្លាប់ |
| ៦៩៣ | យឹម ឌឹម | យុទ្ធជន | តំបន់២៥ | ២៩-៩-៧៥ | ២៥-៦-៧៦ | ឈឺស្លាប់ |
| ៦៩៤ | ប៊ុន ហុក | យុទ្ធជន | កំពង់ស្ពឺ | ២៧-៦-៧៦ | ២៧-៦-៧៦ | ឈឺស្លាប់ |
| ៦៩៥ | ជុំ ឌៀប | យុទ្ធជន | តំបន់២៥ | ២៩-១១-៧៥ | ២៧-៦-៧៦ | ឈឺស្លាប់ |
| ៦៩៦ | គង់ អឿន | យុទ្ធជន | កងពល១៦៤ | ៧-៥-៧៦ | ២៨-៦-៧៦ | ឈឺស្លាប់ |
| ៦៩៧ | ចាន់ តឹម | កងហា | តំបន់៣៣ | ២៣-៣-៧៦ | ២៩-៦-៧៦ | ឈឺស្លាប់ |
| ៦៩៨ | ទូច សារិន | កងហា | តាខ្មៅ | ១៩-៦-៧៦ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៦៩៩ | ង៉ែត ញ៉ាន់ | អនុកងហា | ពោធិចិនតុង | ២៧-៣-៧៦ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៧០០ | មុី សាន | កងរយកុមារ | ផ្សារថ្មី | ១៨-១-៧៦ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៧០១ | ចាប ពេញ | យុទ្ធជន | ព្រែកហូរ | ១១-១១-៧៥ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៧០២ | ទូច ផន | កសិដ្ឋាន | តំបន់២៥ | ៩-៦-៧៦ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៧០៣ | សួស ព្រីញ | ប្រជាជន | កំពង់សោម | ៧-៥-៧៥ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៧០៤ | ឯក យាន | ប្រជាជន | តំបន់២៥ | ១២-៣-៧៦ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៧០៥ | លាវ ស៊ុតសុភ័ណថា | កម្មករ | អគ្គិសនីផ្សារតូច | ១៣-១២-៧៥ | ៣០-៦-៧៦ | ឈឺស្លាប់ |
| ៧០៦ | ចៅ ស៊ុមសត្ថា | កូនសិស្ស | កំពង់ស្ពឺ | ៦-៧-៧៦ | ១៦-៧-៧៦ | |
| ៧០៧ | សុក មួយ (ស្រី) | ប្រជាជន | កំពង់សោម | ២៨-៥-៧៦ | ១៦-៧-៧៦ | |
| ៧០៨ | ប៉ុល សែម | ប្រជាជន | តំបន់២៥ | ៧-៣-៧៦ | ១៧-៧-៧៦ | |
| ៧០៩ | អាត់ ផុន | ចោរព្រៃ | តំបន់៣៣ | ៥-៤-៧៦ | ១៨-៧-៧៦ | |
| ៧១០ | សុខ ដួន | ចោរព្រៃ | តំបន់៣៧ | ៩-៤-៧៦ | ១៨-៧-៧៦ | |

**(នៅមានត)**

* កាលបរិច្ឆេទនេះ ទស្សនាវដ្តីស្វែងរកការពិត កត់ត្រាតាមសំណៅដើមទាំងស្រុង ។

# ពីជ័យជម្នះឆ្ពោះទៅការបំផ្លាញខ្លួនឯង

កងពលលេខ៧០៣ ត្រូវបានបង្កើតឡើងនៅខែមករា ឆ្នាំ១៩៧២ ជាកងវរសេនាធំលេខ២៦៧ និងនៅខែមិថុនា ឆ្នាំ១៩៧៤ ជាកងពលលេខ១២ ដែលត្រូវបំពេញតួនាទីនៅលើសមរភូមិប្រយុទ្ធភាគខាងត្បូងនៃទីក្រុងភ្នំពេញ ។ យុទ្ធជនច្រើនជាង ៥០០០នាក់របស់កងពលនេះភាគច្រើនជ្រើសរើសចេញមកពីគ្រួសារកសិករនៅក្នុងតំបន់២៥(ស្ថិតនៅក្នុងខេត្តកណ្តាល) ។ នៅក្នុងខែកក្កដា ឆ្នាំ១៩៧៥ កងពលលេខ១២ត្រូវបានប្តូរឈ្មោះថ្មីជាកងពលលេខ៧០៣ ហើយស្ថិតនៅក្រោមបញ្ជាការរបស់សេនាធិការកងទ័ពបដិវត្តន៍ខ្មែរក្រហម ។ នៅចុងឆ្នាំ១៩៧៥ យុទ្ធជនដែលមានប្រវត្តិរូប «ស្អាតស្អំ» ត្រូវបានចាត់តាំងឲ្យទៅបម្រើការងារនៅមន្ទីរស-២១ ដែលជាមន្ទីរសន្តិសុខថ្នាក់មជ្ឈិម មន្ទីរនានា និងក្រសួងសំខាន់ៗជាច្រើនទៀត ។ ក្នុងអំឡុងពេលរបបខ្មែរក្រហមយុទ្ធជនយ៉ាងហោច៤៨២នាក់ នៃកងពលនេះ និងយុទ្ធជនយ៉ាងហោច៨៥នាក់ដែលបានទៅបម្រើការនៅមន្ទីរស-២១ ត្រូវបានចោទថាជា«ខ្មាំង»ហើយត្រូវចាប់ខ្លួនបញ្ជូនទៅសួរចម្លើយនៅមន្ទីរស-២១ និងយកទៅប្រហារជីវិតជាបន្តបន្ទាប់ ។ សៀវភៅនេះបានរៀបរាប់អំពីវិធីនៃការជ្រើសរើសយុវជនឲ្យចូលបម្រើបដិវត្តន៍ខ្មែរក្រហម និងការធ្វើទារុណកម្មចំពោះយុទ្ធជនដែលត្រូវបានចោទថាជាខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ។

បន្ទាប់ពីរដ្ឋប្រហាររបស់ឧត្តមសេនីយ៍ លន់ ណុល ទម្លាក់សម្តេចព្រះ នរោត្តម សីហនុ នៅថ្ងៃ១៨ មីនា ១៩៧០ ខ្មែរក្រហមបានចាប់ផ្តើមជ្រើសរើសកុមារឲ្យចូលបម្រើបដិវត្តន៍ ។ កុមារជាច្រើនដែលមានអាយុចាប់ពី១៥ដល់១៨ឆ្នាំ ហើយភាគច្រើនជាបុរសបានស្ម័គ្រចិត្តចូលក្នុងជួរកងទ័ពខ្មែរក្រហម ដោយជឿជាក់ថា ខ្មែរក្រហមអាចនាំសម្តេចព្រះ នរោត្តម សីហនុ មកកាន់អំណាចវិញ ហើយនិងអាចបញ្ចប់ភ្លើងសង្គ្រាមនៅក្នុងប្រទេសកម្ពុជា ។ ចាប់ពីឆ្នាំ១៩៧៤ រហូតដល់ឆ្នាំ១៩៧៥ ខណៈពេលដែលចំនួនអ្នកស្ម័គ្រចិត្តថយចុះ ប្រធានភូមិនិងគណៈឃុំខ្មែរក្រហមបានចាប់បង្ខំយុវជនវ័យក្មេងជាច្រើននាក់ឲ្យចូលបម្រើក្នុងជួរកងទ័ព ។

សៀវភៅនេះពណ៌នាអំពីដំណើរជីវិតរបស់យុទ្ធជនវ័យក្មេង៤០នាក់ដែលបានបម្រើការនៅក្នុងកងពលលេខ៧០៣ ដែលជាកងពលមួយក្នុងចំណោមកងពលទាំងប្រាំបួនដែលស្ថិតក្រោមការគ្រប់គ្រងរបស់សេនាធិការកងទ័ពបដិវត្តន៍នៃរបបកម្ពុជាប្រជាធិបតេយ្យ ។ យុទ្ធជនវ័យក្មេងទាំងនោះភាគច្រើនត្រូវបានជ្រើសរើសមកពីខេត្តកណ្តាល ។ ចាប់តាំងពីចូលបម្រើបដិវត្តន៍រហូតដល់ដណ្តើមបានជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរនៅថ្ងៃ១៧ មេសា ១៩៧៥ យុទ្ធជនវ័យក្មេងទាំងនោះបានលះបង់គ្រួសាររបស់ខ្លួនដើម្បីបុព្វហេតុបដិវត្តន៍ ហើយយុទ្ធជនខ្លះត្រូវបានចាត់តាំងឲ្យទៅបម្រើការនៅសេនាធិការ កងទ័ពមួយចំនួនបានទៅបម្រើការបុគ្គលិកនៃមន្ទីរស-២១និងមន្ទីរព្រៃសដែលជាសាខារបស់មន្ទីរស-២១ស្ថិតនៅក្នុងស្រុកដង្កោ ខេត្តកណ្តាល ។



បន្ទាប់ពីការបរាជ័យនៃខ្មែរក្រហមនៅក្នុងខែមករា ឆ្នាំ១៩៧៩ យុទ្ធជនមួយចំនួនតូចដែលនៅរស់រានមានជីវិត បាន

វិលត្រឡប់មកភូមិកំណើតរបស់ខ្លួនវិញ ។ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ អ្នកទាំងនោះត្រូវអាជ្ញាធរខេត្តកណ្ដាលនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា និងជំនាញការវៀតណាមនៅទីនោះ កោះ ហៅទៅកាន់ តំបន់កោះហៅកាន់ទៅមន្ទីរឃុំនិងស្រុក ដើម្បី «អប់រំរៀនសូត្រ» ។ ខណៈពេលនោះ អតីតយុទ្ធជនមួយចំនួនត្រូវបានអនុញ្ញាតឲ្យត្រឡប់មកផ្ទះសម្បែងវិញបន្ទាប់ពីការសាកសួរនិង «អប់រំឡើងវិញ» មួយរយៈខ្លី ។ យុទ្ធជនភាគច្រើនដែលធ្លាប់បម្រើការនៅមន្ទីរស-២១និងមន្ទីរព្រៃសត្រូវអាជ្ញាធរចាប់បញ្ជូនទៅមន្ទីរ ឃុំឃាំងខេត្តនិងគុកតេ-៣ ស្ថិតនៅក្នុងទីក្រុងភ្នំពេញ ដោយចោទប្រកាន់ពីបទជាប់ពាក់ព័ន្ធនឹងរបបខ្មែរក្រហម ។

## សេចក្ដីសន្និដ្ឋាន

នៅខែមេសា ឆ្នាំ១៩៧៣ វ៉ែន ហ៊ាង បានស្ម័គ្រចិត្តចូលបម្រើជាយុទ្ធនារីក្រហមនៅក្នុងកងពលលេខ៧០៣ ។ ចាប់តាំងពីរំដោះបានទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ១៩៧៥ រហូតដល់ការដួលរលំនៃរបបខ្មែរក្រហមនៅថ្ងៃ៧ មករា ១៩៧៩ ហ៊ាងមិនដែលបានមកសួរសុខទុក្ខក្រុមគ្រួសារម្ដងណាឡើយ ។ ជារៀង



រាល់ថ្ងៃជិតលិច លោកតា ឡាច ដាន់ ត្រូវជាឪពុករបស់ ហ៊ាង តែងតែឈរនៅក្រោមដើមអំពិលនៅខាងមុខផ្ទះទន្ទឹងមើលផ្លូវកូនស្រីរបស់គាត់ជានិច្ច ។ លោកតាតែងតែទៅសួរដំណឹងកូនស្រីរបស់គាត់តាមរយៈយុទ្ធជនដែលវិលត្រឡប់មកស្រុកកំណើតវិញ ។ លោកយាយ វ៉ែន រុន ជាម្តាយរបស់ ហ៊ាង បាននិយាយថា «តានៅមើលផ្លូវកូនស្រីរហូតដល់ដាច់បាយដាច់ទឹក» ។ មិនយូរប៉ុន្មាន លោកតា ដាន់ បានធ្លាក់ខ្លួនមានជំងឺ ហើយនៅឆ្នាំ១៩៨៣ លោកតាបានទទួលមរណភាពដោយមិនបានជួបមុខកូនស្រីរបស់គាត់ឡើយ ។ នៅឆ្នាំ១៩៩២ ជាមួយគ្នានឹងការធ្វើមាតុភូមិនិវត្តន៍របស់ប្រជាជនខ្មែរនៅតាមជំរំទល់ដែនកម្ពុជា-ថៃ វ៉ែន ហ៊ាង បានត្រឡប់មកស្រុកកំណើតរបស់ខ្លួនរួមជាមួយប្តីនិងកូនប្រុសស្រីពីរនាក់ ។ នៅឆ្នាំ១៩៧៨ មន្ទីរស-២១បានធ្វើ«ប្រវត្តិរូបសង្ខេប» វ៉ែន ហ៊ាង ចំនួនមួយសន្លឹកដែលមានបិទរូបថតពាក់កណ្តាលខ្លួនផង ។ តាមឯកសារប្រវត្តិរូបសង្ខេបបានបញ្ជាក់ថា វ៉ែន ហ៊ាង អាយុ២២ឆ្នាំ មានតួនាទីអនុក្រុមយុទ្ធនារី កងពលលេខ៧០៣ ។ មុខរបររកស៊ីមុនចូលបដិវត្តន៍គឺរកត្រី ។ វណ្ណៈភាពកសិករក្រ ។ ហ៊ាង បានចូលបម្រើបដិវត្តន៍តាមរយៈ គង់ ជាប្រធានភូមិត្រើយស្លា ។ ហ៊ាង មានកម្រិតវប្បធម៌ត្រឹមថ្នាក់ទី១០សង្គមចាស់ ។ ប្រវត្តិរូបរបស់ ហ៊ាង បានធ្វើឡើងដោយមន្ទីរស-២១ ក្នុងខណៈពេលដែល ហ៊ាង កំពុងលត់ដំខ្លួននៅមន្ទីរស-២១យ (គុកព្រៃស) ដោយសារមូលហេតុ «រត់ទៅផ្ទះម្តង» ។ នៅត្រង់ផ្នែកខាងក្រោមប្រវត្តិរូបមានបញ្ជាក់អំពីកាលបរិច្ឆេទដែល ហ៊ាង ត្រូវបានបញ្ជូនមកដល់មន្ទីរស-២១យ ថា «ចូលអង្គភាពៈ ២៣-១២-៧៥» ។

នៅក្រោយថ្ងៃ១៧ មេសា ១៩៧៥ មន្ទីរស-៥០គឺជាមន្ទីរឃុំឃាំងអ្នកទោសដែលជាមន្ត្រី បណ្ឌាស័ក្តិនៃរបបសាធារណរដ្ឋខ្មែរ ដែលរបបនេះដឹកនាំដោយលោកសេនាប្រមុខ លន់ ណុល ហើយស្ថិតក្រោមការគាំទ្រពីរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ នៅពេលនោះពុំទាន់មានវត្តមាន មន្ទីរស-២១នៅឡើយទេ ។ មន្ទីរស-៥០ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការយោធាក្រុងភ្នំពេញ ។ មន្ទីរស-៥០ ស្ថិតនៅប៉ែកខាងត្បូងផ្សារថ្មីដែលសព្វថ្ងៃបានក្លាយទៅជាស្នងការដ្ឋាននគរបាលជាតិ ។ បុគ្គលិកនៅមន្ទីរស-៥០ភាគច្រើន ត្រូវបានជ្រើសរើសចេញពីកងពលលេខ៧០៣ ។ អ្នកទោសនៅមន្ទីរស-៥០មានចំនួនមិនច្រើនទេ ហើយក៏មិនមានការសួរចម្លើយនិងធ្វើទារុណកម្មធ្ងន់ធ្ងរដែរ ។ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ អ្នកទោសនៅទីនេះបានបាត់ខ្លួនជារៀងរាល់ថ្ងៃ ។ កម្មាភិបាលដែលនៅមើលការខុសត្រូវនៅទីនេះជាប្រចាំរួមមាន សមមិត្ត សែម ជាប្រធានមន្ទីរនេះ សមមិត្ត ឃឹម វ៉ាត ហៅ ហ៊ី និងសមមិត្ត នុន ហ៊ុយ ។

សៀវភៅនេះបានចាប់ផ្តើមសរសេរពីខែសីហា ឆ្នាំ២០០០ ហើយបញ្ចប់នៅខែធ្នូ ឆ្នាំ២០០២ ។ ទាំងថវិកាសម្រាប់ការសិក្សាស្រាវជ្រាវនិងការបោះពុម្ពផ្សាយបានទទួលពីការិយាល័យប្រជាធិបតេយ្យសិទ្ធិមនុស្សនិងពលកម្មនៃក្រសួងការបរទេសសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលប្រទេសហុល្លង់ ។

## ប្រវត្តិរូបអ្នកនិពន្ធ

ហ៊ុយ វណ្ណៈ កើតនៅក្នុងមន្ទីរពេទ្យខ្មែរក្រហមមួយ នៅថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ១៩៧៨ នៅភូមិព្រីង ឃុំអង្គរាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ ។ ឪពុករបស់វណ្ណៈ ឈ្មោះ ហ៊ុយ ដុន និង ម្តាយឈ្មោះ យឹត គីមឡេង ។ វណ្ណៈ មានបងប្អូន៧នាក់គឺៈ បងប្រុសឈ្មោះ ហ៊ុយ សុជាត អាយុ៣៦ឆ្នាំ បងស្រីឈ្មោះ ហ៊ុយ ដល្លា អាយុ៣៣ឆ្នាំ បងប្រុសឈ្មោះ ហ៊ុយ សុភ័ក្រ អាយុ៣០ឆ្នាំ បងប្រុសឈ្មោះ ហ៊ុយ វណ្ណាត អាយុ២៨ឆ្នាំ បានបាត់ខ្លួននៅក្នុងខេត្តពោធិ៍សាត់នៅចុងឆ្នាំ១៩៧៨ ខណៈពេលដែលខ្មែរក្រហមកំពុងកេណ្ឌប្រជាជនឲ្យទៅភាគពាយ័ព្យនៃប្រទេសកម្ពុជា ប្អូនប្រុសឈ្មោះ ហ៊ុយ វណ្ណា អាយុ២១ឆ្នាំ ប្អូនស្រីឈ្មោះ ហ៊ុយ វណ្ណារី អាយុ១៨ឆ្នាំ និងប្អូនស្រីឈ្មោះ ហ៊ុយ តុលា អាយុ១៦ឆ្នាំ ។ វណ្ណៈ បានចូលរៀនសាលាមធ្យមសិក្សានៅក្នុងខេត្តតាកែវ ។

ក្នុងឆ្នាំ២០០០ វណ្ណៈ បានបញ្ចប់ការសិក្សានៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញថ្នាក់បរិញ្ញាប័ត្រអក្សរសាស្ត្រខ្មែរ ។ នៅក្នុងឆ្នាំ២០០០-២០០២ វណ្ណៈ ក៏បានសិក្សាផ្នែកសារព័ត៌មានដែលជាគម្រោងមួយរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញផ្តល់មូលនិធិដោយអង្គការទីភ្នាក់ងាររបស់សហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) ។

**រសី សាយ្យាណា**

***អតីតជនបដិវត្តន៍ខ្មែរក្រហមៈ***

# មនុស្សតែងតែចង់រស់

ស្រុកតាវែងស្ថិតនៅក្នុងខេត្តរតនគិរី ជាតំបន់ព្រៃភ្នំដាច់ស្រយាលពីទីប្រជុំជននានា ។ តាវែងមិនខុសពីស្រុកដទៃទៀតនៅភូមិភាគឦសានទេ ពីព្រោះជាកន្លែងដែលបង្កលក្ខណៈងាយស្រួលដល់ការលាក់ខ្លួនពង្រឹងកម្លាំងរបស់បដិវត្តន៍ខ្មែរ-ក្រហម ។

យ៉ន ខាំគឿង ជាជនជាតិព្រៅ អាយុ៧០ឆ្នាំ មានស្រុកកំណើតនៅភូមិដាវ ឃុំតាវែងក្រោម ស្រុកតាវែង ខេត្តរតនគិរី នៃតំបន់ភូមិភាគឦសាននេះ ។ ខាំគឿង គឺជាអតីតជនបដិវត្តន៍មួយរូបដែលនៅរស់រានមានជីវិតពីរបបខ្មែរក្រហម ។


យ៉ន ខាំគឿង

ដោយសារ ខាំគឿង ជាកូនកំព្រាម្តាយ ទើបធ្វើឲ្យលោកតា ជួបប្រទះនូវជីវភាពរស់នៅលំបាកវេទនានិងខ្វះការរៀនសូត្រ ហើយក៏បានសម្រេចចិត្តទៅបួសរៀននៅប្រទេសឡាវ ។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៩៥១ ខាំគឿង បានចូលរួមជាមួយចលនាឥស្សរៈនៅស្រុកឡៅង៉ាម ខេត្តសារ៉ាវ៉ាន់ ប្រទេសឡាវ តាមការណែនាំរបស់ ដ្មិល ជាប្រធានកងពល ។ ពេលចូលនោះ ខាំគឿង មិនបានធ្វើការងារអ្វីជាលក្ខណៈធំដុំទេ ក្រៅពីយាមផ្លូវឲ្យកម្មាភិបាលធំៗ ។ នៅឆ្នាំ១៩៥៧ ខាំគឿង វិលត្រឡប់មកស្រុកកំណើតវិញដោយសារតែឪពុកស្លាប់ ។

នៅទសវត្សរ៍១៩៦០ខ្មែរក្រហមចាប់ផ្តើមធ្វើនយោបាយលុបបំបាត់មិនឲ្យមានវណ្ណៈជិះជាន់ មិនឲ្យមានអ្នកមានអ្នកក្រនិងលើកស្ទួយវណ្ណៈកសិករក្រីក្រវិញ ។ ការឃោសនារបស់ខ្មែរក្រហមធ្វើឲ្យប្រជាជនជាច្រើន រួមទាំង ខាំគឿង ផង ចូលរួមបម្រើចលនាបដិវត្តន៍ខ្មែរក្រហមយ៉ាងស្មោះស្ម័គ្រ ។ ខ្មែរក្រហមដើរបំផុសបំផុលប្រជាជនស្លូតត្រង់នៅទីជនបទដាច់ស្រយាលដើម្បីធ្វើឲ្យឃើញពីការជិះជាន់កេងប្រវ័ញ្ចរបស់រដ្ឋាភិបាលសង្គមចាស់ ។

ខាំគឿង បានឲ្យដឹងថា នៅពេលចូលធ្វើបដិវត្តន៍ គាត់ធ្លាប់បានជួបធ្វើការជាមួយសមមិត្ត ប៉ុល ពត គឺនៅចន្លោះឆ្នាំ១៩៦១និងឆ្នាំ១៩៦៣ ដែលកាលណោះ ប៉ុល ពត ទើបនឹងវិលត្រឡប់មកពីក្រុងហាណូយ ។ នៅក្នុងឆ្នាំ១៩៦៧ ខាំគឿង បានជួបនឹង ប៉ុល ពត នៅតាមព្រំដែនម្តងទៀត ហើយថែមទាំងបានជូន ប៉ុល ពត ទៅកាន់មន្ទីររបស់សមមិត្ត កាលៀម ចាន់ធូនិង យ៉ាខាំដៃ ដែលនៅក្បែរអូរជុំ(ឃុំ) ស្រុកតាវែងទៀតផង ។ នៅទីនោះ ប៉ុល ពត បានបង្រៀន ខាំគឿង និងបងប្អូនជនជាតិភាគតិចអំពីនយោបាយដើម្បីចលនាប្រជាជនរយៈពេល១៥ថ្ងៃ ។ ក្រោយពីត្រឡប់មកកន្លែងវិញ ខាំគឿង ក៏ត្រូវ ប៉ុល ពត បញ្ជាឲ្យទៅប្រជុំនៅបានដុយ រយៈពេល១៥ថ្ងៃទៀត ។ ខាំគឿង បញ្ជាក់ប្រាប់ថា ប៉ុល ពត បានតម្រូវឲ្យរាល់កម្មាភិបាលស្រុកតាវែងទាំងអស់ត្រូវតែចូលរួមដោយខានមិនបាន ។

នៅខែមិថុនា ១៩៦៧ លោកតានិងបងប្អូនជនជាតិដទៃទៀត សរុបទាំងអស់៥០នាក់ (កម្មាភិបាលឃុំ២០នាក់ យុវជន៣០នាក់) ត្រូវទៅរៀនវគ្គនយោបាយនៅអណ្តូងមាស ដែលស្ថិតនៅតាមព្រំដែនកម្ពុជា-វៀតណាមរយៈពេល១ខែ ដែលបង្រៀនដោយ ប៉ុល ពត, អៀង សារី ផ្ទាល់ ក្នុងនោះមានវគ្គមាន

ទៀវ សំផន និង នួន ជា ដែរ ។ ខាំគៀង បន្តថា “គាត់បង្រៀនអំពីនយោបាយ ចលនាមហាជន ការឈឺចាប់ចំពោះចក្រពត្តិ ពួកសក្តិភូមិដែលជិះជាន់ គាបសង្កត់ប្រជាជន ។ ពេលនោះទើបរូបខ្ញុំមានឱកាសបានឃើញនិងទាក់ទងមានមុខមាត់ជាមួយ មេដឹកនាំធំៗទាំងអស់ដល់ទៅ៧ឆ្នាំ គឺចាប់ពីឆ្នាំ១៩៦៧ដល់១៩៧៣ ហើយមួយរយៈក្រោយមកក៏បែកគ្នា ព្រោះមេដឹកនាំទាំងនោះត្រូវចុះមកក្រោម” ។

ឆ្នាំ១៩៧៣ ការកាប់សម្លាប់បានកើតឡើង ។ កម្មាភិបាលឃុំតាវែងត្រូវបានចោទប្រកាន់ថា ក្បត់ប្រជាជន ក្បត់បដិវត្តន៍នយោបាយ សេដ្ឋកិច្ច និងជាភ្នាក់ងារសម្ងាត់ សេ.អ៊ី.អា របស់អាមេរិក ។ មិនតែប៉ុណ្ណោះថែមទាំងត្រូវចោទថា ទទួលឥទ្ធិពលនយោបាយពីវៀតណាម ដោយការប្រើអក្សរវៀតណាម ប្រើរបស់របរពីវៀតណាម និងមានការចាត់តាំងសហករណ៍ សេដ្ឋកិច្ចទៀតផង ។

ខាំគៀង បានពន្យល់ប្រាប់អំពីមូលហេតុនេះថា “ដោយសារខេត្តរតនគិរីមានព្រំដែនជាប់នឹងប្រទេសវៀតណាម ម៉្លោះហើយប្រជាជនមួយចំនួនអាចមានលទ្ធភាពលក់ដូរបន្តិចបន្តួចដូចជាជ្រូក មាន់ ទា ស្លៀកពាក់ និងប្រដាប់ប្រដាប្រើប្រាស់ផ្សេងៗ ដើម្បីជួយសម្រួលដល់ជីវភាពរបស់ពួកគេ ។ តែចំពោះបងប្អូនខាងក្រោមអត់មានទេ ពោលគឺអត់មែនទែន” ។

ដោយសារតែទំនាក់ទំនងរកស៊ីជាមួយជនជាតិវៀតណាមធ្វើឲ្យមានការមិនទុកចិត្តគ្នារវាងក្រុមអ្នកតស៊ូខ្មែរក្រហមនិងបងប្អូនជនជាតិ ភាពមន្ទិលសង្ស័យបានឈានទៅដល់ការសម្លាប់ជនជាតិភាគតិច ។ នៅឆ្នាំ១៩៧៣ កម្មាភិបាលមួយចំនួនធំដែលមានកំណើតជាជនជាតិភាគតិចបានរត់ភៀសខ្លួនទៅប្រទេសឡាវ ។

ខាំគៀង បានសន្និដ្ឋានថា ការសម្លាប់ជនជាតិ គឺភាគច្រើនធ្វើឡើងនៅ អូរជ្រៃ អូរល្មៀង និងអូរតាម៉ុល ។ ខាំគៀង បានប្រាប់ថា “នៅឆ្នាំ១៩៧៣ ពេលរូបខ្ញុំនិងបងប្អូនជនជាតិមួយចំនួនធ្វើដំណើរពីស្រុកស៊ឹងត្រែងទៅវ៉ឺនសៃ ដើម្បីរកទិញក្របី បានឃើញការសម្លាប់មនុស្សដោយផ្ទាល់ ។ ជនរងគ្រោះដែលត្រូវសម្លាប់នោះឈ្មោះ ប៊ូលៀន ជនជាតិឡាវ នៅវ៉ឺនសៃ មានតួនាទីជាប្រធានសហករណ៍ គ្រប់គ្រងផ្នែកសេដ្ឋកិច្ចស្រុកនិងជាអនុប្រធានរណសិរ្ស ។ ចំណែកឯតា ឈឿង ដែលជាសមាជិកក្រុមចាត់តាំង ត្រូវឈ្មោះ ថងស៊ីន ដែលជាជនជាតិឡាវដូចគ្នា និងមានតួនាទីជាប្រធានរណសិរ្ស ចាប់យកទៅសម្លាប់” ។

ក្រោយពីឃើញការសម្លាប់កើតមានជាបន្តបន្ទាប់បែបនេះ ខាំគៀង និងបងប្អូនជនជាតិភាគតិចមួយចំនួន បានភៀសខ្លួនទៅឡាវដើម្បីសុំជំនួយដោះស្រាយអំពីការចោទប្រកាន់នេះ ។ ខាំគៀង និងបងប្អូនជនជាតិបានឡើងទៅតវ៉ាដល់តំបន់អាត់តាពើនៃប្រទេសឡាវ ។ ខាងឡាវបានស្នើសុំឲ្យក្រុមគាត់វិលត្រឡប់មកប្រទេសកម្ពុជាវិញ តែក្រុមគាត់ថាវិលមកវិញបាន លុះត្រាណាតែមិនមានការចោទប្រកាន់តទៅទៀត ។ ខាំគៀង បានបញ្ជាក់ថាពេលនោះខាងមជ្ឈិមធានានិងទទួលខុសត្រូវដោយនិយាយជាមួយ ប៉ុល ពត មិនឲ្យមានការសម្លាប់តទៅទៀត ។ ដោយមានការធានាបែបនេះ ខាំគៀង និងបងប្អូនជនជាតិក៏យល់ព្រមត្រឡប់មកឃុំតាវែងវិញ ។ កាលនោះ ខាំគៀង មានតួនាទីជាសមាជិកស្រុកផង និងជាលេខាឃុំតាវែងផង (ពីមុនហៅស្រុក ៥៥) ។

នៅអំឡុងឆ្នាំ១៩៧៤ និង ១៩៧៥ ការចោទនិងការកាប់សម្លាប់ នៅតែមានជាបន្តបន្ទាប់ ។ បងប្អូនជនជាតិភាគតិចប្រហែល ៥០០០នាក់ក៏បានសម្រេចនាំគ្នារត់ភៀសខ្លួនទៅប្រទេសឡាវ និងប្រទេសវៀតណាមម្តងទៀត ។ ពាក់កណ្តាលទៅខាងវៀត-ណាមនិងពាក់កណ្តាលទៀតទៅខាងឡាវ ។ ចំណែក ខាំគៀង បានភៀសខ្លួនទៅរស់នៅឯប្រទេសវៀតណាមជាមួយ តាប៊ុនមី (បច្ចុប្បន្នរស់នៅខេត្តស្ទឹងត្រែង ជាពលរដ្ឋម្នាក់សាមញ្ញម្នាក់) ។ ខាំគៀង បានបញ្ជាក់ប្រាប់ថា “មូលហេតុដែលនាំឲ្យខ្ញុំរត់ភៀសខ្លួនទៅវៀតណាម ដោយសារតែខ្លាចស្លាប់ ព្រោះពេលនោះមានការកាប់សម្លាប់ខ្លាំងណាស់ពីសំណាក់កងកម្លាំង ប៉ុល ពត ។ ...មនុស្សគឺចង់រស់ មនុស្សតែងតែចង់រស់” ។

ក្រោយថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ ខាំគៀង និងបងប្អូនជនជាតិភាគតិចមួយចំនួនធំបាននាំគ្នាវិលត្រឡប់មកមាតុភូមិវិញ ។ បច្ចុប្បន្ននេះ ខាំគៀង គឺជាប្រជាពលរដ្ឋមួយរូបរស់នៅឃុំតាវែង ទីរួមស្រុកតាវែង ខេត្តរតនគិរី ។ **គីម ម៉ូលីដា**

# ដឹងការពិតនាំឱ្យចិត្តរសាយ
# ហេង តេង ៖ អ្នកទោសគុកទួលស្លែង


ហេង តេង (នៅក្នុងគុកទួលស្លែង)

នាព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ នៅក្នុងភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ ប្រជាជនមានការភ្ញាក់ផ្អើលឈូឆរ មកចោមរោមមើលឯកសារចម្លើយសារភាពរបស់ ហេង តេង ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានយកទៅប្រគល់ជូនក្រុមគ្រួសាររបស់ ហេង តេង ។ ឆាយ ជ្រុន បាននិយាយថា "នេះជាលើកទីមួយហើយដែលអ្នកភូមិយើងបានទទួលដំណឹងអំពីមនុស្សដែលបាត់ខ្លួន ។ នៅក្នុងឃុំត្រាំកក់នេះ មានមនុស្សបាត់ខ្លួនច្រើននាក់ ហើយញាតិមិត្តបងប្អូនមិនដែលដឹងថាអ្នកទាំងនោះស្លាប់ឬរស់ពិតប្រាកដឡើយ ។ ពេលនេះអ្នកភូមិទាំងអស់ពិតជាមានការភ្ញាក់ផ្អើលខ្លាំងណាស់" ។

ហេង អឹង អាយុ៦៦ឆ្នាំ ជាបងស្រីរបស់ ហេង តេង បាននិយាយថា "ប៉ុន្មានថ្ងៃមុនខ្ញុំឮប្អូនខាងណោះប្រាប់ថា គាត់បានទទួលដំណឹងរបស់ ហេង តេង ប្អូនប្រុសខ្ញុំ ។ ទោះបីជាខ្ញុំដឹងថាប្អូនខ្ញុំបានស្លាប់ទៅហើយក៏ដោយ ប៉ុន្តែដល់ពេលឮថាមានឯកសារបញ្ជាក់ថាប្អូនខ្ញុំស្លាប់នៅកន្លែងណាពេលណា ខ្ញុំសប្បាយចិត្តណាស់ ។ ខ្ញុំបាត់ដំណឹងប្អូនរបស់ខ្ញុំជាង៣០ឆ្នាំហើយ ពេលនេះក្មួយៗយកឯកសារប្អូនខ្ញុំមកឲ្យខ្ញុំអ៊ីចឹង ទោះជាប្អូនខ្ញុំមិននៅរស់ក៏ខ្ញុំអស់ចិត្តដែរ" ។

ហេង តេង គឺជាអ្នកទោសគុកទួលស្លែងដែលត្រូវខ្មែរក្រហមសម្លាប់ចោលនៅឆ្នាំ១៩៧៦ ។ ហេង តេង មានស្រុកកំណើតនៅភូមិត្រាំកក់ ឃុំញ៉ែងញ៉ង (បច្ចុប្បន្នឃុំត្រាំកក់) ស្រុកត្រាំកក់ ខេត្តកណ្តាល ។ ហេង តេង ជាកូនទី៥ក្នុងចំណោមបងប្អូន៧នាក់ ម្តាយជាជនជាតិខ្មែរ និងឪពុកជាជនជាតិចិន ។ ផ្ទះរបស់ ហេង តេង ស្ថិតនៅក្បែរផ្សារត្រាំកក់ ។ កាលពីកុមារ ហេង តេង ចូលរៀននៅក្នុងសាលាចិនដែលបង្កើតឡើងដោយសហគមន៍ចិននៅក្នុងឃុំញ៉ែងញ៉ង ។ លុះដល់ឆ្នាំ១៩៥២ ហេង តេង ក៏ចូលរៀនថ្នាក់កុមារដ្ឋាននៅសាលាបំពេញវិជ្ជាត្រាំកក់ ។ ឆាយ ជ្រុន អាយុ៦៤ឆ្នាំ ជាអតីតមិត្តសម្លាញ់របស់ ហេង តេង តាំងពីកុមារបាននិយាយថា "ហេង តេង ជាសិស្សពូកែបំផុតនៅក្នុងថ្នាក់និងតែងតែមាននឈ្មោះនៅក្នុងតារាងកិត្តិយសជារៀងរាល់ឆ្នាំ" ។ នៅក្នុងភូមិកំណើត ហេង តេង ត្រូវបានប្រជាជនក្នុងភូមិនិងលោកគ្រូអ្នកគ្រូទទួលស្គាល់ជាក្មេងល្អរៀនពូកែ ខស្សាហ៍ព្យាយាម និងមានអត្តចរិតស្លូតបូត សុភាពរាបសា ។

ឆ្នាំ១៩៥៨ ហេង តេង រៀនចប់ថ្នាក់កុមារដ្ឋាននិងទៅបន្តការសិក្សានៅអនុវិទ្យាល័យព្រះខទ័យ ខេត្តតាកែវ ហើយស្នាក់នៅផ្ទះរបស់សក្តិពទាហានម្នាក់ឈ្មោះ ហ៊ូ ហុងស៊ិន ។ ឆ្នាំ១៩៦២ ហេង តេង ប្រឡងយកសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិនិងចូលរៀននៅថ្នាក់ទី២នៃវិទ្យាល័យព្រះស៊ីសុវត្ថិនៅទីក្រុងភ្នំពេញ ។ ឆ្នាំដដែលនោះ ហ៊ូ ហុងស៊ិន បានផ្លាស់ទីលំនៅមករស់នៅទីក្រុងភ្នំពេញ ដូច្នេះ ហេង តេង ក៏មករស់នៅផ្ទះរបស់គាត់នៅភ្នំពេញ ហើយគាត់ក៏ទំនុកបម្រុង ហេង តេង ឲ្យរៀនសូត្របន្ត ។

ឆ្នាំ១៩៦៤ ហេង តេង ប្រឡងជាប់មធ្យមសិក្សាប័ត្រភាគទី១ និងចូលរៀននៅថ្នាក់បម្រុងនៃវិទ្យាស្ថានបច្ចេកទេសជាន់ខ្ពស់មិត្តភាពខ្មែរ-សូវៀត ។ ខែមីនា ឆ្នាំ១៩៧០ ហេង តេង បានបញ្ចប់ការសិក្សាថ្នាក់វិស្វករផ្នែកបច្ចេកទេសអគ្គិសនី ។ ក្រោយពីប្រឡងជាប់សញ្ញាប័ត្រវិស្វករ ហេង តេង ក៏ធ្វើជាសាស្ត្រាចារ្យផ្នែកបច្ចេកទេសអគ្គិសនីនៅវិទ្យាស្ថានបច្ចេកទេស

ជាន់ខ្ពស់មិត្តភាព ខ្មែរ-សូវៀត ។

នៅឆ្នាំ១៩៦៨ ឆាយ ជ្រុន ដែលធ្វើជាកម្មករសំណង់នៅភ្នំពេញ បានជួប ហេង តេង ដោយចៃដន្យនៅមុខវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត ។ ក្រោយព្រឹត្តិការណ៍រដ្ឋប្រហារដែលរៀបចំដោយ លន់ ណុល នាថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០ ស្រុកត្រាំកក់ក្លាយជាតំបន់រំដោះ ។ ទំនាក់ទំនងរវាង ហេង តេង និងក្រុមគ្រួសារដែលរស់នៅក្នុងស្រុកត្រាំកក់ ក៏ត្រូវកាត់ផ្តាច់ ។

ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ក្រុមគ្រួសាររបស់ ហេង តេង ត្រូវជម្លៀសចេញទៅរស់នៅឃុំជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ហើយនៅខែតុលា ឆ្នាំ១៩៧៥ដដែល ក៏ត្រូវជម្លៀសបន្តទៅរស់នៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ។

ក្រៅពី ហេង តេង និងប្រពន្ធកូន បងប្រុសបងស្រីពីរគ្រួសារទៀត ក៏ត្រូវជម្លៀសទៅរស់នៅខេត្តបាត់ដំបងដែរហើយ អ្នកទាំងអស់ក៏បាត់ដំណឹងរហូតដល់ក្រោយឆ្នាំ១៩៧៩ ហេង អឹង បានទទួលដំណឹងថា បងៗរបស់គាត់ទាំងបីនាក់និងក្រុមគ្រួសារ ត្រូវខ្មែរក្រហមសម្លាប់ចោល ។ ចំណែកឯ ហេង តេង ត្រូវអង្គការចាប់ខ្លួន ។

ឆ្នាំ១៩៨១ ឈូ ទិព្វ ជាអតីតគ្រូបង្រៀនរបស់ ហេង តេង នៅថ្នាក់កុមារដ្ឋាន បានមកទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងបានឃើញរូបថត ហេង តេង បិទនៅជញ្ជាំងសារមន្ទីរ ក៏នាំដំណឹងនេះទៅប្រាប់ដល់ក្រុមគ្រួសាររបស់ ហេង តេង នៅស្រុកត្រាំកក់ ខេត្តតាកែវ ។ ដូច្នេះក្រុមគ្រួសារញាតិមិត្តទាំងអស់ក៏សន្និដ្ឋានថា ហេង តេង បានស្លាប់នៅគុកទួលស្លែង ។

## ចម្លើយសារភាពរបស់ ហេង តេង

ឯកសារចម្លើយសារភាពរបស់ ហេង តេង មាន១១ដុំ



ប្រជាជននៅក្នុងភូមិអង្គរនាបកំពុងមើលឯកសារចម្លើយសារភាពរបស់ ហេង តេង



ហេង អឹង បងស្រីរបស់ ហេង តេង

ដាច់ពីគ្នា ។ ក្នុងនោះឯកសារ ៣ដុំដែលមានចំនួន២១ទំព័រពណ៌នាអំពីប្រវត្តិនិងសកម្មភាពផ្ទាល់របស់ ហេង តេង ។ ឯកសារ១ដុំផ្សេងទៀតមានចំនួន៥ទំព័រគឺជាបញ្ជីឈ្មោះមនុស្សចំនួន៧០នាក់ដែលពាក់ព័ន្ធនឹងសកម្មភាពសេ.អ៊ី.អាជាមួយ ហេង តេង ។ ឯកសារ៦ដុំទៀតសរុប៤២ទំព័រពណ៌នាលម្អិតអំពីមនុស្សចំនួន១៤នាក់ ដែល ហេង តេង ឆ្លើយសារភាពថាជាខ្សែរយៈ សេ.អ៊ី.អាជាមួយនឹងខ្លួន ។ ក្រៅពីនេះ មានប្រវត្តិរូបសង្ខេបរបស់ ហេង តេង មួយសន្លឹក ។ ទាំងប្រវត្តិរូប ទាំងឯកសារចម្លើយសារភាពមិនមានចុះកាលបរិច្ឆេទណាមួយសោះឡើយ ។

ឆាយ ជ្រុន បានប្រាប់ថា អក្សរនៅលើឯកសារចម្លើយសារភាពរបស់ ហេង តេង មិនមែនជាអក្សររបស់ ហេង តេង ផ្ទាល់ទេ ។ ដូច្នេះអក្សរទាំងនោះអាចជាអក្សររបស់អ្នកសួរចម្លើយ ឬអ្នកកត់ត្រាឯកសារ ។

នៅក្នុងចម្លើយសារភាពរបស់ ហេង តេង បាននិយាយថា ខ្លួនបានចូលសេអ៊ីអានៅឆ្នាំ១៩៧៣ តាមរយៈឈ្មោះ ឃឹម កាស ស័ក្តិ៥ប៉េអឹម និងបានទទួលការអប់រំពីឈ្មោះ ព្រុំ គុន ស័ក្តិ៣ប៉េអឹមនៃរបបសាធារណរដ្ឋខ្មែរ ។ បន្ទាប់ពីក្លាយជាភ្នាក់ងារយកការណ៍ឲ្យសេ.អ៊ី.អា ភារកិច្ចរបស់ ហេង តេង គឺតាមដានសកម្មភាពខ្មែរក្រហមតាមដានសិស្សនិស្សិត និងឃោសនាឲ្យពួកគេចូលចិត្តរបបសេរីចាត់ភ្នាក់ងារឲ្យចាំលបបាញ់និងគប់គ្រាប់បែកពេលដែលកងទ័ពខ្មែរក្រហមចូលក្រុងភ្នំពេញ ។ ក្រោយថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ បំផុសបំផុលប្រជាជនឲ្យបង្អាក់ដំណើរការកសាងប្រទេសរបស់បដិវត្តន៍បំផ្លាញឧបករណ៍ផលិតកម្ម បំផ្លាញសម្ភារក្នុងរោងចក្របំផុសប្រជាជនកុំឲ្យទុកចិត្តលើការដឹកនាំរបស់អង្គការបដិវត្តន៍ ។ ឆាយ ជ្រុន បាននិយាយថា “ខ្ញុំស្ទើរតែមិនជឿថា ហេង តេង ចូលសេ.អ៊ី.អា ប៉ុន្តែខ្ញុំមិនហ៊ានសន្និដ្ឋានទេ ព្រោះខ្ញុំបែកឆ្ងាយពីគេ ប្រហែលជាពេលនោះស្ថានភាពតម្រូវឲ្យចូលក៏មិនដឹង ឬក៏ ហេង តេង ចេះតែឆ្លើយឲ្យរួចខ្លួនពីទារុណកម្មសិន ឬក៏ពួកខ្មែរក្រហមចេះតែប្រឌិតឡើងដើម្បីឲ្យមានកំហុសចោទប្រកាន់ ហេង តេង ដើម្បីសម្លាប់ចោលក៏មិនដឹង” ។

តាមបញ្ជីឈ្មោះអ្នកទោសកម្ទេចនៅទួលស្លែង ហេង តេង ត្រូវសម្លាប់នៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៧៦ ។

## ប្រវត្តិរូបសង្ខេបរបស់ ហេង តេង

◆ឈ្មោះ ហេង តេង ភេទប្រុស ជនជាតិខ្មែរ

◆កើតឆ្នាំរោង (ឆ្នាំ១៩៤០) នៅភូមិត្រាំកក់ ឃុំញ៉ែងញ៉ង (បច្ចុប្បន្នឃុំត្រាំកក់) ស្រុកត្រាំកក់ ខេត្តតាកែវ ។

◆តួនាទីមុនរបបខ្មែរក្រហមៈ សាស្ត្រាចារ្យនៅវិទ្យាស្ថានបច្ចេកទេសមិត្តភាពខ្មែរ-សូវៀត

◆ឪពុកឈ្មោះ ហេង គាំង (ស្លាប់ឆ្នាំ១៩៧៤)

◆ម្តាយឈ្មោះ ហេង គីម (ស្លាប់ឆ្នាំ២០០១)

◆ប្រពន្ធឈ្មោះ គង់ ដាណាស៊ី មុខរបរៈ មេផ្ទះ (បច្ចុប្បន្នរស់នៅសហរដ្ឋអាមេរិក)

◆មានកូនប្រុសម្នាក់ឈ្មោះ ហេង ឥន្ទ្រមណី

◆ឃាត់ខ្លួននៅថ្ងៃទី១១ ខែមករា ឆ្នាំ១៩៧៦ នៅឃុំព្រះនេត្រព្រះ ស្រុកព្រះនេត្រព្រះ ខេត្តបាត់ដំបង ។

◆កម្ទេចថ្ងៃទី ២៣ ខែឧសភា ឆ្នាំ១៩៧៦

**សាន់ កល្យាណ**


ឌុប



# សេចក្តីព្រាង

## កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ


ហេន ខូរែល

ដោយហេតុថា មហាសន្និបាតអង្គការសហប្រជាជាតិបានរំឭកនៅក្នុងសេចក្តីសម្រេចរបស់ខ្លួន លេខ ៥៧/២២៨ ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ឡើងថា ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរចំពោះច្បាប់កម្ពុជានិងច្បាប់មនុស្សធម៌អន្តរ-ជាតិក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នៅតែជាបញ្ហាដែលបង្កឲ្យមានការព្រួយបារម្ភយ៉ាងធ្ងន់ធ្ងរដល់សហគមន៍អន្តរជាតិទាំងមូល ។

ដោយហេតុថា នៅក្នុងសេចក្តីសម្រេចដដែលនេះ មហា-សន្និបាតបានទទួលស្គាល់ការព្រួយបារម្ភធម្មានរូបរបស់រដ្ឋាភិបាលនិងប្រជាជនកម្ពុជាក្នុងការស្វែងរកយុត្តិធម៌ ការបង្រួបបង្រួមជាតិ ស្ថេរភាព សន្តិភាព និងសន្តិសុខ ។

ដោយហេតុថា អាជ្ញាធរកម្ពុជាបានស្នើសុំជំនួយពីអង្គការសហប្រជាជាតិដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជា-ធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងកំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩ ។

ដោយហេតុថា នៅមុនពេលចរចាលើកិច្ចព្រមព្រៀងនេះ មានការរីកចម្រើនជាច្រើនធ្វើឡើងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (បន្ទាប់ពីនេះហៅថា «លោកអគ្គលេខាធិការ») និងរាជរដ្ឋាភិបាលកម្ពុជាឈានទៅបង្កើតនូវអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈពេលកម្ពុជាប្រជាធិបតេយ្យ ដោយមានជំនួយអន្តរជាតិ ។

ដោយហេតុថា តាមសេចក្តីសម្រេចលេខ ៥៧/២២៨ មហាសន្និបាតបានស្វាគមន៍ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ហើយបានស្នើសុំលោកអគ្គលេខាធិការឲ្យបន្តការចរចាដោយពុំមានការពន្យារពេល ដើម្បីសម្រេចកិច្ចព្រមព្រៀងជាមួយរដ្ឋាភិបាលដោយឈរលើការចរចាពីពេលមុនស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញសមស្របតាមខ្លឹមសារនៃសេចក្តីសម្រេចនេះ ដើម្បីឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចចាប់ផ្តើមដំណើរការបានឆាប់ ។

ដោយហេតុថា លោកអគ្គលេខាធិការនិងរដ្ឋាភិបាលកម្ពុជាបានធ្វើការចរចាស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។

អាស្រ័យហេតុនេះ ក្នុងពេលនេះ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាដូចតទៅៈ

### មាត្រា ១

### *គោលបំណង*

គោលបំណងរបស់កិច្ចព្រមព្រៀងនេះគឺកំណត់អំពីកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ការរំលោភទៅលើច្បាប់មនុស្សធម៌និងទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើ

អនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងកំឡុងថ្ងៃ ១៧ មេសា ១៩៧៥ ដល់ថ្ងៃ ០៦ មករា ១៩៧៩ ។ ក្នុងចំណោមប្រការផ្សេងៗទៀត កិច្ចព្រមព្រៀងនេះផ្តល់នូវមូលដ្ឋានគតិយុត្តិ គោលការណ៍ និងបែបបទសម្រាប់កិច្ចសហប្រតិបត្តិការនេះ ។

## មាត្រា ២

## ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ

១) កិច្ចព្រមព្រៀងនេះទទួលស្គាល់ថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរូបរឿងក្តីដូចដែលបានចែងក្នុង "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ" (បន្ទាប់ពីនេះហៅថា "ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ") ដូចដែលបានអនុម័តនិងធ្វើវិសោធនកម្មដោយអង្គនិតិបញ្ញត្តិកម្ពុជា នៅក្រោមរដ្ឋធម្មនុញ្ញកម្ពុជា ។ កិច្ចព្រមព្រៀងនេះទទួលស្គាល់ផងដែរថា អង្គជំនុំជម្រះវិសាមញ្ញមានយុត្តាធិការលើរូបបុគ្គលលើមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជា-ធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានចែងក្នុងមាត្រា១ នៃកិច្ចព្រមព្រៀង ។

២) កិច្ចព្រមព្រៀងនេះត្រូវអនុវត្តក្នុងប្រទេសកម្ពុជាតាមរយៈច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលបានចូលជាធរមាននិងបានធ្វើវិសោធនកម្ម ។ កិច្ចព្រមព្រៀងនេះត្រូវអនុវត្តតាមអនុសញ្ញាទីក្រុងវីយែន ស្តីពីច្បាប់នៃសន្ធិសញ្ញាជាពិសេសមាត្រា ២៦ និង ២៧ ។

៣) នៅក្នុងករណីចាំបាច់មានវិសោធនកម្មលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ វិសោធនកម្មបែបនេះត្រូវតែមានការពិគ្រោះយោបល់គ្នាជាមុនរវាងភាគីទាំងពីរ ។

## មាត្រា ៣

## ចៅក្រម

១) ចៅក្រមកម្ពុជាម្នាង និងម្នាងទៀតចៅក្រមដែលតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម តាមសំណើរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ (បន្ទាប់ពីនោះហៅថា "ចៅក្រមអន្តរជាតិ") ត្រូវបម្រើការនៅក្នុងអង្គជំនុំជម្រះនីមួយៗនៃអង្គជំនុំជម្រះវិសាមញ្ញទាំងពីរថ្នាក់ ។

២) សមាសភាពរបស់អង្គជំនុំជម្រះមានដូចខាងក្រោមៈ

ក) អង្គជំនុំជម្រះសាលាដំបូងៈ ចៅក្រមខ្មែរបីរូប និងចៅក្រមអន្តរជាតិពីររូប ។

ខ) អង្គជំនុំជម្រះតុលាការកំពូលៈ ដែលជាកន្លែងទទួលពាក្យបណ្តឹងឧទ្ធរណ៍ផងនិងជាកន្លែងចេញសម្រេចបិទផ្លូវតវ៉ាផងៈ ចៅក្រមខ្មែរបួនរូប និងចៅក្រមអន្តរជាតិបីរូប ។

៣) ចៅក្រមត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត មានគុណសម្បត្តិ ដែលតម្រូវសម្រាប់តែងតាំងឲ្យបម្រើការក្នុងការិយាល័យតុលាការនៅប្រទេសរបស់ខ្លួន ។ ចៅក្រមត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួននិងមិនអាចទទួលយកឬស្វែងរកការណែនាំពីរដ្ឋាភិបាលឬប្រភពណាមួយផ្សេងទៀតឡើយ ។

៤) នៅក្នុងគ្រប់សមាសភាពរបស់អង្គជំនុំជម្រះ ត្រូវគិតគូរឲ្យបានត្រឹមត្រូវដល់បទពិសោធន៍របស់ចៅក្រមក្នុងច្បាប់ព្រហ្មទណ្ឌ ច្បាប់អន្តរជាតិ រួមទាំងច្បាប់មនុស្សធម៌អន្តរជាតិនិងច្បាប់សិទ្ធិមនុស្ស ។

៥) លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងបញ្ជូនបញ្ជីឈ្មោះបេក្ខជនសម្រាប់តំណែងជាចៅក្រមអន្តរជាតិយ៉ាងតិចប្រាំពីររូប ហើយពីក្នុងបញ្ជីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងចំនួនប្រាំរូបដើម្បីបម្រើការជាចៅក្រមនៅក្នុងអង្គជំនុំជម្រះក្តីទាំងពីរថ្នាក់ ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតែងតាំងចៅក្រមអន្តរជាតិ ដោយយកពីក្នុងបញ្ជីឈ្មោះដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានប្រគល់ជូនតែប៉ុណ្ណោះ ។

៦) ក្នុងករណីដែលមានកន្លែងទំនេររបស់ចៅក្រមអន្តរជាតិណាមួយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងចៅក្រមអន្តរជាតិមួយរូបទៀតពីក្នុងបញ្ជីឈ្មោះដដែលនេះជំនួស ។

៧) ចៅក្រមត្រូវតែងតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

៨) បន្ថែមលើចៅក្រមអន្តរជាតិដែលជម្រះក្តីក្នុងអង្គជំនុំជម្រះនឹងមានវត្តមាននៅគ្រប់លំដាប់ថ្នាក់នៃការជំនុំជម្រះ ប្រធាន

អង្គជំនុំជម្រះដោយផ្អែកតាមករណីនីមួយៗ និងដោយយកពីក្នុងបញ្ជីឈ្មោះដែលលោកអគ្គលេខាធិការបានដាក់ជូន អាចចាត់តាំងនូវចៅក្រមបម្រុងមួយរូប ឬច្រើនជាងនេះ ដែលត្រូវមានវត្តមាននៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ សម្រាប់ជំនួសចៅក្រមអន្តរជាតិណាមួយ ប្រសិនបើចៅក្រមនោះមិនអាចបន្តការជំនុំជម្រះក្តីបាន ។

## មាត្រា ៤
## ការសម្រេចសេចក្តី

១) ចៅក្រមត្រូវព្យាយាមឈានទៅដល់ការឯកភាពគ្នាជាឯកច្ឆ័ន្ទនៅក្នុងការសម្រេចសេចក្តីរបស់ខ្លួន ។ ប្រសិនបើមិនអាចទទួលបានការឯកភាពគ្នាជាឯកច្ឆ័ន្ទទេ ត្រូវអនុវត្តរូបមន្តខាងក្រោមនេះ ៖

ក) ការសម្រេចសេចក្តីរបស់សាលាដំបូងតម្រូវឲ្យមានសំឡេងឆ្នោតគាំទ្រពីចៅក្រមបួនរូបយ៉ាងតិច ។

ខ) ការសម្រេចសេចក្តីដោយអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកំពូល តម្រូវឲ្យមានសំឡេងឆ្នោតគាំទ្រពីចៅក្រមប្រាំរូបយ៉ាងតិច ។

២) នៅពេលដែលគ្មានការឯកភាពជាឯកច្ឆ័ន្ទទេ ការសម្រេចសេចក្តីរបស់អង្គជំនុំជម្រះត្រូវមានទស្សនៈរបស់មតិភាគច្រើន និងមតិភាគតិច ។

## មាត្រា ៥
## ចៅក្រមស៊ើបអង្កេត

១) មានចៅក្រមស៊ើបអង្កេតខ្មែរមួយរូប និងចៅក្រមស៊ើបអង្កេតអន្តរជាតិមួយរូប ដែលបម្រើការជាសហចៅក្រមស៊ើបអង្កេត ។ សហចៅក្រមស៊ើបអង្កេតទទួលខុសត្រូវចំពោះការងារស៊ើបអង្កេត ។

២) សហចៅក្រមស៊ើបអង្កេតត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ មិនលម្អៀង និងសុចរិត មានគុណសម្បត្តិដែលតម្រូវសម្រាប់តែងតាំងឲ្យបម្រើការក្នុងការិយា-ល័យតុលាការក្នុងផ្នែកនេះនៅក្នុងប្រទេសរបស់ខ្លួន ។

៣) សហចៅក្រមស៊ើបអង្កេតត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរក ការណែនាំពីរដ្ឋាភិបាលឬប្រភពណាមួយផ្សេងទៀតបានឡើយ ។ ប៉ុន្តែគេត្រូវយល់ថា វិសាលភាពនៃការស៊ើបអង្កេតគឺកំណត់ត្រឹមតែមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិនិងទម្លាប់អន្តរជាតិនិងអនុសញ្ញាអន្តរជាតិដែលប្រទេសកម្ពុជាទទួលស្គាល់ និងដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

៤) សហចៅក្រមស៊ើបអង្កេតត្រូវសហការគ្នាដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការស៊ើបអង្កេត ។ នៅក្នុងករណីដែលចៅក្រមស៊ើបអង្កេតមិនអាចឯកភាពគ្នាថា ត្រូវបន្តការស៊ើបអង្កេតណាមួយ ការស៊ើបអង្កេតនោះត្រូវដំណើរការទៅមុខទៀត លើកលែងតែចៅក្រមទាំងនេះឬចៅក្រមណាម្នាក់ក្នុងចំណោមចៅក្រមទាំងនេះ ផ្ញើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឲ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា ៧ ។

៥) បន្ថែមពីលើបញ្ជីឈ្មោះបេក្ខជនចៅក្រមអន្តរជាតិដែលបានចែងក្នុងមាត្រា៣ វាក្យខ័ណ្ឌទី៥ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិនឹងដាក់ជូននូវបញ្ជីឈ្មោះបេក្ខជនពីររូបទៀត ហើយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងចៅក្រមមួយរូបពីក្នុងបញ្ជីនេះ ដើម្បីបម្រើការជាចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមួយរូបទៀតជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ។

៦) ក្នុងករណីមានកន្លែងទំនេរ ឬតម្រូវការដើម្បីបំពេញកន្លែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អ្នកដែលត្រូវតែងតាំងឲ្យបំពេញកន្លែងនោះត្រូវតែជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុងនោះតែម្តង ។

៧) ចៅក្រមស៊ើបអង្កេតត្រូវតែងតាំងសម្រាប់រយៈពេលនៃការជំនុំជម្រះ ។

## មាត្រា ៦
## ព្រះរាជអាជ្ញា

១) មានព្រះរាជអាជ្ញាខ្មែរមួយរូប និងព្រះរាជអាជ្ញាអន្តរ-ជាតិមួយរូបដែលមានសមត្ថកិច្ចបង្ហាញខ្លួននៅក្នុងអង្គជំនុំជម្រះ

ក្តីទាំងពីរថ្នាក់ដោយបម្រើការជាសហព្រះរាជអាជ្ញា ។ សហព្រះរាជអាជ្ញាទទួលខុសត្រូវលើការងារចោទប្រកាន់ ។

២) សហព្រះរាជអាជ្ញាត្រូវតែជាបុគ្គលដែលមានចរិតលក្ខណៈនិងស្មារតីខ្ពស់ និងមានកម្រិតសមត្ថភាពវិជ្ជាជីវៈខ្ពស់ និងមានបទពិសោធន៍ទូលំទូលាយក្នុងការស៊ើបអង្កេតនិងការចោទប្រកាន់ក្នុងរឿងក្តីព្រហ្មទណ្ឌ ។

៣) សហព្រះរាជអាជ្ញាត្រូវឯករាជ្យក្នុងការបំពេញមុខងាររបស់ខ្លួន និងមិនទទួលយក ឬស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពណាមួយផ្សេងទៀតឡើយ ។ ប៉ុន្តែគេត្រូវយល់ថា វិសាលភាពនៃការចោទប្រកាន់គឺកំណត់ត្រឹមមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ និងដែលបានប្រព្រឹត្តក្នុងកំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។

៤) សហព្រះរាជអាជ្ញាត្រូវសហការគ្នាដើម្បីឈានទៅដល់ការឯកភាពគ្នាមួយក្នុងការចោទប្រកាន់ ។ ក្នុងករណីដែលព្រះរាជអាជ្ញា មិនអាចឯកភាពគ្នាថាត្រូវបន្តការចោទប្រកាន់ណាមួយ ការចោទប្រកាន់នោះត្រូវដំណើរការទៅមុខទៀតលើកលែងតែព្រះរាជអាជ្ញាទាំងពីរនេះ ឬព្រះរាជអាជ្ញាណាមួយក្នុងចំណោមព្រះរាជអាជ្ញាទាំងពីរ ធ្វើការស្នើសុំនៅក្នុងរយៈពេលសាមសិបថ្ងៃ ឲ្យដោះស្រាយការខ្វែងគំនិតគ្នានេះតាមមាត្រា៧ ។

៥) លោកអគ្គលេខាធិការនឹងផ្តល់ជូននូវបញ្ជីឈ្មោះបេក្ខជនពីររូប ហើយពីក្នុងបញ្ជីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនឹងតែងតាំងម្នាក់ជាសហព្រះរាជអាជ្ញា និងមួយរូបទៀតជាសហព្រះរាជអាជ្ញាអន្តរជាតិបម្រុងនោះតែម្តង ។

៦) ក្នុងករណីមានកន្លែងទំនេរ ឬតម្រូវការដើម្បីបំពេញកន្លែងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អ្នកដែលត្រូវតែងតាំងឲ្យបំពេញកន្លែងនោះ ត្រូវតែជាចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង ។

៧) ព្រះរាជអាជ្ញាត្រូវតែងតាំងសម្រាប់រយៈពេលនៃដំណើរការជំនុំជម្រះ ។

៨) សហព្រះរាជអាជ្ញានីមួយៗ មានព្រះរាជអាជ្ញារងមួយរូបឬច្រើនរូបជាជំនួយក្នុងការចោទប្រកាន់ចំពោះមុខអង្គជំនុំជម្រះ ។ ព្រះរាជអាជ្ញារងអន្តរជាតិត្រូវតែងតាំងដោយព្រះរាជអាជ្ញាអន្តរជាតិពីបញ្ជីឈ្មោះមួយដែលផ្តល់ដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ៧
## ការដោះស្រាយនូវការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតឬសហព្រះរាជអាជ្ញា

១) ក្នុងករណីដែលសហចៅក្រមស៊ើបអង្កេតឬសហព្រះរាជអាជ្ញាបានធ្វើសំណើស្របតាមមាត្រា៥ វាក្យខ័ណ្ឌ៤ ឬមាត្រា៦ វាក្យខ័ណ្ឌ៤ តាមករណីដែលកើតឡើងសហចៅក្រមស៊ើបអង្កេតឬសហព្រះរាជអាជ្ញាត្រូវដាក់ជូនឯកសាររាយការណ៍ជាលាយលក្ខណ៍អក្សរពីអង្គហេតុនិងហេតុផល បញ្ជាក់ពីគោលជំហរខ្វែងគំនិតគ្នារបស់ខ្លួន ដាក់ជូនប្រធានការិយាល័យរដ្ឋបាល ។

២) ការខ្វែងគំនិតគ្នានេះនឹងត្រូវដោះស្រាយជាបន្ទាន់ដោយ «អង្គបុរេជំនុំជម្រះ» មួយមានចៅក្រមប្រាំរូប ដែលបីរូបតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដោយមានមួយរូបជាប្រធាននិងពីររូបទៀតតែងតាំងដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមតាមសំណើរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ ការជ្រើសរើសចៅក្រមនេះត្រូវអនុវត្តតាមមាត្រា៣ វាក្យខ័ណ្ឌទី៣ ។

៣) ពេលដែលទទួលបានឯកសាររាយការណ៍ដូចបានចែងក្នុងវាក្យខ័ណ្ឌទី១ ប្រធានការិយាល័យរដ្ឋបាលត្រូវកោះប្រជុំអង្គបុរេជំនុំជម្រះភ្លាម និងបែងចែកឯកសាររាយការណ៍នេះជូនដល់សមាជិកអង្គបុរេជំនុំជម្រះ ។

៤) ការសម្រេចសេចក្តីរបស់អង្គបុរេជំនុំជម្រះដែលមិនអាចប្តឹងឧទ្ធរណ៍បាន ត្រូវមានសំឡេងឆ្នោតគាំទ្រដោយចៅក្រមយ៉ាងតិចបួនរូប ។ ការសម្រេចសេចក្តីនេះត្រូវជូនដល់ប្រធានរដ្ឋបាលដែលនឹងផ្សព្វផ្សាយ ហើយចែកជូនដល់សហចៅក្រមស៊ើបអង្កេតឬសហព្រះរាជអាជ្ញា ។ សហចៅក្រមស៊ើបអង្កេតឬសហព្រះរាជអាជ្ញា នឹងត្រូវដំណើរការភ្លាមៗស្របទៅតាម

ការសម្រេចរបស់អង្គបុរេជំនុំជម្រះ ។ ប្រសិនបើគ្មានមតិភាគច្រើនដែលត្រូវការសម្រាប់ធ្វើការសម្រេចសេចក្តីទេ ការស៊ើបអង្កេតឬការចោទប្រកាន់នឹងត្រូវបន្តដំណើរការទៅមុខទៀត ។

## មាត្រា ៨

## ការិយាល័យរដ្ឋបាល

១) ត្រូវមានការិយាល័យរដ្ឋបាលមួយដើម្បីបម្រើការអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេត និងអយ្យការ ។

២) ត្រូវមានប្រធានការិយាល័យរដ្ឋបាលខ្មែរមួយរូបដែលនឹងត្រូវតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជា ។ ប្រធានមានភារៈកិច្ចគ្រប់គ្រងទូទៅលើការងាររបស់ការិយាល័យរដ្ឋបាល លើកលែងតែការងារដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនិងនីតិវិធីរបស់អង្គការសហប្រជាជាតិ ។

៣) ត្រូវមានអនុប្រធានការិយាល័យរដ្ឋបាលអន្តរជាតិមួយរូបដែលនឹងត្រូវតែងតាំងដោយលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អនុប្រធានត្រូវទទួលខុសត្រូវចំពោះការជ្រើសរើសបុគ្គលិកអន្តរជាតិទាំងអស់ និងការគ្រប់គ្រងលើសមាសភាពអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះសហចៅក្រមស៊ើបអង្កេត ការិយាល័យព្រះរាជអាជ្ញា និងការិយាល័យរដ្ឋបាល ។

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា នៅពេលដែលអនុប្រធានការិយាល័យអន្តរជាតិត្រូវបានតែងតាំងដោយលោកអគ្គលេខាធិការ ការតែងតាំងដោយរាជរដ្ឋាភិបាលកម្ពុជាឲ្យជននោះទទួលមុខតំណែង ក៏ត្រូវធ្វើឡើងភ្លាមដែរ ។

៤) ប្រធាននិងអនុប្រធានការិយាល័យត្រូវសហការគ្នាដើម្បីអនុវត្តឲ្យកិច្ចការរដ្ឋបាលមានប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អ ។

## មាត្រា ៩

## ខក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ

យុត្តាធិការលើរូបរឿងក្តីរបស់អង្គជំនុំជម្រះវិសាមញ្ញរួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដូចដែលបានកំណត់ក្នុងអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការនិងការផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដូចបានកំណត់ក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិឆ្នាំ១៩៩៨ និងការរំលោភធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងឧក្រិដ្ឋកម្មផ្សេងៗទៀតដូចបានកំណត់ក្នុងជំពូកទី២នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ។

## មាត្រា ១០

## ទោសប្បញ្ញត្តិ

ទណ្ឌកម្មជាអតិបរមាសម្រាប់ផ្តន្ទាទោសឧក្រិដ្ឋកម្មនៅក្រោមយុត្តាធិការនៃអង្គជំនុំជម្រះវិសាមញ្ញ គឺកំណត់ត្រឹមដាក់ពន្ធនាគារមួយជីវិត ។

## មាត្រា ១១

## ការលើកលែងទោស

១) រាជរដ្ឋាភិបាលកម្ពុជានឹងមិនស្នើសុំឲ្យមានការលើកលែងទោស ឬអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចនឹងត្រូវស៊ើបអង្កេត ឬនឹងត្រូវផ្តន្ទាទោសអំពីឧក្រិដ្ឋកម្មដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះទេ ។

២) ប្រការនេះផ្អែកលើសេចក្តីប្រកាសដោយរាជរដ្ឋាភិបាលកម្ពុជាថា រហូតមកដល់ពេលនេះមានតែករណីមួយគត់ទាក់ទងនឹងបញ្ហាដែលគ្របដណ្តប់ដោយច្បាប់នេះ នៅថ្ងៃទី ១៤ កញ្ញា ១៩៩៦ ពេលដែលការលើកលែងទោសត្រូវបានផ្តល់ដល់មនុស្សម្នាក់គត់ដែលត្រូវបានផ្តន្ទាទោសនៅឆ្នាំ១៩៧៩ ពីបទប្រល័យពូជសាសន៍ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា វិសាលភាពនៃការលើកលែងទោសនេះគឺត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។

## មាត្រា ១២

## នីតិវិធី

១) នីតិវិធីត្រូវសមស្របជាមួយច្បាប់កម្ពុជា ។ នៅពេលណាដែលច្បាប់កម្ពុជាពុំអាចដោះស្រាយបានចំពោះបញ្ហាដោយឡែកណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការ

បកស្រាយ ឬការអនុវត្តន៍បទប្បញ្ញត្តិណាដែល ពាក់ព័ន្ធក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ ។

២) អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមស្តង់ដារយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ដូចដែលបានចែងក្នុងមាត្រា ១៤ និង ១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយដែលកម្ពុជាគឺជាភាគីហត្ថលេខីដែរ ។ ក្នុងផលប្រយោជន៍ធានាឲ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងគួរឲ្យទុកចិត្តបាន គេត្រូវយល់ថា តំណាងរបស់រដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ តំណាងបណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់ ។ ការលើកលែងមិនឲ្យចូលរួមស្តាប់ការជំនុំជម្រះក្តីនេះ តាមមាត្រា១៤នៃអនុសញ្ញា អាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុតតាមយោបល់របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធហើយតែនៅពេលណាដែលការផ្សព្វផ្សាយចេញទៅនាំឲ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌ ។

## មាត្រា ១៣

## សិទ្ធិរបស់ជនជាប់ចោទ

១) សិទ្ធិរបស់ជនជាប់ចោទដែលមានចែងនៅក្នុងមាត្រា ១៤ និង១៥ នៃអនុសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ត្រូវតែបានគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះជាពិសេស រួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវនិងជាសាធារណៈ សិទ្ធិត្រូវបានចាត់ទុកថា គ្មានទោសពៃរ៍រហូតដល់ពេលរកឃើញថាជាប់ពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន សិទ្ធិទទួលបាននូវមេធាវី ប្រសិនបើជនជាប់ចោទគ្មានលទ្ធភាពជួលមេធាវីដោយខ្លួនឯង និងសិទ្ធិពិនិត្យឬបានពិនិត្យសាក្សីដាក់បន្ទុក ។

២) អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា ប្រការស្តីពីសិទ្ធិទទួលបានមេធាវីការពារក្តីនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ បានន័យថា ជនជាប់ចោទមានសិទ្ធិជ្រើសរើសរកមេធាវីដោយខ្លួនឯង ដូចដែលបានធានានៅក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

## មាត្រា ១៤

## អគារ

រាជរដ្ឋាភិបាលកម្ពុជាត្រូវផ្តល់និងត្រូវរ៉ាប់រងចំណាយដោយខ្លួនឯងនូវអគារសម្រាប់សហចៅក្រមស៊ើបអង្កេតការិយាល័យព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។ រាជរដ្ឋាភិបាលក៏ត្រូវផ្តល់ផងដែរនូវសម្ភារប្រើប្រាស់ ការជួយសម្រួល និងសេវាកម្មផ្សេងៗទៀត ដែលចាំបាច់សម្រាប់ប្រតិបត្តិការរបស់អង្គជំនុំជម្រះដែលអាចឯកភាពគ្នាតាមរយៈកិច្ចព្រមព្រៀងដោយឡែករវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាល ។

## មាត្រា ១៥

## បុគ្គលិកកម្ពុជា

ប្រាក់បៀវត្សនិងប្រាក់បំណាច់របស់ចៅក្រមកម្ពុជា ព្រះរាជអាជ្ញាកម្ពុជា និងបុគ្គលិកកម្ពុជាផ្សេងទៀត ជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា ។

## មាត្រា ១៦

## បុគ្គលិកអន្តរជាតិ

ប្រាក់បៀវត្សនិងប្រាក់បំណាច់របស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងបុគ្គលិកអន្តរជាតិផ្សេងទៀត ដែលជ្រើសរើសដោយអង្គការសហប្រជាជាតិ ជាបន្ទុករបស់អង្គការសហប្រជាជាតិ ។

## មាត្រា ១៧

## ជំនួយហិរញ្ញវត្ថុនិងជំនួយផ្សេងៗទៀត របស់អង្គការសហប្រជាជាតិ

អង្គការសហប្រជាជាតិត្រូវទទួលខុសត្រូវដូចតទៅនេះ៖

ក) ប្រាក់បៀវត្សរបស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ អនុប្រធាន

ការិយាល័យរដ្ឋបាល ព្រមទាំងបុគ្គលិកអន្តរជាតិដទៃទៀត

ខ) ចំណាយសម្រាប់ថ្លៃទឹក ភ្លើង ទូរស័ព្ទ ។ល។ ប្រសេវាផ្សេងៗ ដោយមានការព្រមព្រៀងគ្នាដោយឡែករវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា

គ) ប្រាក់បៀវត្សសម្រាប់មេធាវីការពារក្តី

ឃ) ការធ្វើដំណើររបស់សាក្សីក្នុងប្រទេសកម្ពុជានិងមកពីបរទេស

ង) សុវត្ថិភាពនិងសន្តិសុខដោយមានការព្រមព្រៀងដោយឡែករវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាល

ច) ជំនួយខបត្ថម្ភមានកំណត់ដទៃទៀត ដែលអាចនឹងចាំបាច់ដើម្បីធានាដំណើរការរលូនដល់ការស៊ើបអង្កេតការចោទប្រកាន់និងអង្គជំនុំជម្រះវិសាមញ្ញ ។

## មាត្រា ១៨

## ភាពមិនអាចរំលោភបំពានបាននៃបណ្ណសារនិងឯកសារ

បណ្ណសាររបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះនិងការិយាល័យរដ្ឋបាល ហើយជាទូទៅរាល់ឯកសារនិងសម្ភារទាំងអស់ដែលរកបានមក ដែលជារបស់ឬប្រើប្រាស់ដោយអង្គជំនុំជម្រះវិសាមញ្ញ ទោះជានៅកន្លែងណាក៏ដោយក្នុងប្រទេសកម្ពុជា ហើយទោះជារក្សាទុកដោយជនណាក៏ដោយ មិនអាចត្រូវរំលោភបំពានបានឡើយក្នុងរយៈពេលនៃការជំនុំជម្រះក្តី ។

## មាត្រា ១៩

## បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល

១) ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល ព្រមទាំងសមាជិកគ្រួសាររបស់ពួកគេ នឹងទទួលបាននូវបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិ ការលើកលែង និងភាពងាយស្រួលដូចគ្នានឹងភ្នាក់ងារការទូត យោងតាមអនុសញ្ញាទីក្រុងវីយែនឆ្នាំ១៩៦១ ស្តីពីទំនាក់ទំនងការទូត ។

ជាពិសេសពួកគេនឹងទទួលបាន ៖

ក) ភាពជាបុគ្គលមិនអាចរំលោភបំពានបានរួមមានអភ័យឯកសិទ្ធិលើការចាប់ខ្លួនឬឃុំខ្លួន

ខ) អភ័យឯកសិទ្ធិ លើយុត្តាធិការព្រហ្មទណ្ឌ រដ្ឋប្បវេណី និងរដ្ឋបាល ស្របតាមអនុសញ្ញាទីក្រុងវីយែន

គ) ភាពមិនអាចរំលោភបំពានបានចំពោះរាល់ក្រដាសស្នាម និងឯកសារទាំងអស់

ឃ) ការលើកលែងអំពីការរឹតត្បិតផ្នែកអន្តោប្រវេសន៍ និងការចុះបញ្ជីជនបរទេស

ង) អភ័យឯកសិទ្ធិនិងការជួយសម្រួលចំពោះឥវ៉ាន់ផ្ទាល់ខ្លួនដូចគ្នានឹងភ្នាក់ងារការទូត

២) ចៅក្រមអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហព្រះរាជអាជ្ញាអន្តរជាតិ និងអនុប្រធានការិយាល័យរដ្ឋបាល នឹងទទួលបាននូវការលើកលែងពីការយកពន្ធលើប្រាក់បៀវត្ស ប្រាក់បំណាច់ និងប្រាក់ខបត្ថម្ភផ្សេងៗរបស់ពួកគេនៅប្រទេសកម្ពុជា ។

## មាត្រា ២០

## បុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់បុគ្គលិកកម្ពុជានិងអន្តរជាតិ

១) ចៅក្រមសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញានិងបុគ្គលិកកម្ពុជាដទៃទៀតទទួលបានអភ័យឯកសិទ្ធិលើដំណើរការច្បាប់ទាក់ទងនឹងពាក្យសម្តីនិយាយឬសរសេរ និងគ្រប់សកម្មភាពទាំងអស់ដែលពួកគេបានបំពេញក្នុងតួនាទីជាផ្លូវការរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ ។ អភ័យឯកសិទ្ធិនេះនៅតែមានជាបន្តក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។

២) បុគ្គលិកអន្តរជាតិនឹងទទួលបាន ៖

ក) អភ័យឯកសិទ្ធិលើដំណើរការច្បាប់ទាក់ទងនឹងពាក្យសម្តីនិយាយឬសរសេរ និងគ្រប់សកម្មភាពដែលពួកគេបានបំពេញនៅក្នុងតួនាទីជាផ្លូវការរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ ។ អភ័យឯកសិទ្ធិបែបនេះនឹងនៅតែមានជាបន្ត ក្រោយពីពួកគេបញ្ចប់ការងារជាមួយសហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះនិងការិយាល័យ

រដ្ឋបាល ។

ខ) អភ័យឯកសិទ្ធិលើការយកពន្ធលើប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងប្រាក់បំណាច់ផ្សេងៗ ដែលផ្តល់ឲ្យពួកគេដោយអង្គការសហប្រជាជាតិ ។

គ) អភ័យឯកសិទ្ធិលើការរឹតត្បិតខាងអន្តោប្រវេសន៍ ។

ឃ) សិទ្ធិនាំចូលដោយឥតបង់ពន្ធនិងអាករផ្សេងៗ ចំពោះគ្រឿងសង្ហារឹមនិងសម្ភារផ្ទាល់ខ្លួន លើកលែងតែការទូទាត់ចំពោះសេវា នៅពេលដែលទទួលមុខតំណែងជាផ្លូវការលើកទីមួយនៅកម្ពុជា ។

៣) អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាឯកភាពគ្នាថា អភ័យឯកសិទ្ធិដែលផ្តល់ឲ្យដោយច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញទាក់ទងទៅនិងពាក្យសម្តីនិយាយឬសរសេរ និងរាល់សកម្មភាពទាំងអស់ដែលពួកគេបានបំពេញនៅក្នុងតួនាទីជាផ្លូវការរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ នឹងស្ថិតនៅបន្តក្រោយពេលពួកគេឈប់បម្រើការងារជាសហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា អង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ និងការិយាល័យរដ្ឋបាល ។

## មាត្រា ២១

## មេធាវី

១) រាជរដ្ឋាភិបាលមិនត្រូវដាក់មេធាវីរបស់ជនសង្ស័យ ឬជនជាប់ចោទ ដែលត្រូវបានទទួលស្គាល់ដោយអង្គជំនុំជម្រះវិសាមញ្ញ ឲ្យស្ថិតនៅក្រោមវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញតួនាទីដោយសេរីនិងឯករាជ្យរបស់ពួកគេនៅក្រោមកិច្ចព្រមព្រៀងនេះ ។

២) ជាពិសេសមេធាវីនឹងទទួលបានៈ

ក) អភ័យឯកសិទ្ធិលើការចាប់ខ្លួនឬការឃុំខ្លួន និងការរឹបអូសយកសម្ភារផ្ទាល់ខ្លួន

ខ) ភាពមិនអាចរំលោភបំពានបានទៅលើឯកសារទាំងអស់ទាក់ទងនឹងការអនុវត្តន៍មុខងាររបស់ខ្លួន ក្នុងនាមជាមេធាវីរបស់ជនសង្ស័យឬជនជាប់ចោទ ។

គ) អភ័យឯកសិទ្ធិលើយុត្តាធិការព្រហ្មទណ្ឌ ឬរដ្ឋប្បវេណីទាក់ទងនឹងពាក្យសម្តីនិយាយឬសរសេរ និងសកម្មភាពដែលពួកគេបានបំពេញនៅក្នុងតួនាទីផ្លូវការជាមេធាវី ។ អភ័យឯកសិទ្ធិបែបនេះនឹងនៅបន្តផ្តល់ចំពោះពួកគេក្រោយពួកគេបានបញ្ចប់មុខងារជាមេធាវីរបស់ជនសង្ស័យឬជនជាប់ចោទ ។

៣) មេធាវីណាដែលមានសញ្ជាតិខ្មែរឬមិនមែនខ្មែរដែលត្រូវជួលឬចាត់តាំងឲ្យធ្វើការជាមួយជនសង្ស័យ ឬជនជាប់ចោទក្នុងការការពារកូនក្តីរបស់ខ្លួនត្រូវអនុវត្តតាមកិច្ចព្រមព្រៀងនេះ ច្បាប់កម្ពុជាស្តីពីលក្ខន្តិកៈមេធាវី ស្តង់ដារនិងសីលធម៌នៃវិជ្ជាជីវៈច្បាប់ដែលគេទទួលស្គាល់ ។

## មាត្រា ២២

## សាក្សី និង អ្នកជំនាញការ

សាក្សីនិងអ្នកជំនាញការដែលមកបង្ហាញខ្លួនតាមដីកាឬការស្នើសុំរបស់ចៅក្រម សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញា នឹងមិនត្រូវចោទប្រកាន់ឃុំខ្លួន ឬជាកម្មវត្ថុនៃការរឹតត្បិតណាមួយផ្សេងទៀតលើសេរីភាពរបស់ពួកគេដោយអាជ្ញាធរកម្ពុជាឡើយ ។ អាជ្ញាធរកម្ពុជាមិនត្រូវដាក់ពួកគេឲ្យនៅក្រោមវិធានការណាមួយដែលអាចប៉ះពាល់ដល់ការបំពេញមុខងាររបស់ពួកគេដោយសេរីនិងឯករាជ្យ ។

## មាត្រា ២៣

## ការការពារជនរងគ្រោះនិងសាក្សី

សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះវិសាមញ្ញ ត្រូវផ្តល់ការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារបែបនេះរួមមាន ហើយមិនកំណត់ត្រឹមតែ ការអនុវត្តន៍ដំណើការសាកសួរជាសម្ងាត់ និងការការពារអត្តសញ្ញាណរបស់ជនរងគ្រោះឬសាក្សីនោះទេ ។

## មាត្រា ២៤

## សន្តិសុខ សុវត្ថិភាព និងការការពារបុគ្គលដែលមានចែងក្នុងកិច្ចព្រមព្រៀងទាំងនេះ

រាជរដ្ឋាភិបាលនឹងចាត់វិធានការសមស្របនិងមានប្រសិទ្ធភាពដែលចាំបាច់ដើម្បីធានានូវសន្តិសុខ សុវត្ថិភាពនិងការការពារចំពោះបុគ្គលដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលឯកភាពគ្នាថា រដ្ឋាភិបាលទទួលខុសត្រូវលើសុវត្ថិភាពរបស់ជនជាប់ចោទទាំងឡាយ ដោយមិន

គិតថាពួកគេបង្ហាញខ្លួនដោយស្ម័គ្រចិត្តចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញបុមួយក៏ត្រូវចាប់ខ្លួននោះឡើយ ។

## មាត្រា ២៥

## កាតព្វកិច្ចជួយចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង អង្គជំនុំជម្រះវិសាមញ្ញ

រាជរដ្ឋាភិបាលនឹងអនុវត្តដោយគ្មានការពន្យាពេលតាមការស្នើសុំជំនួយរបស់សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា ឬអង្គជំនុំជម្រះវិសាមញ្ញ ឬក៏បញ្ជារបស់ពួកគេរួមមាន ប៉ុន្តែមិនមែនត្រឹមតែៈ

ក) រកអត្តសញ្ញាណនិងទីកន្លែងរបស់បុគ្គលណាមួយ

ខ) ផ្តល់ឯកសារ

គ) ចាប់ខ្លួនឬឃុំខ្លួនបុគ្គលណាមួយ

ឃ) បញ្ជូនជនជាប់ចោទមកកាន់អង្គជំនុំជម្រះវិសាមញ្ញ

## មាត្រា ២៦

## ភាសា

១) ភាសាដែលប្រើប្រាស់ជាផ្លូវការក្នុងការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ និងអង្គបុរេជំនុំជម្រះ គឺភាសាខ្មែរ ។

២) ភាសាការងារជាផ្លូវការរបស់អង្គជំនុំជម្រះវិសាមញ្ញ និងអង្គបុរេជំនុំជម្រះ គឺភាសាខ្មែរ អង់គ្លេស និង បារាំង ។

៣) ការបកប្រែឯកសារសាធារណៈ និងការបកប្រែផ្ទាល់មាត់ពេលសវនាការសាធារណៈជាភាសារុស្ស៊ី អាចផ្តល់ឲ្យអាស្រ័យលើការសម្រេចនិងចំណាយរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងលក្ខខណ្ឌដែលមិនធ្វើឲ្យរំខានដល់ដំណើរការកាត់សេចក្តីនៅមុខអង្គជំនុំជម្រះវិសាមញ្ញ ។

## មាត្រា ២៧

## ការរៀបចំតាមសភាពជាក់ស្តែង

១) ដើម្បីឲ្យមានប្រសិទ្ធភាពនិងសន្សំសំចៃផងនៅក្នុង កិច្ចប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញ គេត្រូវរៀបចំបង្កើតអង្គជំនុំជម្រះតាមរបៀបជាដំណាក់ៗ ទៅតាមលំដាប់លំដោយនីតិវិធី ។

២) នៅក្នុងដំណាក់កាលដំបូងនៃប្រតិបត្តិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ចៅក្រម សហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា នឹងត្រូវបានតែងតាំងរួមជាមួយនឹងបុគ្គលិកដែលត្រូវធ្វើការជាមួយចៅក្រមស៊ើបអង្កេតនិងព្រះរាជអាជ្ញាហើយដំណើរការស៊ើបអង្កេតនិងចោទប្រកាន់ត្រូវចាប់ផ្តើម ។

៣) ដំណើរការជំនុំជម្រះក្តីអ្នកដែលត្រូវបានឃុំឃាំងរួចហើយ ត្រូវដំណើរការទន្ទឹមគ្នានឹងការស៊ើបអង្កេតលើជនដទៃទៀតដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ។

៤) នៅពេលបញ្ចប់ការស៊ើបអង្កេតលើជនជាប់សង្ស័យថាបានប្រព្រឹត្តឧក្រិដ្ឋកម្មដែលឋិតនៅក្រោមយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ហើយដីការចាប់ខ្លួននឹងត្រូវបញ្ជូនទៅរាជរដ្ឋាភិបាលដើម្បីអនុវត្តការចាប់ខ្លួន ។

៥) នៅពេលដែលរាជរដ្ឋាភិបាលចាប់ខ្លួនជនដែលត្រូវចោទប្រកាន់ដែលស្ថិតនៅក្នុងទឹកដីកម្ពុជា ហើយអង្គជំនុំជម្រះវិសាមញ្ញនឹងត្រូវដំណើរការទាំងស្រុង ហើយចៅក្រមតុលាការកំពូលត្រូវចាប់ផ្តើមបម្រើការនៅពេលទទួលរឿងក្តីរបស់ខ្លួនហើយនោះ ។ ចៅក្រមនៃអង្គបុរេជំនុំជម្រះត្រូវបម្រើការតែនៅពេលដែលត្រូវការសេវារបស់ខ្លួនតែប៉ុណ្ណោះ ។

## មាត្រា ២៨

## ការដកខ្លួនចេញពីកិច្ចសហប្រតិបត្តិការ

ប្រសិនបើរាជរដ្ឋាភិបាលផ្លាស់ប្តូររចនាសម្ព័ន្ធឬការរៀបចំអង្គជំនុំជម្រះវិសាមញ្ញ ឬក៏ធ្វើយ៉ាងណាអោយអង្គជំនុំជម្រះដំណើរការតាមរបៀបណាមួយដែលមិនសមស្របជាមួយខ្លឹមសារនៃកិច្ចព្រមព្រៀងនេះ អង្គការសហប្រជាជាតិរក្សាសិទ្ធិផ្អាកជំនួយឧបត្ថម្ភជាហិរញ្ញវត្ថុ ឬជាអ្វីផ្សេងទៀតដែលបានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ។

## មាត្រា ២៩

## ការដោះស្រាយជម្លោះ

ជម្លោះណាមួយរវាងភាគីទាំងសងខាងទាក់ទងនឹងការបកស្រាយឬអនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវដោះស្រាយតាមការចរចាឬដំណោះស្រាយណាផ្សេងទៀតដែលឯកភាពគ្នាទៅវិញទៅមក ។

## មាត្រា ៣០

### ការអនុម័ត

ដើម្បីឲ្យភាគីទាំងពីរមានកាតព្វកិច្ចគតិយុត្តិ កិច្ចព្រមព្រៀងនេះត្រូវអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ និងផ្ដល់សច្ចាប័នដោយកម្ពុជា ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវខិតខំប្រឹងប្រែងឲ្យបានសច្ចាប័ននេះក្នុងកាលបរិច្ឆេទដ៏ឆាប់បំផុតដែលអាចធ្វើទៅបាន ។

### មាត្រា ៣១

### ការអនុវត្តនៅក្នុងប្រទេសកម្ពុជា

កិច្ចព្រមព្រៀងនេះត្រូវអនុវត្តដូចជាច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាក្រោយពីទទួលសច្ចាប័នសមស្របតាមច្បាប់ផ្ទៃក្នុងរបស់ព្រះរាជាណាចក្រកម្ពុជា ស្ដីពីសមត្ថកិច្ចក្នុងការចុះសន្ធិសញ្ញា ។

### មាត្រា ៣២

### ការចូលជាធរមាន

កិច្ចព្រមព្រៀងនេះចូលជាធរមាននៅថ្ងៃបន្ទាប់ពីភាគីទាំងពីរជូនដំណឹងប្រាប់គ្នាទៅវិញទៅមកជាលាយលក្ខណ៍អក្សរថា តម្រូវការសម្រាប់ការចូលជាធរមានតាមផ្លូវច្បាប់ត្រូវបានបំពេញរួចហើយ ។

ធ្វើនៅ [ទីកន្លែង] នៅ [ថ្ងៃ.ខែ] ឆ្នាំ២០០៣ ជាពីរច្បាប់ ជាភាសាអង់គ្លេស ។

ភាគីរាជរដ្ឋាភិបាលកម្ពុជា ភាគីអង្គការសហប្រជាជាតិ

***បកប្រែនិងពិនិត្យកែសម្រួលក្រៅផ្លូវការដោយ ស្វ ប៊ុនស៊ូ***



លោក ហេន ខូវែល ឯកឧត្តម ឌឹម យិនទៀង

## សេចក្ដីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

**ការសរសេរអត្ថបទនេះមានសារសំខាន់÷**

◆ ចូលរួមជាចំណែកមួយនៃប្រវត្តិសាស្ត្រ ទុកសម្រាប់ក្មេងៗជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំដោះអារម្មណ៍ ដោយយកហេតុការណ៍សេចក្ដីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងបានជាថ្មីម្ដងទៀតក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

សូមអរគុណ!

## ពាក្យស្លោកខ្មែរក្រហម

**◆ ដរាបណាក៏ត្រូវបម្រុងជានិច្ច ផ្ដាច់ចិត្តប្រឆាំងនឹងសតិអារម្មណ៍ និងការប្រព្រឹត្តដែលមានមហន្តរាយ ដើម្បីការពារគោលការណ៍របស់បក្ស ដើម្បីពង្រីកឯកភាពសមូហភាពរបស់បក្ស ចំណងរវាងបក្សនិងមហាជន។**

***(ដកស្រង់ពីសៀវភៅកំណត់ហេតុ លេខ០១៨)***

# ការបោះជំហានដ៏សំខាន់មួយ

## សេចក្តីសង្ខេបទៅលើសេចក្តីព្រាងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា

សេចក្តីព្រាងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិ ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៣ បង្ហាញនូវការបោះជំហានដ៏សំខាន់មួយឆ្ពោះទៅបង្កើតតុលាការ ដើម្បីកាត់សេចក្តីអតីតមេដឹកនាំខ្មែរក្រហម ។ ដូចនេះ សេចក្តីព្រាងនេះបង្ហាញនូវការរីកចម្រើនដ៏សំខាន់ឆ្ពោះទៅសម្រេចគោលបំណងដាក់ឲ្យទទួលខុសត្រូវចំពោះបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យ ។

ជនរងគ្រោះនៃរបបខ្មែរក្រហមបានរង់ចាំយុត្តិធម៌អស់ជាង២៨ឆ្នាំមកហើយ ចំណែកឯមេគំនិតបង្កើតភេរវកម្មវិញ ដូចជា សុន សេន និង ប៉ុល ពត ជាដើម បានស្លាប់ទៅដោយគ្មានការវិនិច្ឆ័យទោស ។ ជនសង្ស័យសំខាន់មួយចំនួនទៀតសព្វថ្ងៃនេះរស់នៅដោយសុខស្រួលនៅក្នុងភូមិគ្រឹះដ៏ស្កឹមស្កៃ ក្នុងខណៈដែលក្រុមគ្រួសាររបស់ជនរងគ្រោះប្រមាណពីរលាននាក់ចេះតែបន្តរង់ចាំដល់ថ្ងៃដែលគេយកច្បាប់ជាមូលដ្ឋាននិងសាកលបំផុតមកអនុវត្ត ។

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងមិនមែនជាលិខិតូបករណ៍ល្អឥតខ្ចោះសម្រាប់ដោះស្រាយបញ្ហាឧក្រិដ្ឋកម្មប្រព្រឹត្តឡើងដោយរបប ប៉ុល ពត នោះទេ ។ កិច្ចព្រមព្រៀងនេះផ្ទុកនូវភាពខ្វះចន្លោះជាច្រើន ហើយចាំបាច់តម្រូវឲ្យមានការផ្តោតអារម្មណ៍រួមគ្នា ។ ខាងក្រោមនេះ គឺជាចំណុចសំខាន់ៗមួយចំនួនដែលតម្រូវឲ្យមានការកែប្រែ ឬបំពេញបន្ថែម÷

មាត្រា២មិនបានបញ្ជាក់ច្បាស់អំពីទំនាក់ទំនងរវាងសេចក្តីព្រាងកិច្ចព្រមព្រៀងជាមួយនឹងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញឡើយ ។

មាត្រា៧មិនបាននិយាយអំពីរបៀបដែលតុលាការនេះដំណើរការទៅយ៉ាងដូចម្តេចឡើយ ប្រសិនបើគ្មានមតិភាគច្រើនលើសលប់ទេនោះ ។ ស៊ូហ្សាណា លីនតុន បានទាញហេតុផលត្រឹមត្រូវថា ការសម្រេចទៅលើដែនសមត្ថកិច្ចរបស់តុលាការទៅលើករណី អៀង សារី អាចមានបញ្ហានេះ ។

មាត្រា៩នៃកិច្ចព្រមព្រៀងហាក់ដូចជារំលោភទៅលើគោលការណ៍ nullem crimen sine lege “គ្មានបទល្មើសបើគ្មានច្បាប់ចែង ហើយបើគ្មានច្បាប់ចែងក៏គ្មានការផ្តន្ទាទោសដែរ” ដែលបានលើកឡើងនូវនិយមន័យនៃពាក្យ “ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ” ចេញពីច្បាប់លក្ខន្តិកៈតុលាការព្រហ្មទណ្ឌអន្តរជាតិ ទោះបីជាមាត្រា៩បាននិយាយយោងដល់និយមន័យនៃបទល្មើសដដែលនេះ ដែលចែងនៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះដែលមិនបានរំលោភទៅលើគោលការណ៍ច្បាប់ nullem crimen principle នេះក៏ដោយ ។

កិច្ចព្រមព្រៀងនេះមិនបានបញ្ជាក់ឲ្យបានច្បាស់អំពីទំហំនៃការការពារក្តីសម្រាប់ចុងចោទទេ ។

កិច្ចព្រមព្រៀងមិនបានបញ្ជាក់ឲ្យបានច្បាស់ថាតើតុលាការនេះនឹងត្រូវធ្វើការជាមួយមន្ត្រី យុត្តិធម៌កម្ពុជា និងអង្គការអន្តរជាតិនានាចំពោះបញ្ហាដូចជាការការពារសាក្សីនិងការកសាងសមត្ថភាពយ៉ាងដូចម្តេចនោះទេ ។

រីឯវិធាននៃភស្តុតាងនិងនីតិវិធីនៅក្នុងដំណើរការជំនុំជម្រះក៏កិច្ចព្រមព្រៀងនេះ មិនទាន់បញ្ជាក់ឲ្យបានច្បាស់លាស់ដែរ ។

រាល់បញ្ហាទាំងនេះសុទ្ធតែអាចចាត់ការបាន ហើយបញ្ហានេះមិនអាចរារាំងដល់ការឈានទៅបង្កើតតុលាការដែលបានគ្រោងទុកនោះទេ ។ ធ្វើការពិចារណាទៅឃើញថា បញ្ហាទាំងនេះមិនមានកម្លាំងគ្រប់គ្រាន់ក្នុងការរារាំងមិនឲ្យមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តសេចក្តីព្រាងកិច្ចព្រមព្រៀងនេះទេ ។

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាចាំបាច់ត្រូវតែធ្វើការជិតស្និទ្ធជាមួយគ្នាដើម្បីដោះស្រាយបញ្ហានេះនិងបញ្ហាសំខាន់ៗផ្សេងៗទៀត ក្រោយពេលដែលកិច្ចព្រមព្រៀង

នេះត្រូវបានសម្រេចជាលើកចុងក្រោយ ហើយឆាប់ៗតាមតែអាចធ្វើទៅបាន ភាគីទាំងពីរគួរតែសន្យាដាក់លក្ខខណ្ឌជាមួយគ្នាថានឹងរួមគ្នាដោយសុទ្ធចិត្តនៅពេលមានតុលាការ ។ ប្រសិនបើគ្មានកិច្ចសហប្រតិបត្តិការពីសំណាក់រាជរដ្ឋាភិបាល ហើយការមិនធ្វើសហប្រតិបត្តិការនេះធ្វើឲ្យប្រែប្រួលដល់រចនាសម្ព័ន្ធការចាត់តាំងឬដំណើរការតុលាការដែលមិនស្របទៅតាមកិច្ចសន្យាដែលមានចែងនៅក្នុងសេចក្ដីព្រាងកិច្ចព្រមព្រៀងដូចជាបទបញ្ញត្តិស្ដីអំពីការការពារសាក្សី សិទ្ធិចុងចោទនិងកិច្ចសហប្រត្តិ-បត្តិការរវាងមន្ត្រីមូលដ្ឋានជាមួយតុលាការនោះ អង្គការសហប្រជាជាតិអាចរក្សាសិទ្ធិក្នុងការដកថយចេញពីដំណើរការនៃតុលាការនេះ ដោយយោងទៅលើមាត្រា២៨ ។

មានអ្នកវិភាគមួយចំនួនមិនយល់ស្របចំពោះអនុសាសន៍កន្លងមក ដោយអះអាងថាសេចក្ដីព្រាងកិច្ចព្រមព្រៀងមិនបានធានាថាតុលាការនេះមានបទដ្ឋានយុត្តិធម៌អន្តរជាតិឡើយ ។ អង្គការអាំណាស្ទីអ៊ិនធ័រណាស់ស្យូណាល់ Amnesty International ឲ្យហេតុផលថា កិច្ចព្រមព្រៀងនេះមាន “ភាពខ្វះចន្លោះធ្ងន់ធ្ងរ...” ដែលសបញ្ជាក់ឲ្យឃើញនូវ “ការឃ្លាតឆ្ងាយពីច្បាប់អន្តរជាតិនិងបទដ្ឋានអន្តរជាតិបច្ចុប្បន្ន” ហើយថា “ភាពខ្វះចន្លោះនៅក្នុងសេចក្ដីព្រាងនេះមានលក្ខណៈធ្ងន់ធ្ងរ...រហូតនាំឲ្យអង្គការអាំណាស្ទីអ៊ិនធ័រណាស់ស្យូណាល់ ជំទាស់មិនឲ្យអង្គការសហប្រជាជាតិចុះហត្ថលេខាបើគ្មានការកែសម្រួលឡើងវិញទៅលើចំណុចសំខាន់ៗទាំងនោះ» ។

ការរិះគន់នេះនិងការរិះគន់ផ្សេងៗទៀតគឺសំអាងមួយផ្នែកទៅលើបញ្ហាជាក់លាក់មួយចំនួនដែលលើកឡើងខាងលើ ។ ក៏ប៉ុន្តែការរិះគន់ទាំងនេះហាក់ដូចជាមានទំនោរទៅរកការព្រួយបារម្ភទៅលើបញ្ហាថាតើអ្នកណា “គ្រប់គ្រង” តុលាការនេះ និងការមន្ទិលសង្ស័យទៅលើរដ្ឋាភិបាលកម្ពុជានិងប្រព័ន្ធតុលាការកម្ពុជា ។ ប្រេដ អាដ្រាម ប្រធានផ្នែកឃ្លាំមើលសិទ្ធិមនុស្សនៅអាស៊ី បានសម្ដែងនូវការព្រួយបារម្ភរបស់គាត់ទៅលើសេចក្ដីព្រាងនៃកិច្ចព្រមព្រៀងនេះថា “សម្ដេច ហ៊ុន សែន ច្បាស់ជាសប្បាយចិត្ត ។ សម្ដេចអាចគ្រប់គ្រងអ្វីៗទាំងអស់ ។ គ្មានចៅក្រមឬព្រះរាជអាជ្ញាខ្មែរណាម្នាក់ហ៊ានធ្វើអ្វីដោយគ្មានការអនុញ្ញាតពីសម្ដេចឡើយ» ។ អង្គការអាំណាស្ទីអ៊ិនធ័រណាស់ស្យូ-ណាល់ បន្ថែមទៀតថា “ប្រព័ន្ធតុលាការកម្ពុជាមានភាពទន់ខ្សោយហើយស្ថិតនៅក្រោមសម្ពាធនយោបាយ ជាពិសេសនៅក្នុងរឿងក្ដីសំខាន់ៗ ។ ដូចនេះប្រព័ន្ធ តុលាការបច្ចុប្បន្នមិនអាចធានាថា ការជំនុំជម្រះក្ដីដំណើរការទៅនៅក្នុងលក្ខណៈមួយដែលស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិឡើយ» ។

ជាការសមស្របក្នុងការធ្វើឲ្យសកម្មភាពរបស់មន្ត្រីកម្ពុជា (និងបរទេស) ដឹងឮជាសាធារណៈ ហើយការព្រួយបារម្ភអំពើពុករលួយ ឬភាពលម្អៀងមិនមានមូលដ្ឋាន ។ ការដាក់ចេញនូវការធានាដំណើរការនីតិវិធីគឺជាការចាំបាច់ដូចដែលអង្គការសិទ្ធិមនុស្សសំខាន់ៗសង្កត់ធ្ងន់ទៅលើបញ្ហានេះ ។ ក៏ប៉ុន្តែអ្នករិះគន់រាជរដ្ឋាភិបាលគួរតែជៀសវាងសន្មតជាមុនថា ចៅក្រមនិងមន្ត្រីខ្មែរមិនអាចទុកចិត្តបាន ។ ដោយប្រកាសថាតុលាការកម្ពុជាមិនអាចជឿជាក់បាន ហើយចាត់វិធានការតាមតែអាចធ្វើទៅបានក្នុងការកាត់បន្ថយកិច្ចប្រតិបត្តិការរបស់តុលាការឲ្យនៅក្នុងកម្រិតតិចបំផុត អ្នករិះគន់ទៅលើតុលាការដែលស្នើឡើងនោះអាចនឹងបដិសេធមិនផ្ដល់ឱកាសដល់អ្នកចូលរួមមកពីភាគីរាជរដ្ឋាភិបាលកម្ពុជា ចូលរួមប្រកបដោយអត្ថន័យចំពោះបុព្វហេតុស្វែងរកយុត្តិធម៌ ។

តុលាការខ្មែរក្រហមមួយផ្នែកគឺអំពីអតីតកាល មួយផ្នែកទៀតគឺដើម្បីយុត្តិធម៌នៃអំពើគួរឲ្យព្រឺព្រួចដែលប្រព្រឹត្តឡើងដោយរបប ប៉ុល ពត ។ ការចូលរួមដ៏ខ្លាំងពីបរទេសនៅក្នុងដំណើរការជម្រះក្ដីនេះមានសារសំខាន់ណាស់ក្នុងការធានាថាយុត្តិធម៌ត្រូវតែសម្រេចបាន និងក្នុងការកាត់បន្ថយដល់ការព្រួយបារម្ភទៅលើភាពខុសឆ្គងនៅក្នុងប្រព័ន្ធតុលាការ ។ ប៉ុន្តែដំណើរការតុលាការនេះក៏ទាក់ទងដល់អនាគតនិងការកសាងនីតិរដ្ឋនៅកម្ពុជាដែរ ។ ប្រព័ន្ធច្បាប់កម្ពុជាចង់ឲ្យល្អឬអាក្រក់យ៉ាងណាៗ នោះគឺអាស្រ័យទៅលើកម្ពុជាខ្លួនឯងផ្ទាល់ ។ កាន់តែគិតថាតុលាការនេះមានបរទេសច្រើនជាង គឺឱកាសមានកាន់តែតិចសម្រាប់អ្នកធ្វើការនៅក្នុងស្រុក ក្នុងការបង្កើតនូវការទុកចិត្តសម្រាប់ខ្លួនឯងនិងធានាភាពជឿជាក់ពីសាធារណជន ។ ឧទាហរណ៍ តុលាការនៅទីក្រុងឡាអេអាចរកយុត្តិធម៌ចំពោះអំពើដែលប្រព្រឹត្តឡើង

ដោយខ្មែរក្រហម ប៉ុន្តែគេអាចអះអាងទាំងស្រុងថា ប្រព័ន្ធតុលាការកម្ពុជាមិនមានលក្ខណៈសម្បត្តិសមស្របសម្រាប់វិនិច្ឆ័យក្តីចំពោះបទល្មើសដែលកើតឡើងនៅលើទឹកដីរបស់ខ្លួនរវាងឆ្នាំ ១៩៧៥-១៩៧៩ ។ ច្បាប់អន្តរជាតិអាចឈ្នះនៅក្នុងតុលាការនៅភីសជាឡេស ប៉ុន្តែប្រជាជនកម្ពុជាមានជំនឿតិចតួចណាស់ទៅលើអង្គច្បាប់នោះ ។

ក្រោយពីស្ថិតក្នុងបរិបទបែបនេះចំនួន២៤ឆ្នាំមក ប្រជាជនកម្ពុជាចាំបាច់ត្រូវតែឃើញរដ្ឋាភិបាលរបស់ខ្លួនមានសមត្ថភាពអាចគ្រប់គ្រងយុត្តិធម៌ពិតប្រាកដ ។ អ្នកវិនិយោគទុនបរទេសដែលសន្យាថានឹងជួយជ្រោមជ្រែងដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជាក៏ត្រូវការសំអាងដែលថា ប្រព័ន្ធតុលាការកម្ពុជាកំពុងតែមានសមត្ថភាពនិងភាពគួរឲ្យទុកចិត្តបានឡើងវិញហើយ ។ ដើម្បីឲ្យនីតិរដ្ឋចាក់ឫសយ៉ាងរឹងមាំនៅកម្ពុជា ហើយដើម្បីសន្តិសុខរបស់មនុស្សជាតិកាន់តែប្រសើរឡើងភាពជឿជាក់ជាសាធារណៈនិងជាអន្តរជាតិនៅក្នុងប្រព័ន្ធច្បាប់គឺមានសារសំខាន់ណាស់ ។ គោលដៅនេះត្រូវតែធ្វើឲ្យមានតុល្យភាពសមស្របជាមួយគោលបំណងចំពោះមុខក្នុងការធានាផ្តល់នូវយុត្តិធម៌ដែលអាចជឿជាក់បានចំពោះអំពើឃោរឃៅប្រព្រឹត្តឡើងដោយកម្ពុជាប្រជាធិបតេយ្យ ។ ទាំងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាសុទ្ធតែមានតួនាទីដែលមិនអាចខ្វះបានក្នុងការត្រួតពិនិត្យដំណើរការស្វែងរកយុត្តិធម៌នៅកម្ពុជា ។

វាមិនមែនជាគោលដៅទេក្នុងការកំណត់ថាអ្វីទៅដែលបង្កើតបានជាការបែងចែករវាងតួនាទីរបស់កម្ពុជានិងអង្គការសហប្រជាជាតិ នៅក្នុងដំណើរការទទួលខុសត្រូវចំពោះមុខច្បាប់ ។ ដោយតម្រូវឲ្យមានការសម្រេចដោយយកមតិភាគច្រើនលើសលប់ ជ្រើសរើសបុគ្គលិកជាអ្នកស៊ើបអង្កេត និងព្រះរាជអាជ្ញាក្នុងស្រុកនិងអន្តរជាតិ និងផ្តល់សិទ្ធិដល់អង្គការសហប្រជាជាតិក្នុងការដកខ្លួនថយមិនគាំទ្រប្រសិនបើរាជរដ្ឋាភិបាលខកខានក្នុងការធ្វើកិច្ចសហប្រតិបត្តិការ (មាត្រា២៨) សេចក្តីព្រាងនេះរួមមានបទប្បញ្ញត្តិសំខាន់ៗដែលគាត់តែងឡើងដើម្បីធានាថាតុលាការនេះត្រូវតាមគំរូអន្តរជាតិ ។ ដោយសម្រេចឲ្យកម្ពុជាមានតួនាទីធំបែបនេះ កិច្ចព្រមព្រៀងនេះក៏នឹងផ្តល់ឱកាសដល់រាជរដ្ឋាភិបាលក្នុងការបង្ហាញច្បាស់ថា រាជរដ្ឋាភិបាលកម្ពុជាអាចជឿទុកចិត្តបានទាក់ទងដល់បញ្ហាច្បាប់និងយុត្តិធម៌ ។ ក្រោយពីមានការចរចាជាច្រើនឆ្នាំមក នេះគឺជាបញ្ហាដែលភាគីទាំងពីរមានបញ្ហាជាមួយគ្នា ហើយប្រសិនបើសេចក្តីព្រាងកិច្ចព្រមព្រៀងត្រូវបានទាត់ចោល ឱកាសក្នុងការកាត់សេចក្តីមេដឹកនាំខ្មែរក្រហមដែលមានវ័យកាន់តែចាស់ហើយនោះនឹងមិនអាចមានម្តងទៀតទេ ។

អ្នករិះគន់ខ្លាំងបំផុតទៅលើសេចក្តីព្រាងកិច្ចព្រមព្រៀងនេះបានទទូចថា មហាសន្និបាតអង្គការសហប្រជាជាតិគួរតែកុំចុះហត្ថលេខាទៅលើសេចក្តីព្រាងនេះ ប្រសិនបើគ្មានការកែប្រែលើចំណុចសំខាន់ៗនោះទេ ។ ដោយមានការព្រួយបារម្ភថាតុលាការនេះនឹងគ្មានភាពយុត្តិធម៌ និងជាការធ្វើឲ្យខូចដល់កេរ្តិ៍ឈ្មោះរបស់អង្គការសហប្រជាជាតិ អ្នករិះគន់ទាំងនោះចង់ឃើញការចរចាបន្តទៀត ឬប្រហែលជាត្រូវបញ្ចប់នៅត្រឹមនេះក៏ថាបាន ។ អ្នករិះគន់អះអាងដោយមានហេតុផលថា គ្រោះថ្នាក់កើតចេញពីការទទួលយកនូវសេចក្តីព្រាងនេះគឺថា រាជរដ្ឋាភិបាលកម្ពុជានឹងមិនធ្វើឲ្យតុលាការសម្រេចបាននូវគំរូយុត្តិធម៌អន្តរជាតិមួយបានឡើយ ហើយប្រហែលជារហូតដល់នាំដល់ការដកខ្លួនថយរបស់អង្គការសហប្រជាជាតិថែមទៀតផង ។

ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាសម្រេចថានឹងបំពានទៅលើទស្សនៈមតិអន្តរជាតិនិងស្មារតីនៃកិច្ចព្រមព្រៀងនេះលទ្ធផលគឺច្បាស់ជាចេញតាមផ្លូវដែលលើកឡើងនេះមិនខាន ។ ក៏ប៉ុន្តែបើប្រៀបធៀបរវាងដំណាក់កាលនៃការចរចាដែលនឹងបន្តទៅមុខទៀតជាមួយស្ថានភាពជាក់ស្តែងដែលចុងចោទស្ថិតនៅក្នុងវ័យកាន់តែចាស់ទៅហើយនោះ ការបដិសេធនូវសេចក្តីព្រាងនេះគឺពិតជាមានការប្រថុយប្រថានដោយមានន័យថាការចរចានឹងមិនអាចមានជារៀងរហូត ។ លទ្ធផលចេញមកគឺធ្វើឲ្យបទឧក្រិដ្ឋទាំងឡាយប្រព្រឹត្តឡើងដោយរបបកម្ពុជាប្រជាធិបតេយ្យនោះដែលមិនមានការជំនុំជម្រះក្តីនោះនឹងក្លាយទៅជាស្លាកស្នាមប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អង្គការសហប្រជាជាតិ ហើយវានឹងឆ្កឹះដំបៅចាស់របស់កម្ពុជានាពេលអនាគត ។

**ចន ឆរនីអារី**

# ផ្លូវដែលត្រូវប្រកាន់យកក្នុងពេលខាងមុខ

## ការសង្កេតទៅលើសេចក្ដីព្រាងនៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្ដីក្រោមច្បាប់កម្ពុជាទៅលើឧក្រិដ្ឋកម្មប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ

មុនពេលចាប់ផ្ដើមវាយតម្លៃទៅលើកិច្ចព្រមព្រៀងនេះ ខ្ញុំត្រូវតែសារភាពថាក្នុងនាមជាអ្នកសង្កេតការណ៍អន្តរជាតិម្នាក់ ខ្ញុំពិបាកសម្រេចចិត្តថាតើត្រូវសប្បាយចិត្តជំនួសប្រជាជនកម្ពុជា ដែលនៅទីបញ្ចប់មានការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ចំពោះការបំផ្លិចបំផ្លាញ និងការឈឺចាប់ដ៏ធ្ងន់ធ្ងរ ប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប៉ុក៏មិនស្រួលក្នុងចិត្តចំពោះការសម្របសម្រួលរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ។ ប៉ុន្តែដោយសារថា ការសម្របសម្រួលនេះគឺជាអ្វីដែលបានព្រមព្រៀងគ្នាក្រោយពីមានបញ្ហាធំៗមក ផ្លូវដែលត្រូវប្រកាន់យកនាពេលខាងមុខគឺធ្វើយ៉ាងណាធ្វើកិច្ចការនេះឲ្យបានល្អបំផុត ។ ដូច្នេះខ្ញុំផ្ដល់ការសង្កេតនេះដោយចេតនាស្មោះអស់ពីចិត្ត ។

ភាគីទាំងសងខាងរួមជាមួយនឹងភាគីជាសាមីត្រូវធ្វើអ្វីតាមតែអាចធ្វើទៅបាន ដើម្បីធានាឲ្យប្រាកដថាយន្តការនៃការទទួលខុសត្រូវចំពោះមុខច្បាប់នេះនឹងនាំមកនូវយុត្តិធម៌សម្រាប់កម្ពុជា និងប្រើប្រាស់ឱកាសជំនុំជម្រះក្ដីដើម្បីអភិវឌ្ឍយុត្តិសាស្ត្របន្ថែមសម្រាប់ឆ្លើយតបទៅនឹងសេចក្ដីត្រូវការក្នុងការជួលជុលការខូចខាតនៅក្នុងសង្គម ។ សេចក្ដីសង្ឃឹមទាំងឡាយត្រូវតែមានលក្ខណៈសមរម្យនិងអាចសម្រេចបាន ។ ការគិតដោយក្ដីប្រាថ្នាទាំងអស់នៅលើលោកនេះ មិនសុទ្ធតែនាំឲ្យការវិនិច្ឆ័យទោសមេដឹកនាំមួយក្ដាប់តូចដែលមានវ័យកាន់តែចាស់ ដើម្បីផ្ដល់នូវការជួលជុលមួយរំពេចចំពោះការខូចខាតដែលកំពុងតែបន្តបំផ្លិចបំផ្លាញសង្គមកម្ពុជានោះទេ ។ សង្គមស៊ីវិលមានតួនាទីសំខាន់ណាស់ក្នុងការផ្ដល់នូវការគាំទ្រចំពោះកម្មវិធីអង្គជំនុំជម្រះវិសាមញ្ញ ក៏ប៉ុន្តែនៅពេលទន្ទឹមគ្នានេះ ក៏ត្រូវតែធ្វើជាអ្នកចាំតាមដានមើលដំណើរការអង្គជំនុំជម្រះនេះដែរ ។ មិនតែប៉ុណ្ណោះ សង្គមស៊ីវិលមានតួនាទីសំខាន់មួយទៀត គឺដាក់សម្ពាធទៅលើរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ឲ្យរៀបចំ និងអភិវឌ្ឍកម្មវិធីចាំបាច់នានាដូចជា ការការពារដល់សាក្សី ការយកចិត្តទុកដាក់មើលថែទាំខាងរោគវិកល ការពិភាក្សានិងការផ្ដល់ព័ត៌មានជាសាធារណៈ ។

និយាយរួម កិច្ចព្រមព្រៀងនេះគឺជាការរីកចម្រើនមួយទៅលើអត្ថបទព្រាងអនុស្សរណៈនៃការយោគយល់គ្នាដែលធ្វើឡើងកន្លងទៅ ។ ប៉ុន្តែ បញ្ហាសំខាន់នៅជ្រៅៗនៅឡើយ ដូចជាសុចរិតភាពនៃដំណើរការរឿងក្ដីដែលបណ្ដាលមកពីទស្សនាទានបង្កើតអង្គជំនុំជម្រះជាលក្ខណៈចម្រុះជាតិសាសន៍ គ្រប់គ្រងដោយបុគ្គលិកខ្មែរដែលធ្វើឲ្យការសម្រេចចិត្តនានាផ្អែកលើមូលដ្ឋានបោះឆ្នោតដែលមានកម្រិតមិនប្រក្រតីខ្ពស់ ដោយមានសហចៅក្រមពីររូបនិងសហព្រះរាជអាជ្ញាពីររូបធ្វើការនៅការិយាល័យពីរផ្សេងគ្នា ហើយនៅពេលមានការខ្វែងយោបល់គ្នាទៅលើការស៊ើបអង្កេតនិងការចោទប្រកាន់ គឺត្រូវដោះស្រាយដោយចៅក្រមជំនុំ ។ ច្បាប់ស្ដីអំពីនីតិវិធីព្រហ្មទណ្ឌនៅតែបន្តអនុវត្តនៅឡើយ ។ មិនទាន់បញ្ញត្តិចែងអំពីសំណងការខូចខាតដែលជាបញ្ហាសំខាន់ដោយសារថា អតីតមេដឹកនាំខ្មែរក្រហមគ្រប់គ្រងធនធានដ៏សម្បើម ក្នុងខណៈដែលប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិតចាកផុតពីរបបដឹកនាំកម្ពុជាប្រជាធិបតេយ្យ រស់នៅក្នុងកម្រិតជីវភាពទាបបំផុត ។ បញ្ហាទាំងអស់នេះនឹងមិនត្រូវបំពេញបន្ថែមនូវពាក្យពេចន៍បទដ្ឋានសិទ្ធិមនុស្សជាមូលដ្ឋានទេ មានន័យថា មានការសន្យាគ្រប់គ្រាន់ទៅហើយនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា និងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ ប៉ុន្តែជាអកុសល ធាតុពិតនៅត្រង់ថា ពាក្យនិយាយឲ្យតែពីរោះស្ដាប់ទាំងនេះមិនត្រូវបានអនុវត្តនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាឡើយ ។ វាមានប្រយោជន៍តិចតួចណាស់ក្នុងការសង្កត់ធ្ងន់ថាមន្ត្រីសំខាន់ៗមិនត្រូវស្វែងរកការណែនាំពីរដ្ឋាភិបាល ឬប្រភពខាងក្រៅល្អិកណាតែគ្មានផ្លូវណា

នឹងអនុវត្តបំរាមនេះ ។ មិនតែប៉ុណ្ណោះសោត នៅមានឱកាសសំខាន់ៗជាច្រើនទៀតដែលមិនបានបញ្ចូល ដែលឱកាសទាំងនេះអាចពង្រឹងនូវដំណើរការកាត់សេចក្តីនេះបានច្រើន ។ ចំណុចមួយទៀតគឺដូចដែលអង្គការលើកលែងទោសអន្តរជាតិ *Amnesty International* បានគូសបញ្ជាក់រួចហើយថា ធាតុផ្សំមួយស្តីអំពីការអភិវឌ្ឍន៍សមត្ថភាពនៃកម្មវិធីនេះគឺនៅមានកម្រិតទាបបំផុត ។ នេះគឺជាការអនុវត្តនៅៗតែម្តងដោយគ្មានការយកចិត្តទុកដាក់លើការអភិវឌ្ឍសមត្ថភាពនៃប្រព័ន្ធតុលាការកម្ពុជា ។

អង្គការមិនមែនរដ្ឋាភិបាលនានាបានលើកឡើងអំពីបញ្ហាសំខាន់ៗមួយចំនួនទាក់ទងដល់ការគ្រប់គ្រងទៅលើតុលាការទាំងមូលថាវាស្ថិតនៅក្នុងដៃរបស់បុគ្គលិកខ្មែរ អាស្រ័យដោយកម្រិតនៃឥទ្ធិពលនយោបាយមកលើខ្លួននិងភាពទន់ខ្សោយខាងអាជីពរបស់បុគ្គលិកខ្មែរ ។ ស្ថានការណ៍នេះនៅតែមិនទាន់ផ្លាស់ប្តូរនៅឡើយ ពោលគឺចៅក្រមខ្មែរនឹងគ្រប់គ្រងទៅលើដំណើរការកាត់សេចក្តី ហើយរូបមន្តមតិភាគច្រើនដែលមានលក្ខណៈលម្អៀង "មតិភាគច្រើនលើសលប់" ត្រូវយកមកប្រើ ។ គុណភាពនៃបុគ្គលិកនឹងក្លាយទៅជាកត្តាដែលធ្វើឲ្យមានឬធ្វើឲ្យបាត់បង់វិភាគទានរបស់តុលាការចំពោះប្រទេសកម្ពុជា ប្រសិនបើប្រជាជនកម្ពុជាពិតជាចាប់អារម្មណ៍ទៅលើការចង់ឃើញមេដឹកនាំកម្ពុជាប្រជា-ធិបតេយ្យឡើងតុលាការដូចដែលការស្ទង់មតិបានបង្ហាញនោះពេលនោះគុណភាពនៃបុគ្គលិក ឬដំណើរការជម្រះក្តីនឹងលែងពាក់ព័ន្ធដល់ចំណាប់អារម្មណ៍របស់ប្រជាជនកម្ពុជាទៀតហើយ ។ ប៉ុន្តែខ្ញុំជឿថា ប្រជាជនកម្ពុជាចង់ឃើញដំណើរការអនុវត្តតាមនីតិវិធីត្រឹមត្រូវច្រើនជាងនេះ មានន័យថា គាត់ចង់បានដំណើរការកាត់សេចក្តីមួយដែលមានគុណភាព ពោលគឺមានតម្លៃស្មើនឹងការបាត់បង់របស់គាត់ ។ សង្គមស៊ីវិលមានតួនាទីសំខាន់ក្នុងការបញ្ចុះបញ្ចូលតាមផ្លូវគំនិត ដើម្បីធានាថាមានតែអ្នកច្បាប់កម្ពុជាដែលល្អបំផុតមានសីលធម៌ខ្ពង់ខ្ពស់ និងមានអាកប្បកិរិយាថ្លៃថ្នូរបំផុតទេ ដែលនឹងត្រូវជ្រើសរើសឲ្យចូលរួមនៅក្នុងដំណើរការជម្រះក្តីនេះ ។ ចំណែកឯបេក្ខភាពបញ្ជូនមកតាមរយៈអង្គការសហប្រជាជាតិក៏ត្រូវមានគុណសម្បត្តិទាំងនេះដែរ ។ ប្រជាជនកម្ពុជាមានសិទ្ធិពេញលេញក្នុងការទាមទារឲ្យអង្គការសហប្រជា-ជាតិចាត់តាំងបុគ្គលិកអន្តរជាតិកំពូលៗដែលមានបទពិសោធន៍និងមានសុចរិតភាពពិតប្រាកដមកធ្វើការនៅក្នុងអង្គជំនុំជម្រះនេះ ។

ដំបូងនេះខ្ញុំសូមលើកយកបញ្ហាដែលមិនសូវមានភាពចម្រូងចម្រាស់មកជម្រាបជូន ។ ការមិនឲ្យមានសាលាឧទ្ធរណ៍និងការកាត់បន្ថយចំនួនចៅក្រមនៅតុលាការកំពូលទទួលបាននូវការស្វាគមន៍ ។ សាលាក្តីបីថ្នាក់ដែលបានលើកឡើងពីមុន គឺជារចនាសម្ព័ន្ធតុលាការនៅកម្ពុជាដែលមានលក្ខណៈប្រទាំងប្រទើសនិងអាចធ្វើឲ្យមានការចំណាយមិនចាំបាច់កើនឡើង ដោយហេតុថាតុលាការកំពូលនោះត្រូវបានប្រមើលថា នឹងមានចៅក្រមរហូតដល់៩នាក់ឯណោះ ។ កិច្ចព្រមព្រៀងថ្មីនេះមានអង្គជំនុំជម្រះតែពីរប៉ុណ្ណោះ គឺអង្គជំនុំសាលាដំបូងដែលមានចៅក្រមខ្មែរបីរូប និងចៅក្រមបរទេសពីររូប ចំណែកអង្គជំនុំជម្រះសាលាកំពូលមានចៅក្រមខ្មែរបួនរូបនិងចៅក្រមបរទេសបីរូប ។

វិសោធនកម្មជាក់ស្តែងនានាជាច្រើនដូចជាបទបញ្ញត្តិដែលចែងអំពីព្រះរាជអាជ្ញានិងចៅក្រមបម្រុង ។ ចំណុចនេះមានសារសំខាន់ ។ ចំណុចមួយទៀត គឺការបញ្ជាក់ច្បាស់អំពីតួនាទីរបស់ការិយាល័យរដ្ឋបាល ។ ចំណុចនេះក៏ល្អដែរ ។ ការិយាល័យនេះចង់សំដៅការ "បម្រើអង្គជំនុំជម្រះវិសាមញ្ញ អង្គបុរេជំនុំជម្រះ សហចៅក្រម និងអយ្យការ" (មាត្រា៧(១) ។ ប៉ុន្តែនៅមិនទាន់ច្បាស់នៅឡើយទេ ថាតើសេវាទាំងនេះរួមទាំងការទទួលខុសត្រូវចំពោះការការពារដល់សាក្សី ការការពារដល់ជនជាប់ចោទ សន្តិសុខនៅក្នុងសាលាក្តី ការរចនាក្រុង និង ការផ្សព្វផ្សាយឯកសារ ប្រតិចារឹក ការបកប្រែ ការផ្តល់ព័ត៌មានដល់សាធារណជន...ដែរឬទេ ។ អាចមានអ្នកសន្មតថាយ៉ាងដូច្នេះ ប៉ុន្តែដោយខ្វះនូវបទពិសោធន៍បែបនេះពីមុនមកនៅកម្ពុជា កិច្ចព្រមព្រៀងនេះយកល្អគួរតែបញ្ជាក់ឲ្យបានច្បាស់នូវការងាររបស់ការិយាល័យរដ្ឋបាលថា ខ្លួនពិតជាមានការទទួលខុសត្រូវចំពោះកិច្ចការទាំងនេះ ។ ក្រៅពីបុគ្គលិកអន្តរជាតិ ចៅក្រម សហចៅក្រម បូកនឹងចៅក្រមបម្រុង សហព្រះរាជអាជ្ញាមួយរូប បូកនឹងព្រះរាជអាជ្ញាបម្រុងមួយរូប អនុប្រធានការិយាល័យរដ្ឋបាលមួយរូប និង (ព្រះរាជអាជ្ញារង) វានៅតែមិនទាន់ច្បាស់នៅឡើយថា តើនឹងមានការចូលរួមរបស់អន្តរជាតិនៅក្នុងការងារប្រចាំថ្ងៃដែរឬយ៉ាងណា ។ ឧទាហរណ៍ តើចៅក្រមស៊ើបអង្កេតអន្តរជាតិ

ជំនាញៗ ដែលធ្លាប់ធ្វើការឲ្យតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី ឬរ៉្វាន់ដា អាចត្រូវបានគេជ្រើសរើសឲ្យមកជួយសហចៅក្រមដែរឬទេ ឬក៏ថាតើអ្នកស៊ើបអង្កេតទាំងអស់សុទ្ធតែមកពីជួរនគរបាលជាតិកម្ពុជា? ចុះបញ្ហាទីប្រឹក្សាច្បាប់អន្តរជាតិដែលមានជំនាញច្បាស់លាស់លើបញ្ហានេះ?

អង្គការសហប្រជាជាតិបានជម្រុះចោលនូវបទបញ្ញត្តិពីមុន ដែលចែងយ៉ាងសំខាន់អំពីករណីគ្មានថវិកាបម្រុងទុកក្នុងករណីដែលថវិកាមិនមានដូចដែលបានគ្រោងទុក (ចែងនៅក្នុងមាត្រា២៦នៃសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នា) ។ ប្រការនេះបញ្ជាក់ថា អង្គការសហប្រជាជាតិមានការធានានៅក្រៅឆាកថានឹងមានថវិកាគ្រប់គ្រាន់សម្រាប់ការចូលរួមរបស់ខ្លួននៅក្នុងគម្រោងការនេះ ។ ចំណុចបច្ចេកទេសផ្សេងៗទៀតដែលទាក់ទងទៅនឹងការចាត់ចែងផ្ទៃក្នុងរបស់អង្គការសហប្រជាជាតិទៅលើវិភាគទានរបស់ខ្លួនចំពោះគម្រោងនេះ ជាអាទិ៍ដូចជា ថវិកាអាណាព្យាបាលភាព ត្រូវបានដកចេញពីកិច្ចព្រមព្រៀងនេះទៅហើយ ។ ចំណុចមួយទៀតគឺ ដោយសារអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាធ្លាប់មានប្រវត្តិរកាំរកូសនឹងគ្នា មាត្រា២៨ ស្ដីអំពីការឈប់ធ្វើសហប្រតិបត្តិការ សង្ឃឹមថានឹងត្រូវអនុវត្ត ។ មាត្រានេះចែងថាប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា "ផ្លាស់ប្ដូររចនាសម្ព័ន្ធ ឬអង្គការលេខានៃអង្គជំនុំជម្រះវិសាមញ្ញ ឬធ្វើអ្វីផ្សេងពីនេះ ដែលជាហេតុបណ្ដាលឲ្យអង្គជំនុំជម្រះមិនអាចបំពេញតួនាទីទៅតាមកិច្ចព្រមព្រៀងបច្ចុប្បន្ននេះ អង្គការសហ-ប្រជាជាតិរក្សាសិទ្ធិឈប់ផ្ដល់ជំនួយ ទោះជំនួយជាថវិកាឬជំនួយផ្សេងៗទៀតដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ" ។

មានបញ្ហាសំខាន់មួយទៀតនៅត្រង់មាត្រា៩ ក្នុងសេចក្ដីព្រាងនៃកិច្ចព្រមព្រៀង ។ មាត្រានេះចែងថា និយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃលក្ខន្តិកៈច្បាប់ទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិនឹងត្រូវយកមកអនុវត្ត ។ ប្រការនេះមិនច្បាស់ថាវាជាកំហុសបច្ចេកទេស ឬក៏អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានយល់ព្រមនឹងគ្នាក្នុងការផ្លាស់ប្ដូរនិយមន័យដែលប្រើក្នុងច្បាប់ស្ដីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនោះទេ ។ និយមន័យនៅក្នុងច្បាប់នេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងនិយមន័យនៅក្នុងច្បាប់លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា ដែលមានការប្រើប្រាស់នូវចេតនារើសអើងជាតម្រូវការធាតុផ្សំមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនត្រឹមតែការធ្វើទុក្ខបុកម្នេញទេ ។ បញ្ហាក្នុងការប្រើនិយមន័យលក្ខន្តិកៈទីក្រុងរ៉ូម គឺថាបទល្មើសដែលនឹងត្រូវវិនិច្ឆ័យដោយអង្គជំនុំជម្រះវិសាមញ្ញបានកើតឡើងនៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ ។ និយមន័យនៃបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលបានព្រមព្រៀងគ្នានៅឆ្នាំ១៩៩៨សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាការវិវឌ្ឍទៅមុខលើសពីនិយមន័យដែលប្រើនៅក្នុងច្បាប់លក្ខន្តិកៈ ក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់រ៉្វាន់ដា និងសម្រាប់អតីតយូហ្គោស្លាវី ។ វាគឺជាគោលការណ៍សីលធម៌នៃច្បាប់សិទ្ធិមនុស្សដែលបុគ្គលម្នាក់អាចត្រូវបានវិនិច្ឆ័យទោសកាត់ឲ្យជាប់ទោសឬផ្ដន្ទាទោសដោយឈរលើមូលដ្ឋាននៃការប្រព្រឹត្តអំពើដែលជាបទល្មើសនៅពេលប្រព្រឹត្តអំពើនោះ ។ ក៏ប៉ុន្តែខ្ញុំសង្ស័យថានេះគឺជាកំហុសបច្ចេកទេសពីព្រោះថា មាត្រា២នៃកិច្ចព្រមព្រៀងដែលចែងថា កិច្ចព្រម-ព្រៀងនេះទទួលស្គាល់យុត្តាធិការលើរឿងក្ដីដូចដែលចែងនៅក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដោយគ្មានយោបល់ទៅលើការផ្លាស់ប្ដូរនិយមន័យនៃបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិឡើយ ។

គ្មានអ្វីគួរឲ្យភ្ញាក់ផ្អើលទេថា អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាដើម្បីលាងដៃឲ្យស្អាតកុំឲ្យពាក់ព័ន្ធដល់បញ្ហាលើកលែងឬបន្ធូរបន្ថយទោស ។ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានសម្រេចទុកបញ្ហានេះឲ្យចៅក្រមជាអ្នកសម្រេច ។ មាត្រា១១ បញ្ជាក់សាជាថ្មីនូវលក្ខខណ្ឌដែលចែងនៅក្នុងច្បាប់ស្ដីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញថា "រាជរដ្ឋាភិបាលកម្ពុជាមិនអាចស្នើសុំឲ្យមានការលើកលែងទោសឬអនុគ្រោះទោសដល់ជនទាំងឡាយណាដែលអាចត្រូវបានស៊ើបអង្កេត ឬត្រូវបានផ្ដន្ទាទោសអំពីឧក្រិដ្ឋកម្មដែលលើកឡើងនៅក្នុងកិច្ចព្រមព្រៀងបច្ចុប្បន្ន" ។ មាត្រានេះក៏បានបន្ថែមបញ្ញត្តិដែលបញ្ជាក់ច្បាស់អំពីការអះអាងរបស់រាជរដ្ឋាភិបាលកម្ពុជាដែលថាមានតែបុគ្គលម្នាក់ប៉ុណ្ណោះដែលទទួលបាននូវការលើកលែងទោសទាក់ទងដល់ការចេញសាលក្រមកំបាំងមុខឆ្នាំ១៩៧៩ ស្ដីអំពីបទប្រល័យពូជសាសន៍ ហើយភាគី

ទាំងពីរព្រមព្រៀងគ្នាថា វិសាលភាពនៃការលើកលែងទោសនេះ គឺជារឿងដែលត្រូវសម្រេចដោយអង្គជំនុំជម្រះវិសាមញ្ញ ។ នួន ជា និង ខៀវ សំផន មិនដែលត្រូវបានកាត់ឲ្យជាប់ទោសទេ ដូច្នេះ អ្នកទាំងពីរមិនដែលត្រូវបានលើកលែងទោសម្តងណាឡើយ ហើយក៏មិនដែលទទួលការលើកលែងតាមផ្លូវច្បាប់ថា មិនឲ្យចោទប្រកាន់ទៅលើករណីរបស់បុគ្គលទាំងពីរនេះដែរ ។ ឥឡូវនេះ រាជរដ្ឋាភិបាលមានកាតព្វកិច្ចមិនស្នើសុំការលើកលែងការចោទប្រកាន់ចំពោះបុគ្គលទាំងនេះទេ ចំណែកព្រះមហាក្សត្រវិញព្រះអង្គនឹងមិនប្រើអំណាចដែលរដ្ឋធម្មនុញ្ញប្រទានឲ្យដោយគ្មានសំណើនោះដែរ ។ ដូចនេះ វាហាក់ដូចជាថា ផ្លូវឈានទៅរកការចោទប្រកាន់បុគ្គលទាំងពីររូបនេះគឺមានលក្ខណៈច្បាស់ ។

ប៉ុន្តែបញ្ហាចម្រូងចម្រាស់អំពីករណី អៀង សារី នៅតែបន្តមានដដែល ។ ខាងក្រោមនេះ ហាក់ដូចជាដំណើររឿងក្តីមួយដែលទំនងជានឹងកើតឡើង ។ សហចៅក្រមបរទេសនឹងចង់ស៊ើបអង្កេតទៅលើករណី អៀង សារី ចំណែកខាងកម្ពុជាវិញ មិនចង់ស៊ើបអង្កេត ។ មាត្រា៥ (៤) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាចែងថា ប្រសិនបើមិនមានការព្រមព្រៀងគ្នា សហចៅក្រមត្រូវតែបន្តការស៊ើបអង្កេត ប្រសិនបើសហចៅក្រមណាម្នាក់ពុំបានប្តឹងមិនសុខចិត្តទៅអង្គបុរេជំនុំជម្រះទេ ។ សន្មតថាបញ្ហានេះត្រូវលើកទៅអង្គបុរេជំនុំជម្រះ ។ សន្មតទៀតថា ចៅក្រមខ្មែរធ្វើតាមដែលអ្នកផងធ្លាប់បានប្រមើល ហើយការមិនព្រមស៊ើបអង្កេតលើករណី អៀង សារី អាចធ្វើទៅបានដោយយោលទៅតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់កម្ពុជាពីព្រោះ អៀង សារី បានទទួលការលើកលែងទោសដោយស្របច្បាប់ អៀង សារី មិនអាចទទួលការវិនិច្ឆ័យទោសម្តងទៀតបានទេចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់និងកាត់ឲ្យជាប់ទោសកន្លងមក ។ ចៅក្រមអន្តរជាតិអាចទំនងជាប្រកាន់ជំហររបស់សហគមន៍អន្តរជាតិតាមបទដ្ឋានអន្តរជាតិទាក់ទងនឹងតុលាការឆ្នាំ១៩៧៩ ហើយនិយាយថា ការវិនិច្ឆ័យទោសគឺជាលទ្ធផលនៃដំណើរការកាត់សេចក្តីមិនមានធម្មានុរូបដែលស្ទើរតែត្រូវបានបដិសេធទូទាំងពិភពលោកទៅហើយថាជាការជម្រះក្តីឲ្យតែបានៗតែប៉ុណ្ណោះ ។ ចៅក្រមអន្តរជាតិនឹងបោះឆ្នោតឲ្យមានការបន្តការស៊ើបអង្កេត ។

រាល់ការសម្រេចចិត្តគឺត្រូវធ្វើឡើងដោយមតិភាគច្រើនលើសលប់ ។ មានន័យថា ចៅក្រមអន្តរជាតិមួយរូបត្រូវតែយល់ស្របជាមួយនឹងចៅក្រមខ្មែរ ។ ដូចនេះ នឹងមិនសម្រេចបានមតិភាគច្រើនលើសលប់ឡើយ ។ ប្រការនេះមានន័យថា តាមមាត្រា៧ (៤) ការស៊ើបអង្កេតឬការចោទប្រកាន់នឹងត្រូវបន្ត ។ រឿងក្តីនេះនឹងបន្តទៅមុខ ហើយប្រសិនបើមានភស្តុតាងធ្ងន់សមគួរ ហើយ អៀង សារី នឹងត្រូវចោទប្រកាន់ពីតុលាការ ។ នៅពេលចោទប្រកាន់រួចហើយ អៀង សារី ប្រហែលជានឹងបញ្ចេញយោបល់ប្រឆាំងរបស់ខ្លួនទៅលើដែនសមត្ថកិច្ចរបស់តុលាការពីព្រោះនេះគឺជាសិទ្ធិរបស់ចុងចោទ ហើយតុលាការមិនគួរនិយាយថាបញ្ហានេះត្រូវបានសម្រេចរួចហើយទេ (ពីព្រោះការសម្រេចចិត្តពីមុនអាចអនុវត្តបានតែចំពោះការស៊ើបអង្កេតប៉ុណ្ណោះ ហើយពេលនេះការសម្រេចនេះត្រូវបានប្រឆាំងដោយជនជាប់ចោទ) ដោយនិយាយថា អៀង សារី ត្រូវបានកាត់ឲ្យជាប់ទោសរួចហើយបានលើកលែងទោសរួចម្តងហើយ ហើយការកាត់ឲ្យជាប់ទោសម្តងទៀតគឺជាការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិរបស់ អៀង សារី ។ ដល់ពេលនេះ បញ្ហានេះរត់ទៅដល់អង្គជំនុំជម្រះដំបូងផ្ទាល់តែម្តងដែលក៏នឹងត្រូវសម្រេចដោយឈរលើមតិភាគច្រើនលើសលប់ ។ ប៉ុន្តែ មកដល់ដំណាក់កាលនេះមិនមានភាពសមមូលទៅនឹងមាត្រា៧ (៤) ទេ ក្នុងការនិយាយថា ករណីនេះត្រូវតែបន្តទៅមុខទៀត ប្រសិនបើចៅក្រមមិនបានព្រមព្រៀងគ្នាដោយសំឡេងភាគច្រើនលើសលប់នោះ ។ តើមានអ្វីកើតឡើង ប្រសិនបើចៅក្រមខ្មែរបីរូបបរិយាយថាតុលាការគ្មានដែនសមត្ថកិច្ចកាត់សេចក្តីលើករណី អៀង សារី បានទេ ដោយសារបញ្ហាលើកលែងទោស ចំណែកចៅក្រមអន្តរជាតិពីររូបនិយាយថា តុលាការនេះ មានដែនសមត្ថកិច្ចកាត់សេចក្តីករណី អៀង សារី? បទបញ្ញត្តិដែលចែងអំពីមតិភាគច្រើនលើសលប់បានសេចក្តីថា ប្រសិនបើគ្មានសំឡេងវិជ្ជមានពីចៅក្រមបួនរូបទេអង្គជំនុំជម្រះនេះមិនអាចចេញសេចក្តីសម្រេចបានទេ ។ ប្រការនេះអាចនាំឲ្យមានបញ្ហាវិសាមញ្ញមួយដែលតុលាការមិនអាចចេញសេចក្តីសម្រេចដែលនិយាយថា យល់ព្រមឬមិនយល់ព្រមទៅលើបញ្ហាថាតើ អៀង សារី ត្រូវរួចពីការចោទប្រកាន់ដោយសារការលើកលែងទោសពីមុនឬយ៉ាងណា ។

ជាប្រការល្អដែលបានឃើញនូវ ការពង្រឹងដំណើរការជំនុំជម្រះក្តីឲ្យមានយុត្តិធម៌ និងត្រឹមត្រូវទៅតាមបទបញ្ញត្តិបានចែង ។ ប៉ុន្តែ ទាំងនេះគឺគ្រាន់តែពាក្យពេចន៍បន្ថែមទៅលើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដែលមានស្រាប់តែប៉ុណ្ណោះ (មាត្រា៣៥ ដែលបញ្ជាក់បន្ថែមទៅលើមាត្រា១៤ (៣) នៃកតិកាសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ) និងរដ្ឋធម្មនុញ្ញកម្ពុជា ។ បញ្ហាជាក់ស្តែងសម្រាប់អ្នកដែលធ្វើកំណែទម្រង់ទៅលើប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាគឺត្រូវធ្វើយ៉ាងណាធ្វើឲ្យភាសាច្បាប់ដែលតែងឲ្យតែពីរោះស្តាប់នោះត្រូវបានអនុវត្តជាក់ស្តែងនៅក្នុងតុលាការកម្ពុជា ។ រាល់អ្នកដែលធ្លាប់បានធ្វើការជាមួយចៅក្រមនិងព្រះរាជអាជ្ញាខ្មែរ នឹងបញ្ជាក់ថាខ្លួនមិនចង់ធ្វើការជាមួយគោលការណ៍ទូទៅបែបនេះដែលតម្រូវឲ្យ «អនុវត្តដែនសមត្ថកិច្ចរបស់ខ្លួនឲ្យស្របទៅតាមបទដ្ឋានយុត្តិធម៌ អន្តរជាតិ ភាពយុត្តិធម៌ និង ភាពត្រឹមត្រូវទៅតាមច្បាប់» ទេ មាត្រា១២ (២) ។ គេចូលចិត្ត «ច្បាប់ដែលចែងច្បាស់អំពីអ្វីដែលសអ្វីដែលខ្មៅ» ពោលគឺវិធានបច្ចេកទេសដែលនិយាយច្បាស់ៗនូវអ្វីដែលគួរធ្វើឬមិនគួរធ្វើ ។ គេពិតជាមិនចង់ធ្វើការជាមួយនឹងការបកស្រាយច្បាប់ឬទាញយកវិធានជាក់ស្តែងចេញពីគំនិតអរូបិយឡើយ ។ ម្យ៉ាងទៀត ស្ថិតនៅក្នុងសភាពច្របូកច្របល់ជាមួយច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា អ្នកច្បាប់អន្តរជាតិ និងជនជាតិខ្មែរអាចសង្ឃឹមថានឹងមានការខ្វែងគំនិតគ្នាទៅលើនីតិវិធីដែលត្រូវយកមកប្រើ ។ អ្នកច្បាប់អន្តរជាតិប្រហែលជាមានទំនោរទៅលើច្បាប់ដែលព្រាងដោយអ៊ុនតាក់ (ក្រឹត្យរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ស្តីអំពីច្បាប់ព្រហ្មទណ្ឌនិងនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩២) ។ ចំណែកជនជាតិខ្មែរប្រហែលជានិយាយថា ច្បាប់របស់រដ្ឋកម្ពុជា (ច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣) គឺជាច្បាប់ដ៏ល្អបំផុតដែលត្រូវអនុវត្តតាម ។ នៅក្នុងព្រឹត្តិការណ៍ជុំវិញនឹងមានការតវ៉ាអំពីក្រមនីតិវិធីព្រហ្មទណ្ឌបារាំងនិងរដ្ឋធម្មនុញ្ញកម្ពុជា ។ ដូចនេះ វាជារឿងដ៏អាម៉ាស់មួយដែលអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាមិនបានព្រមព្រៀងនឹងគ្នាឲ្យបានច្បាស់ ក្នុងការអនុម័តវិធានពិសេសនៃនីតិវិធីដែលផ្អែកលើនីតិវិធីអនុវត្តនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ អតីតយូហ្គោស្លាវី ឬ រ៉ាន់ដា ឬក៏តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ អង្គការសហប្រជាជាតិបានយល់ស្របជាមួយរដ្ឋាភិបាលសេរ៉ាឡេអូន ថា វិធាននៃនីតិវិធីនិងវិធាននៃភស្តុតាងរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា នឹងយកមកអនុវត្តដោយមានការផ្លាស់ប្តូរចាំបាច់មួយចំនួនទៅលើដំណើរការកាត់សេចក្តីនៅក្នុងតុលាការពិសេស ប៉ុន្តែ ចៅក្រមអាចប្រើវិធានទាំងនោះតាមការចាំបាច់ជាក់ស្តែង ។ ចៅក្រម (ទាំងចៅក្រមក្នុងស្រុកនិងអន្តរជាតិ) បានយកវិធានទាំងនោះមកប្រើទៅតាមកាលៈទេសៈជាក់ស្តែងពិសេសរបស់ខ្លួន ហើយការបង្ហាញខ្លួនរបស់ជនជាប់ចោទមុនគេនៅមុខតុលាការពិសេស គឺធ្វើឡើងមួយសប្តាហ៍កន្លងទៅ ។ យោងតាមស្ថាន-ការណ៍ជាក់ស្តែងបែបនេះ អ្វីដែលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាមិនទាន់ចាត់ការឲ្យបានជាក់ស្តែងនោះ គឺដូចជាឃ្លាមួយសរសេរថា «នៅត្រង់ចំណុចណាដែលច្បាប់កម្ពុជាមិនអាចយកមកអនុវត្តបានចំពោះបញ្ហាណាមួយនោះ ឬក្នុងករណីមានភាពមិនប្រាកដប្រជាទាក់ទងដល់ការបកស្រាយ ឬការអនុវត្តវិធាននៃច្បាប់កម្ពុជាដែលពាក់ព័ន្ធ ឬក្នុងករណីមានបញ្ហាទាក់ទងនឹងភាពមិនស៊ីគ្នារវាងវិធាននៃច្បាប់កម្ពុជាជាមួយនឹងបទដ្ឋានអន្តរជាតិ ការណែនាំបំភ្លឺអាចរកបាននៅក្នុងវិធាននៃនីតិវិធីដែលបង្កើតឡើងក្នុងកម្រិតអន្តរជាតិ» ។ តើអ្នកណាសម្រេចអំពីអ្វីថាជាការណែនាំ? រត់ទៅរកចៅក្រមដែលជាប់ចំណងដោយសារតម្រូវការសំឡេងភាគច្រើនលើសលប់ពិបាកជួយបន្តិចហើយ ។ ពេលខ្លះអាចមានអ្នកចង់បានការបកស្រាយច្បាប់ ការឲ្យយោបល់ ឬ ការណែនាំដែលមានការពិចារណាត្រឹមត្រូវ មិនមែនគ្រាន់តែនិយាយថា «បាទ» ឬ «ទេ» នោះទេ ។

ឱកាសដ៏ពិសេសមួយដែលមិនបានបញ្ចូលនៅក្នុងកិច្ចព្រមព្រៀងនេះគឺការការពារនិងថែទាំសាក្សី ។ មាត្រា២៣ ត្រូវបានធ្វើវិសោធនកម្មប៉ុន្តែនៅតែខ្សោយនៅឡើយ «សហចៅក្រមស៊ើបអង្កេត សហព្រះរាជអាជ្ញា និង អង្គជំនុំជម្រះវិសាមញ្ញត្រូវផ្តល់នូវការការពារដល់ជនរងគ្រោះនិងសាក្សី ។ វិធានការការពារទាំងនេះមិនត្រូវកម្រិតត្រឹមតែកិច្ចដំណើរការជំនុំជម្រះជាសម្ងាត់ និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះ ឬសាក្សីឡើយ» ។ ម្យ៉ាងទៀត បទពិសោធន៍របស់អង្គការសហប្រជាជាតិជាមួយជនរងគ្រោះនិងសាក្សី នៅឯតុលាការព្រហ្ម

ទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉្វាន់ដានិងយូហ្គោស្លាវី ដែលមានបុគ្គលិកដ៏ច្រើនសន្ធឹកសន្ធាប់ប្រកបដោយជំនាញបរិបូរណ៍ អាចចែករំលែកមកឲ្យកម្ពុជាខ្លះ ។ អាចមានអ្នកខ្លះគិតថា បុគ្គលិកមានបទពិសោធន៍ទាំងនោះអាចទទួលខុសត្រូវចំពោះការការពារដល់សាក្សី ឬយ៉ាងហោចណាស់តាំងចិត្តផ្តល់នូវជំនួយជាដុំកំភួនដល់កម្ពុជាដែរ ។ ប៉ុន្តែផ្ទុយទៅវិញ ការទទួលខុសត្រូវសម្រាប់ការការពារសាក្សីត្រូវដាក់នៅក្នុងបន្ទុករបស់សហចៅក្រមស៊ើបអង្កេតសហព្រះរាជអាជ្ញា និងអង្គជំនុំជម្រះវិសាមញ្ញដោយមិនបាននិយាយអំពីតួនាទីណាមួយរបស់អង្គការសហប្រជាជាតិសោះ ។ ដូចនេះតើភាគីនីមួយៗដែលមានឈ្មោះត្រូវរៀបចំកម្មវិធីគាំពារសាក្សីក្នុងទ្រង់ទ្រាយតូចទៅតាមជម្រើសរៀងៗខ្លួនឬយ៉ាងណា? តើនគរបាលជាតិកម្ពុជាមានកាតព្វកិច្ចជួយនៅក្នុងដំណើរការនេះឬ? ម្យ៉ាងទៀត មិនគិតតែត្រឹមការការពារនោះទេ ការថែរក្សាសាក្សីគួរតែជាផ្នែកមួយនៃដំណើរការនេះដែរ ។ ការប៉ះទង្គិចផ្លូវអារម្មណ៍សាជាថ្មី គឺជាគ្រោះថ្នាក់ខ្លាំងបំផុតដែលបណ្តាលមកពីការធ្វើជាកសិណចំពោះអំពើឃោរឃៅដ៏គួរឲ្យរន្ធត់ ចំណែកឯផលប៉ះពាល់ផ្ទាល់ខ្លួនរបស់សាក្សីនិងការផ្តល់ឱវាទគឺពិតជាមានសារសំខាន់ណាស់ ។ និយាយឲ្យប្រាកដទៅវាមិនទាន់ហួសពេលនៅឡើយទេ ចំពោះអង្គការសហប្រជាជាតិក្នុងការផ្តល់នូវការតាំងចិត្តជួយសមភាគីកម្ពុជាក្នុងការបង្កើតនូវក្រុមគាំពារជនរងគ្រោះនិងសាក្សី ព្រមទាំងផ្តល់នូវបុគ្គលិកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។

បទបញ្ញត្តិដែលចែងថា ស្នាក្តីនឹងត្រូវផ្តល់ឲ្យប្រសិនបើជនជាប់ចោទមិនមានប្រាក់ឈ្នួលនោះ មិនមានការផ្លាស់ប្តូរនៅក្នុងកិច្ចព្រមព្រៀងថ្មីរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលឡើយ ចំណែកឯស្នាក្តីនៅតែបន្តមានសិទ្ធិនិងអភ័យឯកសិទ្ធិរបស់ខ្លួនដដែល ។ ការបន្ថែមដ៏សំខាន់មួយគឺបទបញ្ញត្តិដែលចែងថា ជនជាប់ចោទមានសិទ្ធិក្នុងការជ្រើសរើសស្នាក្តីរបស់ខ្លួន មានន័យថា មេធាវីបរទេសអាចតំណាងឲ្យជនជាប់ចោទបាន ។ ជនជាប់ចោទលែងកំណត់តែមេធាវីជនជាតិខ្មែរដូចមុនទៀតហើយ ។ ប៉ុន្តែសេរីភាពក្នុងការជ្រើសរើសអាចអនុវត្តបានប្រសិនបើក្នុងករណីដែលជនជាប់ចោទមានលទ្ធភាពបង់ថ្លៃសេវាដោយខ្លួនឯងតែប៉ុណ្ណោះ ប្រសិនបើគ្មានលទ្ធភាពបង់ទេ គឺជនជាប់ចោទគ្មានជម្រើសណាក្រៅពីទទួលយកនូវមេធាវីដែលមាននៅក្នុងបញ្ជីរាយនាមមេធាវីដែលធ្វើឡើងដោយអង្គជំនុំជម្រះឡើយ ។ ឧទាហរណ៍ នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីត យូហ្គោស្លាវីនិងរ៉្វាន់ដា ជនជាប់ចោទទុរគត (អ្នកដែលមិនអាចបង់ថ្លៃការពារក្តីបាន) អាចមានជម្រើសតែមួយគត់ គឺជ្រើសរើសយកមេធាវីម្នាក់ពីក្នុងបញ្ជីរាយនាមមេធាវីដែលធ្វើឡើងដោយក្រឡាបញ្ជីដែលជាអ្នកចំណាយលុយជួសមុខឲ្យអង្គការសហប្រជាជាតិ ។ ប៉ុន្តែ អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាមិនបានដោះស្រាយបញ្ហាថាតើអ្នកណានឹងបង់ថ្លៃសម្រាប់មេធាវីអន្តរជាតិ ឬ មេធាវីក្នុងស្រុកជាមួយនឹងមធ្យោបាយគ្រប់គ្រាន់សម្រាប់ធ្វើកិច្ចការរបស់ខ្លួនក្នុងការការពារកូនក្តីរបស់ខ្លួននោះទេ ។ ចុះបើក្នុងករណីមេធាវីត្រូវការធ្វើដំណើរទៅស៊ើបអង្កេតនៅប្រទេសផ្សេងៗដូចជានៅប្រទេសចិន ប្រទេសវៀតណាម ដើម្បីស៊ើបអង្កេតយ៉ាងល្អិតល្អន់ តើត្រូវធ្វើយ៉ាងដូចម្តេច? ចុះបើមេធាវីត្រូវការឯកសារជាច្រើនត្រូវបកប្រែ តើធ្វើយ៉ាងដូចម្តេច? តាមរយៈអ្នកបកប្រែនេះ មេធាវីអាចទាក់ទងនឹងកូនក្តីបាន ។ តើអ្នកណានឹងចំណាយទៅលើអ្នកបកប្រែសម្រាប់មេធាវី? តើមានជំនួយអ្វីខ្លះដែលអង្គជំនុំជម្រះវិសាមញ្ញអាចផ្តល់ឲ្យមេធាវីការពារចុងចោទនៅពេលមេធាវីត្រូវការឯកសារដែលភាគីទាំងពីរបដិសេធមិនព្រមប្រគល់ឲ្យ? ការិយាល័យរដ្ឋបាលមិនមានការទទួលខុសត្រូវក្នុងការជួយដល់មេធាវីការពារជនជាប់ចោទឡើយ ។ ការិយាល័យនេះជួយអ្នកផ្សេងក្នុងនោះរួមមានភាគីមួយក្នុងចំណោមភាគីជាប់វិវាទ ប៉ុន្តែមិនមែនភាគីម្ខាងទៀតដែលជាអ្នកការពារក្តីឡើយ ។ រាជរដ្ឋាភិបាលកម្ពុជាជួយអ្នកផ្សេងនៅក្នុងបរិវេណការិយាល័យ ប៉ុន្តែមិនមែនមេធាវីការពារក្តីទេ ។ ដូចនេះ ទោះជាមានការផ្លាស់ប្តូរមួយហើយក្តី ក៏ហាក់ដូចជានៅតែពុំមានអាវុធស្មើគ្នាសម្រាប់ភាគីទាំងពីរដូចដែលច្បាប់អន្តរជាតិតម្រូវនោះឡើយ ។

កិច្ចព្រមព្រៀងថ្មីនៅមិនទាន់បំភ្លឺអំពីបញ្ហាការពារក្តីដែលនឹងលើកឡើងនៅពេលមានការជំនុំជម្រះក្តីពិតប្រាកដនៅឡើយ ។ ច្បាប់ស្តីអំពីនីតិវិធីព្រហ្មទណ្ឌកម្ពុជាបច្ចុប្បន្នដែលយកមកអនុវត្តចំពោះតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម មិនបានចែងបទបញ្ញត្តិទៅលើការការពារក្តីឡើយ ទោះជាច្បាប់អ៊ុនតាក់បាន

បញ្ជាក់អំពីកត្តាមួយចំនួនដែលអាចសម្រាលទោសក៏ដោយចុះ ។ ចុះអំពីក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦វិញ ដែលហាក់ដូចជានៅតែអាចអនុវត្តបាននៅក្នុងកម្ពុជា ក្នុងអំឡុងសម័យកម្ពុជាប្រជាធិបតេយ្យនៅឡើយ ហើយចុះបើមិនអនុវត្តវិញមានបញ្ហាយ៉ាងណាដែរ? ចុះច្បាប់អន្តរជាតិ? មានការព្រួយបារម្ភណាស់ថា ជនដែលត្រូវជាប់ចោទអាចនឹងមកកាន់តុលាការដោយមិនទាំងដឹងថាអ្វីជាការការពារក្តីដែលខ្លួនត្រូវពឹងផ្អែកផង ។ ប្រការនេះគឺត្រូវបង្កើតដោយអង្គច្បាប់ផ្ទាល់តែម្តង ។ ការស្រាយបំភ្លឺបញ្ហានេះនឹងអាចក្លាយជាការផ្តល់វិភាគទានចំពោះការជំនុំជម្រះក្តីប្រកបដោយភាពយុត្តិធម៌នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញ ប្រសើរជាងគ្រាន់តែបន្ថែមពាក្យពេចន៍មួយចំនួនអំពីកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ដូចដែលមានចែងនៅមាត្រា១២ ស្តីអំពីនីតិវិធីព្រហ្មទណ្ឌ ។ ចៅក្រមតុលាការព្រហ្មទណ្ឌអន្តរជាតិមានស្ទើរគ្រប់បញ្ហាច្បាប់សារធាតុដែលដោះស្រាយរួចជាមុនតាមរយៈច្បាប់លក្ខន្តិកៈ វិធានស្តីអំពីនីតិវិធី និងវិធីស្តីអំពីភ័ស្តុតាង និងឯកសារមួយមានឈ្មោះថាធាតុផ្សំនៃបទល្មើស ។ ប្រសិនបើមានតុលាការមួយដែលមិនត្រូវបានអនុញ្ញាតឲ្យធ្វើស្រេចតែចិត្តខ្លួនចង់នៅក្នុងបញ្ហាសំខាន់និងស្មុគស្មាញដូចជាមាតិកាដែលគ្មានរូបរាងពិតប្រាកដនៃច្បាប់កម្ពុជា និងច្បាប់អន្តរជាតិ ក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ឬបកស្រាយគោលការណ៍ច្បាប់ទូទៅ គឺអាស្រ័យទៅលើអង្គជំនុំជម្រះវិសាមញ្ញ ។ ហេតុដូចនេះ វាហាក់ដូចជាការធ្វេសប្រហែសទៅហើយដែលថា បញ្ហាសំខាន់ៗដូចជាការការពារក្តីដែលនឹងយកមកអនុវត្តនោះមិនទាន់ធ្វើការដោះស្រាយជាមុននោះ ។

ចំណុចចុងក្រោយ ដោយកន្លំទៅលើលក្ខណៈរបស់អនុស្សារណៈនៃការយោគយល់គ្នារវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា វាជាការគួរឲ្យភ្ញាក់ផ្អើលថាកិច្ចព្រមព្រៀងថ្មីនេះ នៅមិនទាន់បញ្ជាក់ច្បាស់ថាតើកិច្ចព្រមព្រៀងនេះមានទំនាក់ទំនងជាផ្លូវការយ៉ាងដូចម្តេចជាមួយនឹងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ គឺថាលក្ខណៈច្បាប់ពិតប្រាកដ និងឋានានុក្រមរវាងអត្ថបទច្បាប់ទាំងពីរនេះឯង ។ តើអត្ថបទច្បាប់មួយណាដែលតុលាការយកមកមើលច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ឬកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ដែលកិច្ចព្រមព្រៀងនេះនឹងក្លាយជាច្បាប់ពេញលក្ខណៈគតិយុត្តិក្រោយពីមានការផ្តល់សច្ចាប័ននៅក្នុងប្រទេសកម្ពុជា ។ ជាខ្លឹមសារ កិច្ចព្រមព្រៀងនេះមានបទបញ្ញត្តិសំខាន់ៗច្រើន ស្តីពីសិទ្ធិរបស់ជនជាប់ចោទ ការលើកលែងទោស នីតិវិធី ។ល ។ ហើយកិច្ចព្រមព្រៀងនេះទៀតសោតតម្រូវឲ្យមានការផ្លាស់ប្តូរមួយចំនួនទៅលើច្បាប់កម្ពុជាដែលមានសុពលភាព ។ មាត្រា២ ទទួលស្គាល់ត្រឹមតែចំណុចមួយចំនួននៅក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ដូចជាយុត្តាធិការលើរឿងក្តី និងយុត្តាធិការលើរូបបុគ្គលដែលជាការនាំឲ្យមានចម្ងល់ថា ចុះក្រៅពីចំណុចនេះនៅក្នុងច្បាប់គេមិនទទួលស្គាល់ទេឬ? ដំរឿងគឺនៅជុំវិញបញ្ហាថាតើត្រូវធ្វើយ៉ាងដូចម្តេចចំពោះច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ។ មិនថាក្នុងជំហរច្បាប់យ៉ាងណានោះទេ ជាលទ្ធផលនៃកិច្ចព្រមព្រៀងនេះកម្ពុជាពិតនឹងជាត្រូវធ្វើវិសោធនកម្មច្បាប់ស្តីអំពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញដោយផ្ទាល់ ឬធ្វើតាមរយៈច្បាប់ដែលយល់ស្របចំពោះកិច្ចព្រមព្រៀងនេះ ។ ម្យ៉ាងទៀតប្រសិនបើមានការផ្ទុយគ្នារវាងច្បាប់ទាំងពីរនេះតើត្រូវធ្វើយ៉ាងដូចម្តេច? បញ្ហាសំខាន់គឺនៅត្រង់ថាអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានព្រមព្រៀងគ្នាថាត្រូវធ្វើការផ្លាស់ប្តូរទៅលើច្បាប់កម្ពុជាមួយដែលមានសុពលអនុម័តដោយអង្គនីតិបញ្ញត្តិដែលមិនមែនជាភាគីនៅក្នុងកិច្ចព្រមព្រៀងនេះ ។ ពិតណាស់ថា អង្គនីតិបញ្ញត្តិនេះនឹងយល់ស្របនៅចុងថ្ងៃនោះតែម្តង ប៉ុន្តែជាទម្លាប់តម្រូវថាវានឹងមិនចេះតែប្រថាប់ត្រាផ្ទាយៗនោះទេ (នឹងមានការចាប់អារម្មណ៍យ៉ាងខ្លាំង ប្រសិនបើអង្គនីតិបញ្ញត្តិបដិសេធមិនព្រមអនុម័ត) ។

**ស៊ូហ្សាណា លីនតុន**

# ពាក្យស្លោកខ្មែរក្រហម

- ◆ កងទ័ពស្រួចប្រមូលផ្តុំវាយកម្ទេចខ្មាំង កម្ទេចកម្លាំងធំរបស់ខ្មាំង ទើបយើងឆាប់រហ័សបានទទួលជ័យជម្នះ និងអាចការពារ ពង្រីកកម្លាំងយើងបាន។

(សៀវភៅកំណត់ហេតុ លេខ១៩៨)

**(តមកពីទំព័រ១)** អង្គការសហប្រជាជាតិ ដើម្បីបង្កើតតុលាការមួយ ។

រដ្ឋាភិបាលកម្ពុជាតែងតែប្រាប់ទៅសហគមន៍អន្តរជាតិថា ខ្លួនកំពុងតែប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធ្វើកិច្ចសហប្រតិបត្តិការជាមួយសហគមន៍អន្តរជាតិស្តីអំពីបញ្ហាកាត់ទោសមេដឹកនាំខ្មែរ-ក្រហម ។

ប្រទេសមួយចំនួនទៀត ដូចជាសាធារណរដ្ឋប្រជាមានិតចិនជាដើម បានគូសបញ្ជាក់ច្បាស់ថា ខ្លួនជំទាស់នឹងការបង្កើតតុលាការដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ រាជរដ្ឋាភិបាលតែងតែប្រាប់ដល់ប្រទេសចិនថា ខ្លួនកំពុងតែដើរតាមនយោបាយ "ឈ្នះៗ" ។ ចិនបានផ្តល់ជំនួយហិរញ្ញវត្ថុដ៏ច្រើនសន្ធឹកសន្ធាប់ដល់កម្ពុជារហូតដល់មានអ្នកខ្លះប៉ាន់ស្មានថាមានចំនួនដល់រាប់កោដិដុល្លារត្រឹមតែរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ។

ជាការពិតណាស់ ការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមគឺជាជម្រើសដ៏ជាទីពេញចិត្ត ប៉ុន្តែយើងក៏ត្រូវតែគិតពិចារណាទៅលើលទ្ធភាពថា តុលាការនេះនឹងមិនមានរូបរាងជារៀងរហូត ។ ប្រសិនបើករណីនេះកើតឡើងពិតមែន តើយើងត្រូវធ្វើដូចម្តេចទើបអាចដោះស្រាយទៅបាននូវតម្រូវការរបស់ប្រជាជនកម្ពុជាដែលចង់បានការរំសាយអារម្មណ៍ និងការចាកផុតពីអារម្មណ៍វិលវល់ និងការព្រួយបារម្ភដែលនៅតែតាមយាយីខ្លួនចាប់តាំងពីរបបខ្មែរក្រហម? វិធីមួយដែលអាចទៅរួចគឺបង្កើតគណៈកម្មការស្វែងរកការពិតដើម្បីជួយស្វែងរកការពិតអំពីរបបខ្មែរក្រហម និងដើម្បីជួយជំរុញឲ្យមានការផ្សះផ្សាក្នុងចំណោមប្រជាជនកម្ពុជា ។ នៅក្នុងអំឡុងពេលកិច្ចប្រជុំកំពូលអាស៊ាននៅទីក្រុងភ្នំពេញកាលពីខែវិច្ឆិកា ឆ្នាំ២០០២ លោកប្រធានាធិបតីអាហ្វ្រិកខាងត្បូង ថាបូ បេគី បានប្រកាសថាប្រទេសរបស់លោករៀបចំខ្លួនរួចជាស្រេចក្នុងការចូលរួមចែករំលែកបទពិសោធន៍ស្តីអំពីគណៈកម្មការស្វែងរកការពិតជាមួយរាជរដ្ឋាភិបាលកម្ពុជា ប្រសិនបើកម្ពុជាប្រាថ្នាចង់ធ្វើតាមផ្លូវនេះ ។ រាជរាដ្ឋាភិបាលធ្លាប់ប្រកាសម្តងហើយថា ខ្លួនចាប់អារម្មណ៍ចំពោះគំនិតធ្វើការស៊ើបអង្កេតតាមបែបគណៈកម្មការស្វែងរកការពិតទៅលើបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងដោយរបបខ្មែរក្រហម ។ នៅខែមករា ឆ្នាំ១៩៩៩ រាជរដ្ឋាភិបាលនិយាយថា ខ្លួនជំទាស់នឹងសំណើរបស់ក្រុមអ្នកជំនាញការនៃអង្គការសហប្រជាជាតិដែលចង់បង្កើតតុលាការអន្តរជាតិ ហើយចង់បង្កើតគណៈកម្មការស្វែងរកការពិតជំនួសវិញ ។ ប៉ុន្តែ នៅពេលដែលកាលៈទេសៈកាន់តែច្បាស់ថាសំណើរបស់អង្គការសហប្រជាជាតិចង់បានតុលាការនេះលែងប្រើកើតហើយ រដ្ឋាភិបាលចង់បោះបោលនូវគំនិតបង្កើតគណៈកម្មការស្វែងរកការពិត ។

ឥឡូវនេះហាក់ដូចជាមានសន្ទុះកាន់តែខ្លាំងឡើងៗទាក់ទងនឹងការបង្កើតតុលាការដែលមានជំនួយពីអង្គការសហប្រជាជាតិ ។ ពេលនេះយើងឮសាជាថ្មីនូវការនិយាយអំពីគណៈកម្មការស្វែងរកការពិត ។ តើនេះជាការចៃដន្យឬ? ខៀវ សំផន និង នួន ជា ត្រូវបានរាយការណ៍មកថា សុំឲ្យមានការបង្កើតគណៈកម្មការស្វែងរកការពិតជំនួសឲ្យការកាត់ទោសតាមផ្លូវព្រហ្មទណ្ឌ ។ មានហេតុផលគ្រប់គ្រាន់ក្នុងការជំទាស់ទៅនឹងគំនិតនេះ ។ ហេតុផលទីមួយគឺថា នៅក្នុងសង្គមដែលមានការអភិវឌ្ឍឧក្រិដ្ឋជនដែលត្រូវបានចោទប្រកាន់មិនអាចជ្រើសរើសផ្លូវណាមួយដើម្បីវិនិច្ឆ័យទោសរបស់ខ្លួនឡើយ ។ លទ្ធភាពនៅតែស្ថិតក្នុងរបត់មួយថាគំនិតបង្កើតគណៈកម្មការស្វែងរកការពិតកំពុងតែត្រូវបានបណ្តុះជាថ្មីម្តងទៀត នេះគឺគ្រាន់តែដើម្បីរារាំងមិនឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌតែប៉ុណ្ណោះ ។

ប្រហែលជាថា កម្ពុជាមិនចាំបាច់បង្កើតគណៈកម្មការស្វែងរកការពិតទេ ពីព្រោះអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់ និងមន្ត្រីនានាបានសង្កេតឃើញថា កម្ពុជាមានគ្រឹះស្ថានមួយហើយដែលដើរតួយ៉ាងសំខាន់បំផុត ជាពិសេសដូចគ្នាទៅនឹងគណៈកម្មការស្វែងរកការពិតដែរ ។ អ្វីដែលពិតជាតម្រូវឲ្យមាន គឺការផ្តល់នូវការគាំទ្រគ្រប់គ្រាន់ដល់គ្រឹះស្ថានដែលមានស្រាប់ ពោលគឺមជ្ឈមណ្ឌលឯកសារកម្ពុជាដែលដំណើរការដោយឯករាជ្យ មិនស្ថិតនៅក្រោមឥទ្ធិពលនយោបាយ លាតត្រដាងការពិតអំពីការប្រល័យពូជសាសន៍នៅកម្ពុជា ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែបង្កើតនូវប្រវត្តិសាស្ត្រពិតមួយ អំពីអ្វីដែលបានកើតឡើងនៅក្នុង "របបប៉ុលពត" ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែបញ្ចេញឈ្មោះចារីនៃបទល្មើស និងប្រាប់ឲ្យដឹងអំពី

ដោតវាសនារបស់ជនរងគ្រោះដែលបានបាត់ខ្លួន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុង តែបើកឯកសារសម្ងាត់បន្សល់ទុកដោយផ្នែកសន្តិសុខផ្ទៃក្នុងរបស់ខ្មែរក្រហម ។ មជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែពុះពារជាមួយនឹងរចនាសម្ព័ន្ធការិយាល័យដែលបន្សល់ទុកតាំងពីរបបបង្រ្កាបមិនរើសមុខដ៏គួរឲ្យរន្ធត់ ហើយក៏កំពុងតែរិះរកនូវការបង្រួបបង្រួមផ្សះផ្សាជាតិតាមរយៈការសិក្សាស្រាវជ្រាវ ក្រោយពីសោកនាដកម្មត្រូវបានបញ្ចប់ ។ ដូច្នេះបើមើលតាមផ្លូវជាច្រើន មជ្ឈមណ្ឌលឯកសារកម្ពុជាទាំងចេតនានិងគោលបំណងគឺជាគណៈកម្មការស្វែងរកការពិតមួយដែលកំពុងតែដំណើរការ ។

ប៉ុន្តែមានបីចំណុចដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានសភាពខុសពីគណៈកម្មការស្វែងរកការពិតដែលមានលក្ខណៈជាប្រពៃណី ។ ទីមួយ គឺគណៈកម្មការស្វែងរកការពិតមានជីវិតខ្លីជាងចំណែកឯមជ្ឈមណ្ឌលឯកសារកម្ពុជាវិញគឺកសាងឡើងក្នុងគោលបំណងក្លាយជាគ្រឹះស្ថានអចិន្ត្រៃយ៍ ។ ទីពីរ គឺគណៈកម្មការស្វែងរកការពិតជាទូទៅជាភ្នាក់ងារសាធារណផ្លូវការ និងមានពេលខ្លះមានអំណាចចេញដីកាកោះ ។ តែផ្ទុយមកវិញ មជ្ឈមណ្ឌលឯកសារកម្ពុជាគឺជាអង្គការឯកជនដែលមិនរកប្រាក់ចំណេញទោះបីជាមជ្ឈមណ្ឌលឯកសារកម្ពុជាចុះកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលសុំជាភោគីនូវឯកសារភ័ស្តុតាងក៏ដោយ ។ ទីបី គឺគណៈកម្មការស្វែងរកការពិតជួនកាលក៏ដូចជាករណីគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សាដែរគឺ មានអំណាចបញ្ជូនខ្លួនជនសង្ស័យដែលមិនព្រមសហការនិងមិនមានចិត្តស្មោះត្រង់ឲ្យតុលាការកាត់ទោសបាន ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមិនមែនជាតុលាការ ហើយក៏មិនមែនជាភ្នាក់ងារអនុវត្តច្បាប់ដែរ ដូច្នេះមជ្ឈមណ្ឌលឯកសារកម្ពុជាក៏មិនមានអំណាចបែបនេះដែរ ។

ទោះជាមានការខុសប្លែកគ្នាពីគណៈកម្មការស្វែងរកការពិតយ៉ាងនេះក៏ដោយ មជ្ឈមណ្ឌលឯកសារកម្ពុជាតែងតែធ្វើការដើម្បីសម្រេចនូវការរសាយចិត្តនៅក្នុងប្រទេសកម្ពុជា ។ ជាការពិបាកក្នុងការប៉ាន់ស្មានអំពីប្រភេទនៃ "ការផ្លាស់ប្តូរដែលនាំឲ្យមានអារម្មណ៍ធូរស្រាល" ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាអាចនាំមកដោយខ្លួនឯងផ្ទាល់ ពោលគឺការលាតត្រដាងដ៏គួរឲ្យរំភើបដែលមានឥទ្ធិពលយ៉ាងសំខាន់ដល់ប្រទេសជាតិទាំងមូល ។ កិច្ចការជាច្រើនដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែអនុវត្តអាចមានឥទ្ធិពលទៅលើប្រជាជនកម្ពុជាក្នុងទ្រង់ទ្រាយតូចតែប៉ុណ្ណោះ ។ ឧទាហរណ៍ជាក់ស្តែង ការងារស្វែងរកគ្រួសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានផ្តល់នូវការបន្ធូរអារម្មណ៍សម្រាប់បុគ្គលមួយចំនួនដែលបានទទួលពត៌មានទាក់ទងនឹងវាសនារបស់សាច់ញាតិរបស់ខ្លួន ។ កន្លងទៅថ្មីៗនេះ ជនជាតិខ្មែរកាត់បារាំងម្នាក់មកពីប្រទេសស៊ុយអែដ ជាមួយម្តាយដែលជាជនជាតិបារាំងបានមកដល់មជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីស្វែងរកស្វាមីនិងឪពុករបស់ខ្លួនដែលជាអ្នកការទូតជនជាតិខ្មែរម្នាក់បានបាត់ខ្លួននៅក្នុងសម័យបដិវត្តន៍ខ្មែរក្រហម ។ ជាង១ភាគ៤នៃសតវត្សរ៍ទៅហើយដែលអ្នកម្តាយនិងកូនមានមន្ទិលសង្ស័យ មានការព្រួយបារម្ភនិងមានភាពមិនប្រាកដប្រជា ថាតើមានអ្វីកើតឡើងចំពោះស្វាមីនិងឪពុក ក្រោយពីគាត់វិលមកកម្ពុជាវិញដើម្បីកសាងប្រទេសជាតិ ។ អ្វីដែលអ្នកទាំងពីរបានដឹង គឺស្វាមីនិងឪពុកបានបាត់ស្រមោលឈឹងតែម្តង ។ ឯកសារតម្កល់ទុកនៅមជ្ឈមណ្ឌលឯកសារកម្ពុជាបង្ហាញថា ការពិតគាត់ត្រូវបានបញ្ជូនមកសម្លាប់ចោលនៅមន្ទីរស-២១(គុកទួលស្លែង) ។ ក្រោយពីកូននិងម្តាយដឹងរឿងពិតអស់ហើយ អ្នកទាំងពីរពិតជាទទួលអារម្មណ៍ភ្លាមនិងគួរឲ្យកត់សម្គាល់នៅក្នុងឆាកជីវិតរបស់គាត់ ។ តាមពិតទៅអ្នកទាំងពីរមិនសប្បាយចិត្តចំពោះការពើបប្រទះពត៌មានបែបនេះទេ ក៏ប៉ុន្តែការដឹងប្រសើរជាងការដែលមិនបានដឹង ។ ទោះការពិតនោះជាដំណឹងល្អ ឬអាក្រក់ក្តី វានៅតែអាចធ្វើឲ្យជនរងគ្រោះទាំងនោះទទួលបាននូវការរសាយចិត្តពីភាពមិនប្រាកដប្រជាដែលដក់ជាប់នៅក្នុងអារម្មណ៍អស់រយៈពេលជាច្រើនឆ្នាំមកហើយ ដូចក្នុងករណីជនបរទេសពីររូបខាងលើស្រាប់ ។ យើងបានឃើញបញ្ហាដូចគ្នានេះជាច្រើនករណីនៅមជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងដែលយើងតែងតែនិយាយថា "ការពិតអាចធ្វើឲ្យអ្នកមានអារម្មណ៍ធូរស្បើយលែងខ្វល់ខ្វាយ" ។

ការងារធំៗទាំងឡាយរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏មានលក្ខណៈប្រហាក់ប្រហែលនេះដែរ ។ ជាក់ស្តែងការធ្វើផែនទីរណ្តៅសាកសពនៃអំពើប្រល័យពូជសាសន៍មានឥទ្ធិពលដល់ការ

ផ្លាស់ប្តូរផ្នែកចិត្តសាស្ត្រទៅលើប្រជាជនកម្ពុជាមួយចំនួនដែលកន្លងមកមិនជឿថា មានការកាប់សម្លាប់ខ្មែរយ៉ាងរង្គាលដូច្នេះទេ ។ ប៉ុន្តែនៅពេលដែលប្រជាជនទាំងនោះបានឃើញរណ្តៅសាកសពរាយប៉ាយនៅពាសពេញផ្ទៃប្រទេសនៅក្នុងដែនទីដែលជាសញ្ញាណបញ្ជាក់អំពីការសម្លាប់ឬមួយរង្វាស់ លក្ខណៈជាប្រព័ន្ធពេលនោះ ប្រជាជនកម្ពុជានឹងទទួលស្គាល់ថានេះជាការពិតមិនខាន ។ ការពិតអំពីអ្វីដែលមនុស្សអាចធ្វើចំពោះមនុស្សម្នាក់ទៀត នឹងធ្វើឲ្យយើងមានអារម្មណ៍ធូរស្បើយលែងខ្វាយខ្វល់ ហើយធ្វើឲ្យចង់ស្តាប់នូវការនិយាយកាន់តែលម្អិតអំពីសារជាតិរបស់យើង ។ ចំពោះកម្មវិធីសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌល


ប្រារព្ធពិធីបង្សុកូលជូនវិញ្ញាណក្ខន្ធជនរងគ្រោះក្នុងរបបខ្មែរក្រហម

ឯកសារកម្ពុជាវិញ បន្ទាប់ពីបានអានសៀវភៅមួយក្បាលសរសេរដោយ អៀ ម៉េងទ្រី និង សឹម សុរិយ៉ា ដែលមានចំណងជើងថា "ជនរងគ្រោះឬជនដៃដល់" អ្នកអាននឹងយល់ឃើញភ្លាមថា គ្រប់ជនជាតិខ្មែរទាំងអស់ សុទ្ធតែជាជនរងគ្រោះនៃរបបខ្មែរក្រហម សូម្បីតែខ្មែរក្រហមខ្លួនឯងក៏ដោយ ។ ការយល់ឃើញបែបនេះ អាចធ្វើឲ្យប្រជាជនខ្មែរទាំងអស់ចាប់ផ្តើមផ្សះផ្សាគ្នាឡើងវិញជាមួយអ្នកដែលខ្លួនបានចាត់ទុកថាជាខ្មាំងគួរឲ្យស្អប់ខ្ពើមនិងគួរឲ្យខ្លាចពេញមួយជីវិតទៅហើយ ។ ការពិតនឹងធ្វើឲ្យអ្នកទាំងនោះមានអារម្មណ៍ធូរស្បើយលែងខ្វាយខ្វល់រួមរស់ជាមួយគ្នាក្រោយពីមានការមិនចូលចិត្តគ្នាអស់រយៈពេលដ៏យូរ ។



ចំពោះទស្សនាវដ្តីស្វែងរកការពិតវិញនោះ ដោយសារការផ្តល់ព័ត៌មានពីអំពើប្រល័យពូជសាសន៍ទៅកាន់ប្រជាជនទូទាំងប្រទេស ទស្សនាវដ្តីនេះអាចពន្យល់យ៉ាងងាយអំពីរបបខ្មែរក្រហមដោយបង្ហាញឲ្យឃើញថា ខ្មែរក្រហមមិនមែនជាព្រះអាទិទេពឬបិសាចអ្វីទេ ។ ខ្មែរក្រហមទាំងនោះជាមនុស្សសាមញ្ញដូចមនុស្សគ្រប់គ្នាអ៊ីចឹងដែរ ពោលគឺជាមនុស្សដែលប្រព្រឹត្តអំពើមិនល្អហើយត្រូវបានដឹកនាំទៅរកផ្លូវខុសពីសំណាក់មេដឹកនាំឆ្គួតលីលាមួយចំនួនតូច ។ ជនដែលត្រូវបោកប្រាស់នាំទៅរកផ្លូវខុស យើងមិនត្រូវស្អប់ខ្ពើមនិងភ័យខ្លាចនោះទេ ។ អ្វីដែលអ្នកទាំងនោះត្រូវការ គឺការអប់រំ (មិនមែនជាការបន្ទោស ឬដាក់កំហុស) និងនាំឲ្យចូលមករួមរស់នៅក្នុងសង្គមជាតិវិញ ។ ការពិតនឹងធ្វើឲ្យមានអារម្មណ៍ធូរស្បើយលែងខ្វាយខ្វល់ក្នុងការរួបរួមផ្សះផ្សាជាមួយអ្នកផ្សេងទៀត ។

កម្មវិធីជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្តល់នូវការឆ្លុះបញ្ចាំងបន្ថែមទៀតអំពីវិធីក្នុងការជំរុញឲ្យមានការរសាយចិត្តនិងការបង្រួបបង្រួមផ្សះផ្សា ។ យើងបានខិតខំស្វែងរកធ្វើសម្ភាសន៍កម្មាភិបាលខ្មែរក្រហមដែលធ្វើការងារសន្តិសុខ ក្នុងគោលបំណងប្រមូលផ្តុំចងក្រងជាទិន្នន័យទូលំទូលាយមួយផ្តល់នូវព័ត៌មានអំពីអ្វីដែលបានកើតឡើងក្នុងរបបផ្តាច់ការដែលគួរឲ្យរន្ធត់បំផុតរបស់ ប៉ុល ពត ។ យើងទទួលបាននូវការរីកចម្រើនយ៉ាងច្រើននៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះដោយបានធ្វើការជាមួយអ្នកផ្តល់សម្ភាសន៍ចំនួន៧៧២នាក់ ។ ក្រៅពីនោះយើងបានប្រមែប្រមូលចងក្រងទៅជាវ៉ូលូមឯកសារទាក់ទងនឹងបុគ្គលដែលត្រូវធ្វើសម្ភាសន៍ដោយក្រុមជំរុញឲ្យមានការទទួលខុសត្រូវមានចំនួនរហូតដល់២៨០០ទំព័រ ។ ឯកសារទាំងនេះនឹងចេញជាសាច់ការ នៅពេលដែលដំណើរនីតិវិធីព្រហ្មទណ្ឌជាផ្លូវការត្រូវបានចាប់ផ្តើម ព្រោះឯកសារនេះលាតត្រដាងនូវ

ខ្សែសង្វាក់នៃការបញ្ឈប់យ៉ាងលម្អិតស្តីអំពីការអនុវត្តអំពើប្រល័យពូជសាសន៍ ។ ពត៌មានទាំងនេះនឹងធ្វើឲ្យមានអារម្មណ៍ធូរស្បើយលែងខ្វាយខ្វល់មើលឃើញនូវប្រវត្តិសាស្ត្រពិតនៃរបបខ្មែរក្រហមដែលជាការឆ្លុះបញ្ចាំងនូវការពិតទាក់ទងទៅនឹងអ្នកដែលនៅតែបន្តបដិសេធថា ខ្លួនមិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍សោះនោះ ។

ឧទាហរណ៍ចុងក្រោយមួយទៀតនៃកិច្ចខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក្នុងការជំរុញឲ្យមានការរសាយចិត្តនិងការផ្សះផ្សា គឺកិច្ចសហការជាមួយសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។ យើងកំពុងតែធ្វើការជាមួយនាយកសារមន្ទីរទួលស្លែងរៀបចំតាំងពិព័រណ៍ក្នុងលក្ខណៈទំនើបប្រែក្លាយសារបែបគរុកោសល្យដែលមាននៅក្នុងសាច់ពិព័រណ៍ផ្ទាល់ ដើម្បីសង្កត់ធ្ងន់ទៅលើបញ្ហាបង្រួបបង្រួមផ្សះផ្សាជាតិ ។ ឧទាហរណ៍ យើងបានបង្កើតជាការិយាល័យអានឯកសារប្រចាំនៅសារមន្ទីរទួលស្លែងសម្រាប់ភ្ញៀវមកទស្សនា មានកុំព្យូទ័រនិងម៉ាស៊ីនម៉ៃក្រូហ្វីល ដើម្បីបម្រើដល់សាធារណជនដែលអញ្ជើញចូលមើលឯកសារដែលយើងប្រមែប្រមូលបាន ។ យើងក៏បានជួយរុះរើផែនទីដែលមានរូបលលាដ៏ក្បាលខ្មោច ហើយជំនួសវិញដោយផែនទីវាលពិឃាតដែលរចនាឡើងតាមលក្ខណៈវិទ្យាសាស្ត្រទំនើបតាមប្រព័ន្ធកំណត់ទីតាំងដោយផ្កាយរណប ។ ដោយមានជំនួយមកពីលោក ឫទ្ធី ប៉ាន់ ជាអ្នកផលិតខ្សែភាពយន្តសារមន្ទីរផ្តល់នូវការបញ្ចាំងខ្សែភាពយន្តជារៀងរាល់ថ្ងៃ ។ ខ្សែភាពយន្តនោះមានចំណងជើងថា “ហ្វូត បុប្ផាណា: សោកនាដ្យកម្មមួយរបស់កម្ពុជា” ដែលជារឿងមួយគួរឲ្យសង្វេគ ទាក់ទងនឹងស្វាមីភរិយាមួយគូ ដែលត្រូវបានសម្លាប់នៅសារមន្ទីរទួលស្លែងពីបទ “លួចស្រលាញ់គ្នា” ។ ការកែលម្អរបស់យើងនាពេលថ្មីៗនេះដោយមានកិច្ចសហការជាមួយអ្នកថតរូប ហេង ស៊ីនិត បានឆ្លុះបញ្ចាំងពីរូបភាពរបស់អតីតបុគ្គលិកគុកទួលស្លែង ព្រមជាមួយនឹងការឆ្លុះបញ្ចាំងអំពីការពិតថា តើបទពិសោធន៍អតីតបុគ្គលិកគុកមានផលប៉ះពាល់យ៉ាងណាខ្លះដល់ជីវិតជាក់ស្តែងរបស់គេសព្វថ្ងៃនេះ ។ កម្មវិធីប្រហាក់ប្រហែលគ្នានេះកំពុងតែដំណើរការហើយយើងសង្ឃឹមថា ការឆ្លុះបញ្ចាំងនូវការពិតដូចដែលស្តែងតាមការតាំងពិព័ណ៌ថ្មីនេះនឹងជួយធ្វើឲ្យអ្នកមកទស្សនាកុំឲ្យមានអារម្មណ៍ថា សេចក្តីស្អប់គឺជាចម្លើយទៅនឹងរឿងរ៉ាវដ៏គួរឲ្យរន្ធត់នៃរបបខ្មែរក្រហម ។

ឥទ្ធិពលរសាយចិត្តដែលចេញពីការពិត សបញ្ជាក់ឲ្យឃើញអំពីគោលដៅការងាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ ទោះជាជម្រើសចង់បានតុលាការដ៏គួរឲ្យទុកចិត្តបាន នៅតែស្ថិតនៅឆ្ងាយក៏ដោយ ក៏អ្វីដែលមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងធ្វើគឺមានគោលបំណងនាំមកនូវ “ការផ្លាស់ប្តូរភ្លាមៗនិងគួរឲ្យកត់សម្គាល់” ដល់ប្រទេសកម្ពុជានិងដល់ប្រជាជនកម្ពុជាម្តងម្នាក់ៗ ហើយបន្តិចម្តងៗ ដល់ទីបញ្ចប់អាចជួយសម្រួលដល់ការផ្សះផ្សាជាតិនៅគ្រប់ទីកន្លែងក្នុងប្រទេសកម្ពុជា ។ វាមិនអាចកើតឡើងក្នុងមួយប៉ព្រិចភ្នែកបានទេ ហើយក៏គ្មានវិធីណាដែលអាចផ្លាស់ប្តូរទស្សនៈរបស់ជនជាតិខ្មែរដែលមើលបំណាំខ្លួនឯង និងមើលបំណាំអ្នកដទៃភ្លាមៗនោះដែរ ។ ប៉ុន្តែ តាមរយៈការបង្ហាញនូវការពិតតាមលក្ខណៈស្រាវជ្រាវជាវិទ្យាសាស្ត្រ អំពីការប្រល័យពូជសាសន៍កម្មវិធីទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានដើរតួនាទីជា“គណៈកម្មការស្វែងរកការពិត” មួយ ដែលទាញយកបញ្ហានេះចេញពីអ្នកនយោបាយដែលតែងតែកេងយកផលប្រយោជន៍ពីប្រជាជនដើម្បីបម្រើផលប្រយោជន៍របស់ខ្លួន និងផ្តល់ឲ្យប្រជាជនកម្ពុជាវិញនូវបំណាកស្រាយមួយដែលប្រជាជនទូទៅងាយយល់និងចាប់បាន ។ បន្តិចម្តងៗ ប្រជាជនកម្ពុជាអាចទទួលស្គាល់នូវការពិតដោយស្ងៀមស្ងាត់នៅក្នុងចិត្ត ហើយនៅទីបញ្ចប់ប្រទេសកម្ពុជាទាំងមូល អាចសម្រេចបាននូវការផ្សះផ្សាជាតិដ៏ “ពិតប្រាកដ” មួយ ។

**មជ្ឈមណ្ឌលឯកសារកម្ពុជា**

## ពន្យល់ពាក្យខ្មែរក្រហម

- **សហភាព :** សភាពរួបរួមជាមួយគ្នា ។
- **នយោបាយ :** ឧបាយជាគ្រឿងដឹកនាំ ។
- **កុសលធម៌ :** សេចក្តីសន្តោសករុណា ។
- **ឧបសគ្គៈ** គ្រឿងរារាំងដំណើរ ។

**(ដកស្រង់ពីសៀវភៅកំណត់ហេតុ ប៊ុន ធឿន)**

# តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម

## សន្និសីទកាសែតរបស់ឯកឧត្តម សុខ អាន


ឯកឧត្តម សុខ អាន

*ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៣*

**ឯកឧត្តម សុខ អាន៖** ថ្ងៃនេះ គណៈប្រតិភូជាន់ខ្ពស់ដែលដឹកនាំដោយសម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា បានត្រឡប់មកវិញពីការចូលរួមសន្និសីទកំពូលនៃចលនាមិនចូលបក្សសម្ព័ន្ធលើក១៣ ដែលបានប្រព្រឹត្តទៅប្រាំថ្ងៃកន្លងទៅហើយ នៅទីក្រុងគូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី ។ កាលពីលើកមុនសន្និសីទ កំពូលបានប្រព្រឹត្តទៅនៅប្រទេសអាហ្វ្រិកខាងត្បូង ហើយលើកទី១៣នេះ បានប្រព្រឹត្តទៅនៅទីក្រុងគូឡាឡាំពួរប្រទេសម៉ាឡេស៊ី ហើយលើកក្រោយទៀត បីឆ្នាំទៅមុខទៀតគឺនៅឆ្នាំ២០០៦ សន្និសីទកំពូលនឹងប្រព្រឹត្តទៅនៅប្រទេសគុយបា ។ នេះជាដំណើរការជាបន្តបន្ទាប់នៃចលនាមិនចូលបក្សសម្ព័ន្ធ ។ ជារៀងរាល់លើក១៨ខែ ក្រោយកិច្ចប្រជុំសន្និសីទកំពូលដែលចូលរួមដោយថ្នាក់ប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាលនោះ ១៨ខែក្រោយ នឹងមានការប្រជុំថ្នាក់រដ្ឋមន្ត្រីការបរទេស ដើម្បីពិនិត្យនិងជំរុញការអនុវត្តសេចក្តីសម្រេចទាំងឡាយដែលបានធ្វើឡើងនៅក្នុងឱកាសសន្និសីទកំពូល ។ នៅក្នុងសន្និសីទកំពូលលើកនេះ យើងអបអរសាទរដែលឃើញថាចលនាមិនចូលបក្សសម្ព័ន្ធនៅតែមានលក្ខណៈសកម្ម ហើយដែលប្រកាន់ខ្ជាប់នូវគោលការណ៍និងគោលនយោបាយរបស់ខ្លួនទាំងផ្នែកនយោបាយនិងផ្នែកផ្សេងៗទៀត ដែលទន្ទឹមនឹងនេះគឺសន្និសីទកំពូលលើកនេះប្រើពាក្យថា Revitalization នេះបានន័យថា ធ្វើឲ្យសកម្មថែមទៀតនូវចលនាមិនចូលបក្សសម្ព័ន្ធនៅក្នុងការប្រជុំលើកនេះសន្និសីទកំពូលលើកទី១៣ បានចេញនូវឯកសារសំខាន់ៗ ៤ នោះគឺសេចក្តីថ្លែងការណ៍ទីក្រុងគូឡាឡាំពួរ ១ ដែលជាអត្ថបទធំសំខាន់ជាងគេ ហើយក្រៅពីនេះ គឺមានសេចក្តីថ្លែងការណ៍ស្តីពីបញ្ហាអ៊ីរ៉ាក់ បញ្ហាប៉ាឡេស្ទីន ហើយនិងសេចក្តីថ្លែងការណ៍ចុងក្រោយមួយទៀតដែលសរុបពីបញ្ហាផ្សេងៗទៀត រួមទាំងបញ្ហាសេដ្ឋកិច្ច សង្គមកិច្ច នៅក្នុងពិភពលោក ។ នៅក្នុងចំណុចសំខាន់ យើងឃើញថា ចលនាមិនចូលបក្សសម្ព័ន្ធផ្តោតអារម្មណ៍ខ្លាំងទៅលើពាក្យ Revitalization គឺការធ្វើឲ្យចលនាកាន់តែសកម្មថែមទៀតនេះ ។ ដោយការចាប់អារម្មណ៍រួមគឺមើលឃើញថា ការធ្វើសកម្មថែមទៀតនេះ នេះជាចំណុចដែលមានសេចក្តីសង្ឃឹមនៅក្នុងចលនាដែលស្ថិតនៅក្រោមការដឹកនាំនិងឋានៈជាអ្នកសម្របសម្រួល និងជាអ្នកនាំពាក្យរបស់ចលនានៃឯកឧត្តមនាយករដ្ឋមន្ត្រី មហាធៀរ មហាម៉េដ នៃប្រទេសម៉ាឡេស៊ី ហើយទន្ទឹមនឹងនេះក៏មានការខិតខំនិងពង្រឹករចនាសម្ព័ន្ធរបស់ចលនាមិនចូលសម្ព័ន្ធ គឺជាឧទាហរណ៍បង្កើតឡើងនូវគណៈកម្មាធិការនៅក្នុងក្របខ័ណ្ឌនូវអ្វីដែលគេហៅថា ការិយាល័យសម្របសម្រួល *Coordinating Bureau* គឺមានគណៈកម្មការខាងនយោបាយ គណៈកម្មការខាងសេដ្ឋកិច្ច និងមានគណៈកម្មការខាងសង្គមកិច្ចដែលយើងឃើញថាជាការខិតខំរបស់ចលនាដើម្បីធ្វើឲ្យការផារខាងផ្នែកសេដ្ឋកិច្ច ខាងផ្នែកអភិវឌ្ឍន៍ ខាងផ្នែកកាត់បន្ថយភាពក្រីក្រ ខាងសង្គមកិច្ច ជារួមរបស់ពិភពលោកឲ្យកាន់តែលក្ខណៈសកម្មថែមទៀត នៅក្នុងក្របខ័ណ្ឌមិនចូលបក្សសម្ព័ន្ធ ព្រោះក៏មានយោបល់ជារួមដែរថា ចលនាបានខិតខំបញ្ជាក់ជំហរយ៉ាងច្បាស់ប្រកាន់ជំហរយ៉ាងច្បាស់នៅក្នុងវិស័យនយោបាយ ប៉ុន្តែជាការល្អកាន់តែល្អថែមទៀត បើចលនាមិនចូលបក្សសម្ព័ន្ធខិតខំប្រឹងប្រែងថែមទៀតធ្វើឲ្យកាន់តែច្បាស់ឡើងនៅក្នុងវិស័យផ្នែកការផារសេដ្ឋកិច្ច ការផារពាណិជ្ជកម្ម ការផារអភិវឌ្ឍន៍ ការផារកាត់

បន្ថយភាពក្រីក្រនេះ ។ ដូច្នេះនៅលើកនេះយើងថា ចំណុចដែលថ្មី គឺការផ្តោតការយកចិត្តទុកដាក់នៅលើចំណុចដែលខ្ញុំបានលើកឡើងនេះ ។ ក្រៅពីការដែលចូលរួមនៅក្នុងសន្និសីទកំពូលលើកទី ១៣ នេះគឺប្រមុខរាជរដ្ឋាភិបាល សម្តេច ហ៊ុន សែន ក៏បានធ្វើការជួបប្រាស្រ័យមួយចំនួន ។ ហើយក្នុងនេះខ្ញុំគិតថា ឯកឧត្តមអស់លោកមានពត៌មានជាបន្តបន្ទាប់ដែរ អ៊ីចឹងខ្ញុំមិនចាំបាច់ធ្វើអត្ថាធិប្បាយវែងទេ ខ្ញុំរង់ចាំសំណួរពីអស់លោក លោកស្រីវិញ ។ សូមអញ្ជើញ!

**អ្នកសួរៈ** ឯកឧត្តមអាចបញ្ជាក់សេចក្តីសម្រេចស្តីពីការជួបចរចារវាងសម្តេច ហ៊ុន សែន ជាមួយនាយករដ្ឋមន្ត្រីថៃបានទេ?

**ឯកឧត្តម សុខ អានៈ** ខ្ញុំគិតថាអស់លោកពិតជាសួរពីបញ្ហានេះ ។ ខ្ញុំគិតថានេះជាចំណុចសំខាន់មួយដែរ ព្រោះថា ក្នុងរយៈពេលជិតមួយខែក្រោយខបទ្វវហេតុថ្ងៃទី២៩កន្លងមកនេះ ដែលជាលើកទីមួយដែលប្រមុខរាជរដ្ឋាភិបាលទាំងពីរបានជួបប្រាស្រ័យដោយផ្ទាល់នៅមុននេះយើងក៏មានការជួបប្រាស្រ័យដែរនូវកម្រិតរដ្ឋមន្ត្រីនិងកម្រិតគណៈប្រតិភូជំនាញផ្សេងៗ ។ ជាពិសេសយើងឃើញថាគណៈប្រតិភូថៃបានអញ្ជើញមកជាបន្តបន្ទាប់នៅក្នុងដំណើរការដែលយើងហៅថា ដំណើរការប្រក្រតីនីយកម្មនៃទំនាក់ទំនងកម្ពុជា-ថៃ ។ ខ្ញុំជឿជាក់ថា អស់លោកលោកស្រីជ្រាបហើយថា រហូតមកដល់មុនថ្ងៃទី២៩ កន្លងមកនេះ គឺយើងថា ទំនាក់ទំនងកម្ពុជា-ថៃគឺមានកម្រិតខ្ពស់ បើប្រៀបធៀបទៅនឹងរយៈមុនៗរវាងប្រជាជននិងរវាងរាជរដ្ឋាភិបាលទាំងពីរ ប៉ុន្តែខបទ្វវហេតុថ្ងៃទី២៩ បានធ្វើឲ្យមានការលំបាកច្រើននៅក្នុងទំនាក់ទំនងនេះ ។ នៅក្នុងការជួបប្រាស្រ័យនេះប្រមុខរាជរដ្ឋាភិបាលទាំងពីរលោកផ្តោតការពិភាក្សាទៅលើការដែលយើងខំយ៉ាងណាជំរុញដំណើរការប្រក្រតីនីយកម្មទំនាក់ទំនងនេះឲ្យបានល្អប្រសើរ ដើម្បីស្តារទំនាក់ទំនងទ្វេភាគីនេះឲ្យមានលក្ខណៈល្អប្រសើរឡើងវិញដូចមុនថ្ងៃទី២៩ មករា កន្លងមក ។ ដូច្នេះហើយការពិភាក្សាផ្តោតទៅលើចំណុចជាក់ស្តែង ឧទាហរណ៍ថា ឥឡូវនេះ ព្រះរាជាណាចក្រថៃ រាជរដ្ឋាភិបាលថៃបានបញ្ជូនភារធារីត្រឡប់មកទីក្រុងភ្នំពេញវិញហើយ ។ ដូច្នេះ គិតថាយើងក៏បានពិភាក្សាគ្នាផងដែរ អំពីការសម្រួលទំនាក់ទំនងធ្វើដំណើររវាងអ្នកដំណើរ ជាពិសេសគឺពីភ្នំពេញទៅបាងកក តាមរយៈការផ្តល់ទិដ្ឋាការ ត្រង់ចំណុចនេះមានលទ្ធផលជាវិជ្ជមាន ហើយចំណុចផ្សេងទៀត ឧទាហរណ៍បញ្ហាពាណិជ្ជកម្មនៅតាមព្រំដែន ថ្នាក់ដឹកនាំទាំងពីរក៏បានឯកភាពគ្នាដែរថា ជំរុញពាណិជ្ជកម្ម ទំនាក់ទំនងពាណិជ្ជកម្មនេះឲ្យបានល្អប្រសើរ នេះគឺនៅលើមូលដ្ឋានគោរពផលប្រយោជន៍គ្នាទៅវិញទៅមកទាំងសងខាង ។ ក្រៅពីនេះក៏មានបញ្ហាស្តារការខូចខាតរបស់ក្រុមហ៊ុនថៃមួយចំនួនដែលបានទទួលការខូចខាតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយចំណុចនេះយើងក៏បានចាត់តាំងរួចហើយនូវគណៈកម្មការទាំងបួន ហើយគណៈកម្មការក៏បានធ្វើការ ហើយខ្លួនខ្ញុំជាប្រធានគណៈកម្មការប្រក្រតីនីយកម្មនៃគម្រោងនេះដែរ សមភាគីថៃមានឯកឧត្តម ស៊ូរ៉ាគៀត រដ្ឋមន្ត្រីក្រសួងការបរទេស លោកក៏ជាអ្នកទទួលខុសត្រូវនៅក្នុងការងារប្រក្រតីនីយកម្មទំនាក់ទំនងនេះដែរ ។ ដូច្នេះការជួបប្រាស្រ័យនេះជាជំហានមួយដ៏សំខាន់នៅក្នុងដំណើរការប្រក្រតីនីយកម្មទំនាក់ទំនងកម្ពុជា-ថៃ ។

**អ្នកសួរៈ** ជារួមការសងការខូចខាតភាគីទាំងពីរឯកភាពគ្នាជម្រើសសងដោយទឹកប្រាក់ ឬក៏ជាបញ្ហាពន្ធដារនាំចូល?

**ឯកឧត្តម សុខ អានៈ** បាទ នេះជាបញ្ហាដែលជាការងារជំនាញរបស់គណៈកម្មការមួយដែលដឹកនាំដោយឯកឧត្តម ព្រំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ដែលកំពុងតែដំណើរការ ។ ដូច្នេះ គណៈកម្មាធិការធ្វើការស៊ើជម្រៅរបៀបថា តើយើងបង្កលក្ខណៈឲ្យក្រុមហ៊ុនថៃអាចចាប់ផ្តើមការងាររបស់គេបានល្អប្រសើរវិញ ជាពិសេសការងារដែលគេវិនិយោគនៅក្នុងព្រះរាជាណាចក្រកម្ពុជានេះ គឺយើងត្រូវធ្វើរបៀបណានោះ គណៈកម្មការទាំងពីរនឹងជជែកគ្នាឲ្យបានហ្មត់ចត់ ហើយយើងក៏បានបញ្ជាក់ដែរថាយើងនឹងជំរុញឲ្យគណៈកម្មការធ្វើឲ្យបានឆាប់ ។

**អ្នកសួរៈ** សម្តេចនាយករដ្ឋមន្ត្រីបានប្រាប់ភាគីថៃថា នឹងចាត់វិធានការក្នុងការស៊ើបអង្កេត?

**ឯកឧត្តម សុខ អានៈ** យើងមិនទាន់បានចូលលម្អិតទៅដល់នោះទេ គ្រាន់តែមានការឯកភាពជាគោលការណ៍ដូចខ្ញុំលើកប្រាប់ពីខាងដើម នៅក្នុងការជំរុញដំណើរការប្រក្រតីនីយកម្ម

ហើយក៏មានការយោលទៅលើចំណុចដែលថា យើងគួរតែសហការគ្នាដើម្បីកុំឲ្យឧបទ្ទវហេតុបៀបនេះកើតឡើងម្តងទៀតនៅពេលអនាគត ។

**អ្នកសួរ:** កិច្ចប្រជុំគណៈកម្មការ តើភាគីកម្ពុជាជាអ្នកស្នើទៅមុន ឬក៏ភាគីថៃជាអ្នកស្នើមកមុន បង្កើតគណៈកម្មការស៊ើបអង្កេតនេះ?

**ឯកឧត្តម សុខ អាន:** យើងបានបង្កើតតាំងពីដើមទី ។

**អ្នកសួរ:** ខាងភាគីថៃ?

**ឯកឧត្តម សុខ អាន:** ខ្ញុំនិយាយថាភាគីកម្ពុជាទេ ខាងថៃលោកបានសម្របសម្រួលតាមការងារនេះដែរដើម្បីឲ្យការងារនេះបានរលូន មានលក្ខណៈរលូនលឿនទៅមុខ ។

**អ្នកសួរ:** ម្សិលមិញខ្ញុំបានអានកាសែត ឌឺណេសិន របស់ថៃ សម្តេចបានអញ្ជើញភាគីថៃមកប្រទេសកម្ពុជា ។

**ឯកឧត្តម សុខ អាន:** ដូចខ្ញុំនិយាយថា យើងអាចធ្វើសហប្រតិបត្តិការលើគ្រប់វិស័យ ពាក្យសហប្រតិបត្តិការមិនមែនបានន័យថា ទាល់តែយើងអត់សមត្ថភាព ទើបយើងធ្វើសហប្រតិបត្តិការទេ ។ ពាក្យថាធ្វើសហប្រតិបត្តិការមានន័យទូលំទូលាយណាស់ យើងអាចធ្វើសហប្រតិបត្តិការគ្នាលើគ្រប់វិស័យ ។

**អ្នកសួរ:** ម្សិលមិញ គេបានចុះផ្សាយពីការសងការខូចខាតដល់ភាគីថៃ?

**ឯកឧត្តម សុខ អាន:** បាទនេះជាការពិតហើយ ប៉ុន្តែយើងបានឆ្លើយតបតាំងពីដើមទីមក គឺយើងមានអនុស្សារណៈរបស់យើងដែលបានឆ្លើយតបទៅនឹងចំណុចទាំងបី ហើយរហូតមកដល់ពេលនេះគឺតាំងពីដើមទីមក ការឆ្លើយតបរបស់យើងមានការពេញចិត្តទៅវិញទៅមកទាំងសងខាងលើចំណុចទាំងបី បើអ៊ីចឹងពិនិត្យទៅលើខ្លឹមសារអនុស្សារណៈថៃនោះ យើងឃើញថានេះមិនមែនជាបញ្ហាទៀតទេ ។

**អ្នកសួរ:** ឯកឧត្តមមានបានឮកាសែត ឌឺណេសិន របស់ថៃនិយាយថា នាយករដ្ឋមន្ត្រីថៃចង់បញ្ជូនឧត្តមសេនីយ៍ឲ្យមកស៊ើបអង្កេតនៅកម្ពុជា?

**ឯកឧត្តម សុខ អាន:** ខ្ញុំគិតថាដំណើរការប្រក្រតីនីយកម្មដូចខ្ញុំជម្រាបថា យើងប្រព្រឹត្តទៅជាជំហានៗសមស្របទៅតាមសភាពការណ៍ ។ ដូច្នេះការផ្លាស់ប្តូរពាណិជ្ជកម្មនៅតាមព្រំដែនវាជាចំណុចមួយ ជាជំហានមួយនៃដំណើរការប្រក្រតីនីយកម្ម ហើយឯកឧត្តម ថាក់ស៊ីន ក៏មិនមានចំណុចអ្វីដែលទៅទប់ស្កាត់ដំណើរការផ្លាស់ប្តូរពាណិជ្ជកម្មនៅតាមព្រំដែននោះដែរ ។ ចំណុចធំដែលភាគីទាំងពីរយកចិត្តទុកដាក់ គឺការធ្វើយ៉ាងម៉េចកុំឲ្យមានឧបទ្ទវហេតុបៀបនេះកើតឡើងជាថ្មីទៀត ហើយចំនួនដែលពាក់ព័ន្ធទៅនឹងពាណិជ្ជកម្មនោះក៏ជាចំណុចដែលពាក់ព័ន្ធទៅនឹងបញ្ហានេះដែរ គឺថា ពាណិជ្ជករទាំងសងខាង ប្រជាជនទាំងសងខាងដែលឆ្លងដែនទៅវិញទៅមកនោះ គឺធ្វើយ៉ាងម៉េចឲ្យមានសុវត្ថិភាពនិងមានសន្តិសុខគ្រប់គ្រាន់ នោះដំណើរការនឹងប្រព្រឹត្តទៅនឹងត្រូវស្តារឡើងវិញជាធម្មតា ទៅតាមការរីកវិវត្តនៃសភាពការណ៍ រួមដូចចំណុចដែលខ្ញុំបានលើកឡើងនេះ ។

**អ្នកសួរ:** ឯកឧត្តម នៅពេលដែលសម្តេចអញ្ជើញទៅនោះ សម្តេចបានថ្លែងយ៉ាងម៉េចនូវជំហររបស់កម្ពុជាចំពោះបញ្ហាអ៊ីរ៉ាក់?

**ឯកឧត្តម សុខ អាន:** ជំហររបស់យើងក៏ដូចជាជំហររួមរបស់ចលនាមិនចូលសម្ព័ន្ធដូច្នេះដែរគឺជាពិសេសយើងបានផ្តោតការយកចិត្តទុកដាក់ទៅលើការរីកចម្រើនរបស់សភាពការណ៍ជម្រាបជូន ចែករំលែកទស្សនៈការយល់ឃើញរបស់យើងសង្ឃឹមថានេះជាចំណុចរួមដែលចលនាមិនចូលបក្សសម្ព័ន្ធបានលើកឡើង ។

**អ្នកសួរ:** ឯកឧត្តមបានទទួលលិខិតពីឯកឧត្តមអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ ស្តីអំពីការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម?

**ឯកឧត្តម សុខ អាន:** អរគុណ យើងបានទទួលលិខិតរបស់ឯកឧត្តម កូហ្វីអាណាន់ ផ្ញើជូនសម្តេច ហ៊ុន សែន កាលពីប៉ុន្មានសប្តាហ៍មុននេះ អំពីការបរិច្ឆេទនៃការប្រជុំក្រុមការងាររបស់លោកមកកម្ពុជា គឺជាជំហានមួយបន្ទាប់ពីគណៈប្រតិភូរបស់យើងទៅប្រជុំនៅទីក្រុងញូវយ៉ក ដែលមានរូបខ្ញុំផ្ទាល់ដឹកនាំទៅធ្វើការនៅទីក្រុងញូវយ៉ក ។ ក្នុងលិខិតឯកឧត្តម កូហ្វី អាណាន់ បានស្នើបញ្ជូនកាលបរិច្ឆេទពីរ ទីមួយ គឺកាលបរិច្ឆេទនៅក្នុងខែកុម្ភៈ ហើយមួយទៀតគឺកាលបរិច្ឆេទនៅក្នុងខែមីនា ថ្ងៃទី១៣ ទៅ

ដល់ថ្ងៃទី១៦ ពីលិខិតលើកមុនៗ ហើយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បាន ផ្ញើលិខិតត្រឡប់ទៅជូនឯកឧត្តម កូហ្វី អាណាន់ វិញ ហើយយើងបានឯកភាពនូវកាលបរិច្ឆេទថ្ងៃទី១៣ ខែមីនា នេះ ។ ប៉ុន្តែយើងក៏បានជូនជាយោបល់ដែរ បើសិនជាគណៈប្រតិភូមកមុននេះមួយអាទិត្យនោះកាន់តែល្អទៅទៀត គឺកុំឲ្យវាជាន់ទៅនឹងថ្ងៃទី១៨ មីនា ដែលជាកាលបរិច្ឆេទចុងក្រោយដែលឯកឧត្តម កូហ្វី អាណាន់ លោកត្រូវធ្វើរបាយការណ៍ជូនមហាសន្និបាតនៃអង្គការសហប្រជាជាតិ ហើយកាលពីម្សិលមិញនេះ យើងក៏បានទទួលលិខិតរបស់ឯកឧត្តម កូហ្វី អាណាន់ ផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន វិញ ដោយបញ្ជាក់ថាលោកនឹងបញ្ជូនឯកឧត្តម ហេន កូរ៉េល ដែលជាអគ្គលេខាធិការរងនៃអង្គការសហប្រជាជាតិ ទទួលបន្ទុកផ្នែកច្បាប់នេះ មកភ្នំពេញនៅថ្ងៃទី១៣ រហូតដល់ថ្ងៃទី១៧ ខែមីនា ខាងមុខនេះ បានន័យថាមួយថ្ងៃមុនកាលបរិច្ឆេទកំណត់ដែលឯកឧត្តម លោក កូហ្វី អាណាន់ ត្រូវរាយការណ៍ជូនមហាសន្និបាតរបស់អង្គការសហប្រជាជាតិតាមស្មារតីនៃសេចក្តីសម្រេចចិត្តរបស់មហាសន្និបាទអង្គការសហប្រជាជាតិដែលកំណត់ថា៩០ថ្ងៃក្រោយសេចក្តីសម្រេចចិត្តបានន័យថា ថ្ងៃទី១៨ ខែ១២ ដែលសេចក្តីសម្រេចចិត្តបានអនុម័ត អ៊ីចឹងថ្ងៃទី១៨ ខែ៣ យោងតាមស្មារតីនៃសេចក្តីសម្រេចចិត្តថ្ងៃទី១៨ ខែ១២ គឺលោកត្រូវរាយការណ៍ជូនមហាសន្និបាតអង្គការសហប្រជាជាតិ ហើយក្រោយពីសម្តេចរដ្ឋមន្ត្រី ហ៊ុន សែន បានឆ្លើយតបទៅ ឯកឧត្តម កូហ្វី អាណាន់ វិញនេះ ដូចខ្ញុំបានជម្រាបអម្បាញ់មិញ ម្សិលមិញយើងបានទទួលលិខិតរបស់ឯកឧត្តម កូហ្វី អាណាន់ ផ្ញើជូនសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បញ្ជាក់ថានៅថ្ងៃទី១៣ ខាងមុខនេះគឺគណៈប្រតិភូក្រុមការងារដឹកនាំដោយអគ្គលេខាធិការរង ឯកឧត្តម ហេន ខូរ៉េល នឹងមកដល់ភ្នំពេញ ហើយនឹងស្នាក់នៅធ្វើការរហូតដល់ថ្ងៃទី១៧ ខែមីនា ។

**អ្នកសួរៈ** ឯកឧត្តម តើយើងត្រូវចរចាទៅលើបញ្ហាអ្វីខ្លះ?

**ឯកឧត្តម សុខ អានៈ** បាទ! ជាធម្មតាយើងចរចាគ្នាទៅលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជាជាមួយអង្គការសហប្រជាជាតិដែលជាអត្ថបទជាមូលដ្ឋាន ដែលអាចនិយាយបានថា ជាអត្ថបទបទដ្ឋានជាមូលដ្ឋាននៃកិច្ចសហ-ប្រតិបត្តិការរវាងកម្ពុជានិងអង្គការសហប្រជាជាតិ ។

**អ្នកសួរៈ** ឯកឧត្តមនិយាយពីខាងដើមមកថាតើនេះជាការចរចាចុងក្រោយឬ?

**ឯកឧត្តម សុខ អានៈ** បាទ! ជាការត្រឹមត្រូវដែលលោកលើកឡើងថា ជាការចរចាចុងក្រោយ ព្រោះនៅតែមួយថ្ងៃទេដែលឯកឧត្តម កូហ្វី អាណាន់ ត្រូវរាយការណ៍ជូនមហាសន្និបាត ព្រោះនៅថ្ងៃ១៨ លោកត្រូវរាយការណ៍ជូនមហាសន្និបាត អ៊ីចឹងត្រូវតែធ្វើការចរចាដល់ថ្ងៃទី១៧ អ៊ីចឹងយើងត្រូវសួរ យើងត្រូវចរចាបញ្ហាអី ដូចយើងជម្រាបអម្បាញ់មិញ គឺយើងនឹងផ្តោតការចរចាទៅលើសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនេះ ។ ដូច្នេះឥឡូវនេះយើងមានច្បាប់រួចហើយ ដែលកំពុងជាធរមាននៅក្នុងព្រះរាជាអាណាចក្រកម្ពុជា ដែលជាមូលដ្ឋាននៃការរៀបចំបង្កើតនូវអ្វីដែលយើងហៅថា អង្គជំនុំជម្រះវិសាមញ្ញ ។ អ៊ីចឹងច្បាប់ជាមូលដ្ឋាននោះយើងមាន ហើយអ្វីដែលយើងមិនទាន់មានហើយអ្វីដែលយើងត្រូវការឲ្យមាននោះ គឺអត្ថបទបទដ្ឋានមួយនេះជាមូលដ្ឋាននៃកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងអង្គការសហ-ប្រជាជាតិ ។

**អ្នកសួរៈ** តើការចរចាលើកមុនដែលឯកឧត្តមបានអញ្ជើញទៅទីក្រុងញូវយ៉ក តើបានទទួលលទ្ធផលដូចម្តេចខ្លះ? តើឯកឧត្តមមានសង្ឃឹមក្នុងការចរចាលើកក្រោយនេះទេ?

**ឯកឧត្តម សុខ អានៈ** បាទ! ជាធម្មតាគឺការចរចាក្រោយពេលដែលយើងគិតថា ក្រោយពេលតាំងពីខែកុម្ភៈ ឆ្នាំ២០០២ ពេលហ្នឹងដែលឯកឧត្តម ហេន ខូរែល បានបញ្ចប់ជាឯកតោភាគីនូវការចរចារវាងអង្គការសហប្រជាជាតិជាមួយនឹងកម្ពុជា នោះគឺវាគិតទៅមួយឆ្នាំ ហើយកាលពីខែ កាលពីចុងឆ្នាំកន្លងមកដែលខ្ញុំបានដឹកនាំក្រុមការងារទៅទីក្រុងញូវយ៉កនោះ គឺការចាប់ផ្តើមលើកទីមួយ ដូច្នេះការជួបប្រជុំមុន ថ្វីដ្បិតតែមានការជួបគ្នាដល់ទៅដប់ដង គឺថាខ្ញុំបានជួបប្រជុំរវាងគណៈប្រតិភូ៦ដង ជាមួយឯកឧត្តម ហេន ខូរែល ហើយខ្ញុំបានជួបប្រាស្រ័យជាមួយឯកឧត្តម កូហ្វី អាណាន់ មុន ដូចនេះ៧ដង ។ ហើយខ្ញុំបាទជួប អាយ ធូ អាយ

មីតធីង (eye to eye meeting) គឺជួបផ្ទាល់តែពីរនាក់ពាដងទៀត ដូច្នេះ បើទៅវា១០ដង កាលពីចុងឆ្នាំកន្លងមកនេះ ពេលដែលខ្ញុំស្នាក់នៅទីក្រុងញូវយ៉កមួយអាទិត្យនេះ គឺបានជួបប្រជុំដល់ទៅ ១០ដង ប៉ុន្តែវាតែមានការជួបគ្នាដល់ទៅ១០ដងនេះ ដែលនៅក្នុងលិខិតរបស់ឯកឧត្តម កូហ្វី អាណាន់ លោកប្រើពាក្យថា preparatory meeting ដើម្បីត្រៀមនូវការចរចា តែតាមពិតយើងចរចារគ្នាដល់ទៅ១០ឯណោះ។ អ៊ីចឹងហើយ ប៉ុន្តែវាតែមានការជួបគ្នា១០ដងមុនក្តី ក៏មិនអាចថាយើងដោះស្រាយបានមួយរយភាគរយនូវចំណុចដែលយើងមិនទាន់ឯកភាពគ្នានោះទេ អ៊ីចឹង វានៅសល់នូវចំណុចសេសសល់មួយចំនួន ដែលយើងនឹងត្រូវបន្តធ្វើការចរចានៅថ្ងៃទី១៣ ខែពាខាងមុខ ហើយសួរថាបញ្ហាអ្វីខ្លះ នោះគឺថាខ្ញុំក៏បានឯកភាពជាមួយឯកឧត្តម ហេន ខូរ៉េល យើងមិននិយាយពីខ្លឹមសារនៃការចរចានោះតាមរយៈមេឌា(media) ទេ តាមរយៈម៉ាស៊ីនពត៌មានទេ ព្រោះយើងចង់ឲ្យការចរចាគ្នា នោះប្រកបដោយផ្លែផ្កា ព្រោះថាបើយើងអត្ថាធិប្បាយពត៌មាន អ៊ីចឹងម្នាក់ៗអត្ថាធិប្បាយកត្រូវរៀងខ្លួន វានឹងនាំឲ្យមានការប៉ះទង្គិចគ្នាដែលរំខានទៅដល់ដំណើរការនៃការចរចា។

**អ្នកសួរៈ** ឯកឧត្តម តើឯកឧត្តមមានសុទិដ្ឋិនិយមក្នុងការចរចាលើកនេះទេ?

**ឯកឧត្តម សុខ អានៈ** បាទ! ចំពោះខ្លួនខ្ញុំ ខ្ញុំតែងតែមានសុទិដ្ឋិនិយម ដូចជាខ្ញុំបាននិយាយជាច្រើនដងហើយ ហើយខ្ញុំមិនកែប្រែពាក្យរបស់ខ្ញុំទេ ខ្ញុំតែងតែនិយាយថា ខ្ញុំមើលមិនឃើញថាមានបញ្ហាជាឧបសគ្គធំដុំនៅក្នុងដំណើរការនៃការចរចានោះទេ វាមានចំណុចមិនទាន់ឯកភាពគ្នា ប៉ុន្តែវាមិនមែនជាឧបសគ្គធំដុំពេកនោះទេ។

**អ្នកសួរៈ** ឯកឧត្តម បើសិនជាជំហររបស់គណៈប្រតិភូ UN ទាមទារឲ្យយក អៀង សារី ទៅកាត់ទោស តើជំហររបស់រដ្ឋាភិបាលយ៉ាងម៉េចដែរ?

**ឯកឧត្តម សុខ អានៈ** អំពីបញ្ហានេះយើងមានមាត្រាមួយនៅក្នុងច្បាប់របស់យើងដែលកំពុងមានជាធរមាន គឺថាបានចែងបញ្ហានេះហើយ។ ហើយនៅក្នុងសេចក្តីព្រាងនៃកិច្ចព្រមព្រៀងនោះក៏មានចែង ដែលយើងប្រើពាក្យថាបញ្ហាលើកលែងទោសនោះដែរតាមស្មារតីច្បាស់លាស់ណាស់ ដែលភាគីទាំងសងខាងអាចព្រមព្រៀងទទួលយកបានទៅវិញទៅមក។

**អ្នកសួរៈ** ចុះយ៉ាងម៉េចដែរ អំពីរឿងពាក់ព័ន្ធទៅនឹងមុខតំណែងរបស់ឯកឧត្តម ជា សុផារ៉ា?

**ឯកឧត្តម សុខ អានៈ** ហ្នឹងហើយ គាត់ទៅចូលរួមក្នុងកិច្ចប្រជុំចលនាមិនបក្សសម្ព័ន្ធនោះដែរ ដែលសព្វថ្ងៃ ឯកឧត្តម ជា សុផារ៉ា ជាទីប្រឹក្សារបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។

**អ្នកសួរៈ** អ៊ីចឹងលោកមិនបានទៅធ្វើជាឯកអគ្គរាជទូតនៅប្រទេសភូមាទេ?

**ឯកឧត្តម សុខ អានៈ** បើលោកធ្វើជាទីប្រឹក្សាហើយ ទៅធ្វើឯកអគ្គរាជទូតម្តេចហ្នឹងកើត អរគុណ។

**អ្នកសួរៈ** តើឯកឧត្តមបានដឹងពីរឿងមហាសន្និបាតរបស់គណបក្សប្រជាជនទេ?

**ឯកឧត្តម សុខ អានៈ** នៅលើយន្តហោះ ខ្ញុំបានមើលកាសែតយើងអម្បាញ់មិញឃើញគេដាក់ថា មហាសន្និបាតរបស់គណបក្សប្រជាជន គេសរសេរដាក់ថាថ្ងៃទី២៨ ខែមីនា។ ខ្ញុំសូមធ្វើការកែតម្រូវវិញ នេះគឺគណបក្សប្រជាជនត្រៀមនឹងធ្វើមហាសន្និបាតនេះនៅថ្ងៃទី២៨ ខែ៤ មិនមែនខែ៣ទេ។ ដូច្នេះ ខ្ញុំសូមកែតម្រូវពត៌មានដែលឃើញនៅក្នុងកាសែតអម្បាញ់មិញនេះ ខ្ញុំសូមបញ្ជាក់ថាថ្ងៃ២៨ ខែមេសា ខែ៤ មករា កុម្ភៈ មីនា មេសា នៅខែមេសា ត្រូវជាខែ៤ មិនមែនខែ៣ នោះទេ។

**អ្នកសួរៈ** តើប្រជុំពីការងារអ្វី?

**ឯកឧត្តម សុខ អានៈ** ត្រៀមការងារការបោះឆ្នោត ដូច្នោះជាស្វ័យប្រវត្តិទេ ការពិភាក្សាគ្នានូវខ្លឹមសារដែលធំនេះគឺការត្រៀមលក្ខណៈសម្រាប់ការបោះឆ្នោតជាសកល នៅខែ៧ ឆ្នាំ២០០៣នេះ ហើយខ្លឹមសារផ្សេងៗនោះ ខ្ញុំមិនបាច់ជម្រាបទេ ព្រោះថានៅពេលសន្និបាតនោះនឹងដឹងហើយ ហើយបើជម្រាបប្រាប់ដឹងមុន គេមិនចាំបាច់ធ្វើមហាសន្និបាតអីទៀត ដូច្នេះ ខ្លឹមសារធំ គឺការងារត្រៀមការបោះឆ្នោតនេះឯង ដូចនេះហើយ ធ្វើមហាសន្និបាតនៅខែ៤ ធ្វើមហាសន្និបាតហើយ យើងនឹងត្រៀមចូលយុទ្ធនាការសម្រាប់បោះឆ្នោត។

# ជីវិតពលិកម្មដើម្បីបក្សនិងបដិវត្តន៍

លោកពូ គីវ គាវ បើរស់នៅដល់សព្វថ្ងៃមានអាយុប្រមាណ៧៨ឆ្នាំហើយ ស្រុកកំណើតរបស់គាត់នៅ ឆាត់អោ ស្រុកបទុមសាគរ ខេត្តកោះកុង ។ ពុំមាននរណាម្នាក់បានដឹងថាឪពុកម្ដាយបងប្អូនរបស់គាត់ឈ្មោះអ្វី និងមានប៉ុន្មាននាក់នោះទេ ។

ឪពុកចិញ្ចឹមរបស់គាត់ឈ្មោះលោកតា មៀច (ស្លាប់) ស្រុកកំណើតនៅភូមិអង្គរនាប ឃុំត្រាំកក់ ស្រុកត្រាំកក់ ខេត្តតាកែវ បច្ចុប្បន្ននេះ ។ សម័យអាណានិគមបារាំងត្រួតត្រានៅប្រទេសកម្ពុជាយើង លោកតា មៀច បួសជាព្រះសង្ឃ ហើយនិមន្តទៅកាន់ខេត្តកោះកុងនិងទទួលយកកុមារ គីវ គាវ ពីកោះកុងមកនៅវត្តអង្គរនាបនេះរៀងរហូតមក ។

លោកតា មៀច លាចាកសិក្ខាបទ ក៏នៅតែទទួលកុមារ គាវ ធ្វើជាកូនចិញ្ចឹមដដែល ។ លុះពេញវ័យក៏ឲ្យកូនសាងផ្នួសរៀនសូត្រ ចេះដឹងលេខនព្វន្ត ចារសាស្ត្រាស្លឹករឹត ហើយថែមទាំងចេះនិយាយភាសាចិន ថៃ និងវៀតណាម យ៉ាងស្ទាត់ទៀតផង ។

បន្ទាប់ពីលាចាកសិក្ខាបទ ឪពុកចិញ្ចឹមបានរៀបការឲ្យជាមួយ ស៊ុយ ឃី ជាកូនស្រីច្បងរបស់លោកតា ស៊ុយ ញ៉ៅ និងយាយ ប៉េះ គា នៅភូមិអង្គរនាប ឃុំត្រាំកក់ បច្ចុប្បន្ននេះ ។

កាលនោះ គីវ គាវ បានចូលរួមចលនាតស៊ូឥស្សរៈ និងយួនយៀកមិញ ដើម្បីបំផុសចលនាប្រជាជនវាយកម្ទេចឥដ្ឋដែលពួកបារាំងយកមកគរទុកបម្រុងធ្វើប៉ម ។ ពួកបារាំងមិនចុះចាញ់ឡើយ បានសម្រេចសង់ប៉ម១គីឡូម៉ែត្រមួយៗ តាមបណ្ដោយផ្លូវជាតិលេខ៣រហូត ដោយគេណ្ឌប្រមូលប្រជាពលរដ្ឋមករស់នៅជាភូមិប្រមូលផ្ដុំ(ភូមិយុទ្ធសាស្ត្រ) ក្បែរៗផ្លូវជាតិនិងប៉មរបស់ខ្លួន ។

ការប្រយុទ្ធរវាងពួកបារាំងនិងខ្មែរឥស្សរៈ យៀកមិញកាន់តែមានសភាពស៊ុតស្មាញនិងសាហាវបំផុត ។ ប្រជាជនត្រូវបារាំងកេណ្ឌដាក់វេនឲ្យជួយយាមប៉មចម្រុះជាមួយ ប៉ាត់ទីសង់ ។

ពូ គីវ គាវ បាននាំកម្លាំងទ័ពឥស្សរៈចូលវាយកំទេចប៉មតាមបណ្ដោយផ្លូវលេខ៣ទាំងអស់ក្នុងយប់តែមួយនាឆ្នាំ១៩៥៣ ។

ពេលនោះ អ្នកមានឈ្មោះក្នុងវេនយាមប៉មទាំងអស់ ត្រូវចៅហ្វាយស្រុកត្រាំកក់ឈ្មោះ វង្ក សារ៉ុត ប្រមូលយកទៅដាក់គុកគ្មានសល់ ។ ក្នុងនោះ គីវ គាវ ក៏ជាប់គុកដែរ លុះក្រោយសន្និសីទហ្សឺណែវ ឆ្នាំ១៩៥៤ ទើបត្រូវដោះលែងមកវិញ ។

ប្រទេសកម្ពុជាមានសន្តិភាពវិញ ហើយរៀបចំធ្វើការបោះឆ្នោតពហុបក្ស ។ ខ្មែរឥស្សរៈបានមកចូលរួមក្នុងសង្គមជាតិវិញដោយបង្កើតបក្សមួយឈ្មោះថា គណបក្សប្រជាជន មានរូបសញ្ញានង្គ័ល ។

យួនយៀកមិញ ត្រូវដកទ័ពទៅស្រុកគេវិញដោយនាំទាំងយុវជន-កុមារខ្មែរជាច្រើនពាន់នាក់ទៅជាមួយផង ។

ពេលបោះឆ្នោតគណបក្សប្រជាជនសម្រេចមិនដាក់បេក្ខភាពទេ ហើយប្ដូរយុទ្ធសាស្ត្រទៅធ្វើការតស៊ូនយោបាយផ្ទៃក្នុងវិញ ។ ពូ គីវ គាវ ស្ថិតនៅក្នុងសាខាបក្សស្រែក្នុង ស្រែវែង ភូមិភាគនិរតី មាន តាម៉ុក ជាលេខាសាខា ។ មានពត៌មាន មាន ឈ្មោះប្រជាជនបោះពុម្ព ហើយចែកផ្សាយតាមសមាជិកក្នុងសាខារបស់គេ ។ ពេលនោះ មានលោក ត្រឹង អ៊ុង ជាអ្នកនាំយកពីបណ្ណាធិការ នៅភ្នំពេញមកទីនេះ ។

ឆ្នាំ១៩៦២ ពូ គាវ ទៅរកស៊ីធ្វើចម្ការកប្បាសនៅត្រែង ឃុំអណ្ដើកហែប ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង ។ បន្ទាប់ពីបានរៀបចំសមាជិកក្នុងសាខាឈ្មោះ កែវ ម៉ត់ ឲ្យឈរជាបេក្ខភាពបោះឆ្នោតមេឃុំ គឺពុំបានជ័យជម្នះ ពេលនោះជ័យលាភីត្រូវបានទៅលោកតា ស៊ាន សុខ ជាមនុស្សរបស់គណបក្សសង្គមរាស្ត្រនិយម ។ ពេលរស់នៅខេត្តបាត់ដំបង ពូ គីវ គាវ បានធ្វើការកសាងកម្លាំងបញ្ចូលយុវកកដល់យុវជន២រូបឈ្មោះ សៀង ង៉ាន់ និង ប៊ិច អ៊ូច ដោយទាក់ទងជាមួយមេដឹកនាំបក្សភូមិភាគពាយ័ព្យ នៅភ្នំវាយចាប ជាប់រហូត ។

ឆ្នាំ១៩៦៧ ចលនាតស៊ូនយោបាយនៅបាត់ដំបង បានប្ដូររូបភាពមកធ្វើកុប្បកម្មដណ្ដើមអាវុធ ។

រដ្ឋាភិបាលក៏បានបង្ក្រាបចលនាបះបោរនេះយ៉ាងខ្លាំងក្លាបំផុត អ្នកតស៊ូផ្ទៃក្នុងនិងអ្នកតស៊ូក្នុងព្រៃត្រូវកាត់ផ្ដាច់ពីគ្នា ។

ការពារសន្តិសុខលើផ្ទៃប្រទេសជាតួនាទីរបស់កងយោធពលខេមរភូមិន្ទ និងមានចាត់តាំងភ្នាក់ងារបង្កប់ជាប្រជាជនឲ្យជួយស៊ើបការណ៍ ស្រាវជ្រាវប្រមូលព័ត៌មានសម្ងាត់ ការតស៊ូមានសភាពតឹងតែងនិងគ្រោះថ្នាក់ជាទីបំផុត ។ ស្ថិតក្នុងស្ថានការណ៍នេះ ក្រុមរបស់លោកពូ គីវ គាវ ត្រូវបែកមុខមិនអាចរស់នៅបានក៏នាំគ្នាវិលត្រឡប់មកស្រុកកំណើតវិញ ក្នុងឆ្នាំ១៩៦៧ ។

នៅភូមិភាគនិរតី វរសេនីយ៍ត្រី ហ៊ិន នីម ដែលមានបន្ទាយនៅភ្នំនរាយណ៍និងអូរកំបុតជាមូលដ្ឋាន ក៏ចាប់ផ្តើមបង្ក្រាបពួកខ្មែរក្រហមក្រោមការដឹកនាំរបស់ តាម៉ុក យ៉ាងខ្លាំងក្លាបំផុតដែរ ។

ពេលមកដល់ស្រុកកំណើត សភាពការណ៍មានសភាពតឹងតែងបំផុត គាត់ត្រូវគេតាមឃ្លាំមើលជានិច្ច មិនអាចធ្វើសកម្មភាពបានទាល់តែសោះ ។ រយៈពេល៣ថ្ងៃមកដល់ស្រុកកំណើតអំណោយផលល្អ ដោយទីនេះជាមូលដ្ឋានចាស់របស់គាត់ខ្សែរយៈស្គាល់គ្នាទាំងអស់ គ្មានអ្វីរារាំងគាត់បានឡើយ ។ ថ្វីដ្បិតតែគាត់មិនដើរទៅណាពីផ្ទះ តែបក្សពួករបស់គាត់ឈ្មោះ ជាស ឈន មុខរបរដើរទិញជ្រូក មានភារៈជាអ្នកបើកផ្លូវ ។

តាមសម្តីពូ ជាស ឈន គាត់បានទាក់ទងតា សុក ហ៊ិន ហៅ មក់ ។ តាមក់ បន្តតាម តារាម រួច តារាម បន្តទៅតាអឿង នៅភូមិស្រែដំរៅ ឃុំសំរោង ។

យប់ចេញដំណើរ តាអឿង តាឈន នៅវង់ចាំភូមិចាស់ត្រពាំងស្ពាន ចម្ងាយ១០០ម ខាងលិចវត្តអង្គរនោប ។

បងសែន កូន តាមក់ ជាអ្នកនាំ ពូគាវ ចេញពីផ្ទះបងអ៊ួច (តាមសម្តីបង អ៊ួច) ។

ប្រមាណមួយខែក្រោយមក សៀង ង៉ាន់ បាននិយាយជាលេសប្រាប់អ្នកស្រុកថាៈ ទៅរកស៊ីធ្វើកម្មករនៅកំពង់សោម (ក្រុងព្រះសីហនុ) ការពិត គាត់ទៅចូលរួមតស៊ូនៅក្នុងព្រៃ ។

ឆ្នាំ១៩៦៧ មក ១៩៧០ ក្រុមគាត់តែងចុះមកយកស្បៀង ថ្នាំពេទ្យ ខោអាវ។ល។ និងផ្សព្វផ្សាយនយោបាយរបស់គេនៅពេលយប់ ទោះបីកងឈ្លក់ ទាហាន ប៉ូលិស យាមល្បាតយ៉ាងតឹងរ៉ឹងក៏ដោយ ក៏ពួកគាត់ចុះមូលដ្ឋានបានញឹកញាប់រាប់មិនអស់ប្រកបដោយសុវត្ថិភាព ។

ពេលថ្ងៃ ស្វែងរកជួបប្រជាជននៅក្នុងព្រៃដែលរកស៊ីកាប់ឈើ ចាំងឈើ ដើម្បីអប់រំពង្រឹកកម្លាំងបដិវត្តន៍ថ្មីបន្ថែម ។

មុនពេលរត់ចូលព្រៃ ពូ គីវ គាវ អ្នកមីង ស៊ុយ យី ជាភរិយា មានកូនក្នុងបន្ទុក៥នាក់ គឺ÷ ១) ឈ្មោះ គីវ គីម ប្រពន្ធឈ្មោះ ជាត់ រៀបការឆ្នាំ១៩៦៨ មានកូន៣នាក់ ។ ២) ឈ្មោះ គីវ រ៉ន ស្រី ប្តីឈ្មោះ វឿន ជីដូនមួយ តាម៉ុក រៀបការឆ្នាំ១៩៧៤ ។ ៣) ឈ្មោះ គីវ ហេង ប្រុស ធ្វើកងទ័ព ។ ៤) ឈ្មោះ គីវ ម៉ុម ស្រី ធ្វើនីរសាតំបន់១៣ ។ ៥) ឈ្មោះ គីវ សារុន ស្រី កុមារី សព្វថ្ងៃមានប្តី នៅរស់ ។

ឆ្នាំ១៩៧០ ស្រុកត្រាំកក់ បានក្លាយជាតំបន់រំដោះ ពូគាវ ពេលនោះ មានតួនាទីជាលេខាបក្សស្រុក១០៥ តំបន់១៣ ហើយមានកូនស្រីម្នាក់ទៀត ឈ្មោះ គីវ ចិន សព្វថ្ងៃមានប្តីនៅរស់ ។

ក្រោយរំដោះឆ្នាំ១៩៧៥ តាម៉ុក បានដកគាត់ពីលេខាបក្សស្រុកមកអង្គភាពលត់ដំនៅវត្តវិហារខ្ពស់ ក្រោយមក គេយកទៅកងផលិតតំបន់នៅស្រុក១០៨ ពុំដឹងមូលហេតុអ្វីហើយបាត់ខ្លួនរហូតសព្វថ្ងៃនេះ ។ ចំណែកកូន៤នាក់ធំៗត្រូវគេចាប់បាត់ដំណឹងព្រមពេលជាមួយគ្នានេះដែរ ។

មីង ស៊ុយ យី ជាប្រពន្ធរបស់គាត់ រួមនឹងកូនស្រីតូចៗ គីវ សារុន និង គីវ ចិន ត្រូវគេយកទៅដាក់នៅដីវៃជ្រៃអូរញ៉ោ ទទួលរងទារុណកម្មយ៉ាងវេទនាជាមួយកូនប្រសាស្រីឈ្មោះ នាង ជាត់ និងចៅកំព្រា៣នាក់ ។ យាយយី សព្វថ្ងៃស្លាប់ហើយ ។

ចំណែក វឿន ប្អូនជីដូនមួយតាម៉ុក ពេលចាប់នាង គីវ រ៉ន ជាភរិយា អង្គការបានរៀបចំគូស្រករថ្មីឲ្យម្នាក់ទៀត ដើម្បីកុំឲ្យខូចចិត្ត ព្រោះមានឋានៈជាស្នងការវរសេនាតូចរបស់តំបន់១៣ ។

នេះជាឆាកជីវិតដែលពោរពេញទៅដោយពលីកម្ម ដើម្បីបក្សកុម្មុយនិស្តនិងបដិវត្តន៍ ហើយត្រូវបានបក្សនិងបដិវត្តន៍ជូនគ្រួសារ គីវ គាវ នូវឃាតកម្មឃោរឃៅព្រៃផ្សៃ ទទួលរងទារុណកម្មយ៉ាងខ្លោចផ្សា គួរចារឹកទុកក្នុងទំព័រទស្សនាវដ្តីរបស់លោកទុកជាប្រវត្តិសាស្ត្រសម្រាប់កូនខ្មែរជំនាន់ក្រោយ ។

ចំណែក សៀង ង៉ាន់ ក្រោយឆ្នាំ១៩៧៥ ជាលេខាបក្សតំបន់៥ ភូមិភាគពាយ័ព្យ ក៏ត្រូវបាត់ខ្លួន បាត់ដំណឹងរហូតសព្វថ្ងៃ ។

សូមលោកនាយកជួយស្រាវជ្រាវរកឈ្មោះ សៀង ង៉ាន់ ហៅសមមិត្ត ភន លេខាបក្សតំបន់៥ ក្រែងអាចមានឈ្មោះត្រូវគេសម្លាប់នៅស-២១ នេះ ។

**អៀប ឌុច**

# មិនត្រូវធ្វើឱ្យយុត្តិធម៌ទៅជារឿងសាមញ្ញទេ

ខ្ញុំសូមឆ្លៀតឱកាសក្នុងពេលបុណ្យចូលឆ្នាំសកលនិងបុណ្យចូលឆ្នាំចិនដើម្បីជូនពរចំពោះក្រុមការងាររបស់លោកនិងរូបលោកផ្ទាល់ ។ ឆ្នាំ២០០៣ ជាឆ្នាំមួយពោរពេញទៅដោយរឿងដែលគួរឲ្យភ្ញាក់ផ្អើលជាច្រើនទាក់ទងទៅនឹងយុត្តិធម៌និងការតស៊ូប្រឆាំងនឹងភាពរួចទោស (និទណ្ឌភាព) ។ ចំពោះរឿងនេះ ខ្ញុំបានអានវគ្គនីមួយៗនៃសេចក្តីថ្លែងការណ៍របស់លោកដែលដកស្រង់មកចុះផ្សាយដោយលោក *J.C. Pomonti* ក្នុងកាសែត *Le monde* ចេញថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៣រួចហើយ ។ ខ្ញុំសូមអនុញ្ញាតធ្វើការកត់សម្គាល់ខ្លះៗដូចខាងក្រោម÷

ខ្ញុំក៏មានជំនឿដូចលោកចំពោះប្រសិទ្ធភាពនៃប្រព័ន្ធផ្សព្វផ្សាយ (les medias) និងសាធារណៈមតិទូទៅ ។ ប៉ុន្តែយើងត្រូវរំឭកហេតុការណ៍សំខាន់ៗឡើងវិញឲ្យបានច្រើនដងនៅក្នុងពិភពលោក ដែលអ្នករងគ្រោះទាំងនោះគ្មានកងទ័ព ទាំងកម្លាំងប៉ូលិស ទាំងរដ្ឋអាជ្ញា ដើម្បីធ្វើឲ្យបំណងរបស់គេត្រូវបានអនុវត្តឡើយ ដូច្នេះគំនិតសុទិដ្ឋិនិយមជ្រុលហួសហេតុទាំងអស់ត្រូវរក្សាឲ្យល្អលើកលែងតែដើម្បីប្តឹងផ្តល់ នៅពេលដែលកន្លែងកប់សាកសពមួយក្នុងចំណោមកន្លែងកប់សាកសពជាច្រើនរបស់ពួកគេដែលស្លាប់ដោយគ្រាប់កាំភ្លើងឬព្រនង់របស់ពួកកាន់អំណាចផ្តាច់ការត្រូវបានគាស់កកាយ ។

នៅប្រទេសកម្ពុជា ក្នុងរឿងក្តីពួកខ្មែរក្រហម ប្រសិនបើការកាត់ក្តីកើតមានក្នុងប្រទេសនេះ ដែលពួក នួន ជា, អៀង សារី និង ខៀវ សំផន...។ល។ សុទ្ធតែមានបុព្វសិទ្ធិដូចមន្ត្រីជាន់ខ្ពស់ម្នាក់របស់ប្រទេស ជាអាទិ៍ពួកនេះនឹងបង្វែរការកាត់ក្តីនេះជាគុណប្រយោជន៍សម្រាប់ខ្លួនដោយមធ្យោបាយផ្សេងៗដែលអាចយល់បានដោយងាយគឺ ការសងសឹក ការគំរាមកំហែង ការព្យាបាទមិនចេះចប់ និងការប្រហារជីវិត ។

ដោយហេតុនេះ ខ្ញុំមានគំនិតដែលចេះតែសង្ស័យដូចលោកដែរពីលទ្ធផលនៃការកាត់ក្តីនោះ ។ ខ្ញុំជឿជាក់ថា សាលាក្តីមួយដែលគ្មានមូលដ្ឋានរឹងមាំនឹងផ្តល់នូវការវិនិច្ឆ័យមួយដែលក្លែងបន្លំ ។ ដើម្បីធ្វើឲ្យគំនិតរបស់ខ្ញុំរឹតតែច្បាស់ ខ្ញុំសូមអនុញ្ញាតលើកឧទាហរណ៍ខ្លះៗមកនិយាយជាសំអាងដូចតទៅៈ មនុស្សកំបុតដៃម្នាក់អាចថែទាំផ្កាក្នុងសួនដោយត្រឹមត្រូវបានទេ អ្នកមានជើងតែម្ខាងអាចប្រណាំងប្រជែងរត់ចម្ងាយ ១០០ម៉ែត្របានទេ តើគេឈរលើកៅអីមួយដែលមានជើងបី ហើយថែមទាំងជើងពីរកើតទេ? ។ល។ ចំពោះផ្នែកទី២នៃទស្សនៈរបស់លោកគឺស្ថិតនៅត្រង់យល់ថា "វានឹងមិនបំពានសាធារណជនឡើយ" ហើយថា"ពួកអ្នករងគ្រោះនឹងទៅជាចៅក្រមពិតប្រាកដ" ។ ខ្ញុំយល់ស្របតាមលោក ។ ដូច្នេះជនរងគ្រោះបានវិនិច្ឆ័យទោសចំពោះបទឧក្រិដ្ឋរបស់ពួកគេរួចទៅហើយ នេះគឺខ្ញុំនិយាយពីពួកអ្នកដែលរួចផុតពីគ្រោះថ្នាក់ ។ ពួកខ្មែរក្រហមបានកាត់ទោសដោយការបង្ខាំងជនរងគ្រោះឲ្យនៅមួយកន្លែងជានិច្ចកាល ឬកាត់ទោសប្រហារជីវិតតែម្តង ។

គេនឹកឃើញថា នៅថ្ងៃបន្ទាប់ពីការដួលរលំរបស់ពួកខ្មែរក្រហម ជនរងគ្រោះដែលរួចផុតពី(គ្រោះថ្នាក់) បានព្រួតដៃគ្នាកាត់ទោសសម្លាប់កម្មាភិបាលនិងពួកអ្នករួមគំនិត ដែលពួកគេបានជួបប្រទះក្នុងដំណើររត់គេចរៀងៗខ្លួនរបស់កម្មាភិបាលនិងពួកអ្នកសមគំនិតទាំងនោះនៅពេលបានដឹងពីការមកដល់របស់ពួកអ្នកលុកលុយវៀតណាម! ។ ពួកគេបានកាត់ទោសអ្នកទាំងនោះដោយសម្លាប់ចោលតែម្តង ។ សាកសពពួកខ្មែរក្រហមនៅរាយដេរដាសតាមផ្លូវនានា ។

ប៉ុន្តែខ្ញុំសូមប្រាប់លោកថា នោះពុំមែនជាយុត្តិធម៌ទេ ។ គេត្រូវតែចៀសវាងច្បាប់ តាលីយ៉ុង (ច្បាប់ដែលបញ្ញត្តិដាក់ទណ្ឌកម្មឲ្យធួននឹងកំហុសបានន័យថា បើគេធ្វើខ្វាក់ភ្នែកត្រូវធ្វើឲ្យអ្នកនោះខ្វាក់ភ្នែកវិញ បើនិយាយឲ្យខ្លីគឺភ្នែកសងភ្នែកដៃសងដៃ) ។ ប៉ុន្តែ សូមបញ្ជាក់ថាប្រសិនបើពួកអ្នករងគ្រោះសុទ្ធតែជាចៅក្រមពិតប្រាកដគឺថា ពួកខ្មែរក្រហមត្រូវបានកាត់ទោសរួចទៅហើយ! ។

លើកលែងតែលោក Pomonti កាត់យកសម្តីរបស់លោកមួយចំណែកចេញ ជាការប្រសើរគេមិនត្រូវធ្វើឲ្យយុត្តិធម៌ទៅជារឿងសាមញ្ញទេ ។ ម្នាក់ៗមានតួនាទីរៀងៗខ្លួន ។ ពួកចៅក្រមមានភារកិច្ចកាត់ក្តី ។ វិនិច្ឆ័យទោសពួកខ្មែរក្រហមនៅប្រទេសកម្ពុជា គឺការវិនិច្ឆ័យមិនល្អមួយ ។ ភស្តុតាងគឺថា ការវិនិច្ឆ័យទោសពួកខ្មែរក្រហមនៅឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញពុំមានតម្លៃគតិយុត្តិណាមួយទាល់តែសោះ គឺដោយសារតែអឺចឹងហើយទើបគេមានបំណងវិនិច្ឆ័យទោសពួកមេដឹកនាំខ្មែរក្រហមជាថ្មីនោះ ។

ចំពោះនាទីរបស់ពួកអ្នករងគ្រោះ គឺប្តឹងផ្តល់និងធ្វើសាក្សី ។ ដើម្បីវិញ្ញាណក្ខ័ន្ធពួកអ្នកស្លាប់ (យ៉ាងហោច) គេមិនត្រូវបង្កើតឲ្យមាន

តុលាការមួយដែលគ្មានមូលដ្ឋានរឹងមាំឡើយ ។ រៀបចំវិនិច្ឆ័យទោសពួកខ្មែរក្រហមនៅប្រទេសកម្ពុជាពុំមែនផ្តល់យុត្តិធម៌ដល់ជនរងគ្រោះឡើយ ។

ប៉ុន្តែលោកអះអាងថា ការរៀបចំកាត់ទោសពួកខ្មែរក្រហមនៅប្រទេសកម្ពុជា "នឹងនាំមកនូវជោគជ័យដល់គណបក្សប្រជាជនកម្ពុជាលើពួកខ្មែរក្រហម" ។ គឺត្រឹមត្រូវណាស់ ។ នេះគឺជាលទ្ធផលតែមួយគត់ដែលរាជរដ្ឋាភិបាលត្រូវការខាងផ្នែកនយោបាយ ។ ខ្ញុំអះអាងដូចគ្នាថា នេះជាកន្លល់ធំបំផុតរបស់រាជរដ្ឋាភិបាល ។ ក្នុងរឿងនេះ បើតុលាការជាចលករនៃសកម្មភាពរបស់ខ្លួន គេច្បាស់ជាឲ្យចាប់ខ្លួនពួកមេដឹកនាំខ្មែរក្រហមដែលខ្ញុំបានរាប់ឈ្មោះតាំងពីយូរមកហើយ ។ ប៉ុន្តែរាជរដ្ឋាភិបាលមិនដែលមានឆន្ទៈនឹងធ្វើទាល់តែសោះ ។ រាជរដ្ឋាភិបាលពុំមានបំណងថា យុត្តិធម៌ត្រូវតែរៀបចំតាមបណ្តាបទដ្ឋានគតិយុត្តិឡើយ ។

ការកត់សម្គាល់ទាំងនេះគឺ សំដៅការពារការពិតជាសាធារណៈនៃស្ថានភាពរបស់ជនរងគ្រោះទាំងឡាយដែលសិទ្ធិផ្សេងៗត្រូវបានគេធ្វើមិនដឹងមិនឮតាំងពី២៧ឆ្នាំមកហើយ ។







រាំប៊ុយយ៉េត, ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០០៣

**ហុករ៉េង ឆាយ**

អគ្គលេខាធិការគណៈកម្មការជនរងគ្រោះពីរបបខ្មែរក្រហម

# ជាពុទ្ធិ ជាគតិ និងជាការស្រាវជ្រាវ

ជាបឋម ខ្ញុំសូមឱកាសបន្តិចដើម្បីជម្រាបជូនលោកនាយកថា ខ្ញុំមានកិត្តិយស និងមានវាសនាដោយបានទទួលនូវការផ្តល់នូវសៀវភៅល្អៗជាច្រើនដែលបានរៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា តាមរយៈលោក ទេព ម៉េងឃាន ។ សៀវភៅទាំងអស់នេះ មានជាអាទិ៍ ទស្សនាវដ្តីស្វែងរកការពិតចាប់ពីលេខទី១ ខែមករា ឆ្នាំ២០០០ រហូតដល់បច្ចុប្បន្ននិងបន្តទៅទៀត, សៀវភៅ "មុនដំបូងខ្មែរក្រហមសម្លាប់ប៉ាខ្ញុំ", សៀវភៅ "អាន់ប្រែង", សៀវភៅ "ជនរងគ្រោះនិងជនដៃដល់" ព្រមទាំងឯកសារសំខាន់ៗដទៃទៀត ។ល ។ ការផ្តល់ជូនរបស់លោកនាយកចំពោះរូបខ្ញុំមានតម្លៃ និងមានជីវិតជានិរន្តរ៍សម្រាប់ការងាររបស់ខ្ញុំ ។ ទាំងនេះគឺជាមាស ជាប្រាក់ និងជាប្រទីបដែលអាចឲ្យយើងមើលឃើញអំពីអតីតកាលនិងសម្លឹងទៅអនាគតប្រកបដោយភាពប្រយ័ត្នប្រយែង ។ ខ្ញុំយល់ថាកិច្ចការរបស់លោកបានផ្តល់ កំពុងផ្តល់ និងបន្តផ្តល់ជាពុទ្ធិ ជាគតិ និងជាការស្រាវជ្រាវមួយសម្រាប់កុលបុត្រខ្មែរគ្រប់ជំនាន់ ។ នៅពេលណាខ្ញុំលើកយកទស្សនាវដ្តីស្វែងរកការពិតរបស់លោកមកអាន អារម្មណ៍របស់ខ្ញុំហាក់វិលត្រឡប់ទៅរកអតីតកាល២៨ឆ្នាំមុននេះភ្លាម ។ សេចក្តីវេទនា ភាពភ័យខ្លាច និងអនុស្សាវរីយ៍អាក្រក់បានដក់ជាប់ក្នុងអារម្មណ៍ខ្ញុំជានិច្ច ។ ឪពុករបស់ខ្ញុំត្រូវបានមនុស្សខ្មែរក្រហមចងក្រៀកបោះដាក់លើឡានយកទៅបាត់រហូត (ប្រហែលជាខែមិថុនា ១៩៧៧) ។ ស្បែកជើងរបស់របរប្រើប្រាស់ជាប់នឹងខ្លួនរបស់គាត់ត្រូវបានកូនឈ្លបខ្មែរក្រហមយកប្រើប្រាស់មានន័យថាគេសម្លាប់គាត់ហើយ ព្រោះគាត់ជាសាស្ត្រាចារ្យ គឺជាខ្មាំងរបស់អង្គការ ។ ប្អូនស្រីខ្ញុំស្លាប់ព្រោះគ្មានថ្នាំ និងអ្នកថែទាំ ។

ជាចុងក្រោយ ខ្ញុំសូមថ្លែងអំណរគុណជាអនេកចំពោះការផ្តល់ជូននូវសៀវភៅ និងឯកសារទាំងឡាយរបស់លោកនាយកដល់រូបខ្ញុំ ។ សង្ឃឹមថាការផ្តល់នេះនឹងមានជាបន្តទៀតតទៅអនាគត ។ ឆ្លៀតឱកាសបុណ្យចូលឆ្នាំខ្មែរឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំមមែ បញ្ចស័ក ព.ស២៥៤៧ ខ្ញុំបាទ ព្រមទាំងក្រុមគ្រួសារ សូមប្រសិទ្ធិពរជ័យជូនចំពោះលោកនាយកព្រមទាំងសហការីរបស់លោកទាំងអស់ ប្រកបតែនឹងពុទ្ធពរទាំង៥ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ។






ភ្នំពេញថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៣

ដោយសេចក្តីគោរព

***ទាវ សារៈមុនី***



ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 40, April 2003.**

**Funded by Norway, Sweden, Switzerland, Netherlands and USA.**